ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកិច្ចការនារី
MINISTRY OF WOMEN'S AFFAIRS

# នារីរតនៈទី ៦

## ផែនការយុទ្ធសាស្ត្រ
## ដើម្បីលើកកម្ពស់សមភាពយេនឌ័រ
## និងការបង្កើនភាពអង់អាចដល់ស្ត្រីនិងក្មេងស្រី

## ឆ្នាំ២០២៤-២០២៨

# នារីរតនៈទី ៦

## ផែនការយុទ្ធសាស្ត្រ
## ដើម្បីលើកកម្ពស់សមភាពយេនឌ័រ
## និងការបង្កើនភាពអង់អាចដល់ស្ត្រីនិងក្មេងស្រី
## ឆ្នាំ២០២៤-២០២៨

ធ្វើនៅ រាជធានីភ្នំពេញ, ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧

ត្រូវនឹងខែមីនា ឆ្នាំ២០២៤

# អារម្ភកថា

ក្នុងរយៈពេល២៥ឆ្នាំចុងក្រោយ បន្ទាប់ពីបានសម្រេចនូវសុខសន្តិភាពពេញលេញ ឯកភាពជាតិ និងឯកភាពទឹកដីទាំងស្រុង តាមរយៈ**នយោបាយឈ្នះ-ឈ្នះ** របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** រាជរដ្ឋាភិបាលកម្ពុជាសម្រេចបាននូវសមិទ្ធផលធំៗលើគ្រប់វិស័យ ទាំងនយោបាយ សង្គម និងសេដ្ឋកិច្ច។ ម្លប់ដ៏ត្រជាក់នៃសន្តិភាព បានបង្កើតស្ថានភាពអំណោយផល ធ្វើឱ្យប្រទេសជាតិ មានកិច្ចអភិវឌ្ឍ និងភាពរីកចម្រើន ដែលអនុញ្ញាតឱ្យរាជរដ្ឋាភិបាល បានពង្រីកការវិនិយោគជាបន្តបន្ទាប់ លើការអភិវឌ្ឍសង្គម និងអនុវត្តកម្មវិធីនយោបាយឆ្លើយតបនឹងយេនឌ័រ និងការពារសិទ្ធិមនុស្ស ក្នុងនោះសិទ្ធិស្ត្រី ឱ្យបានកាន់តែទូលំទូលាយ។ កន្លងមក **យុទ្ធសាស្ត្រចតុកោណ ទាំង៤ដំណាក់កាល** បានចាត់ទុក**ស្ត្រីជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិ** តាមរយៈការលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនការវិនិយោគទៅលើការលើកកម្ពស់សិទ្ធិ ឋានៈ តួនាទី និងស្ថានភាពសេដ្ឋកិច្ច-សង្គមរបស់ស្ត្រី និងក្រុមគ្រួសារ។

រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ស្វាហាប់ និងប្រកបដោយគតិបណ្ឌិតរបស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានបន្តកំណត់**ការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចរបស់ស្ត្រីនៅគ្រប់វិស័យ ជាអាទិភាពក្នុងរបៀបវារៈគោលនយោបាយ** និង**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១** ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព ក្នុងការកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ តាមរយៈការពង្រឹងភាពជាពលរដ្ឋ ក្នុងសង្គមដែលមានអារ្យធម៌ខ្ពស់ ប្រកបដោយសីលធម៌ សមធម៌និងបរិយាបន្ន ដែលក្នុងនោះ **«ស្ត្រី គឺជាស្នូល»**។ រាជរដ្ឋាភិបាល នឹងបន្តលើកកម្ពស់សមភាពយេនឌ័រ តាមរយៈការបង្កើនការវិនិយោគលើយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រីនៅក្នុងវិស័យសេដ្ឋកិច្ច អប់រំ សុខភាព និងការដឹកនាំសាធារណៈ ដើម្បីទាញយកអត្ថប្រយោជន៍ពីភាគលាភយេនឌ័រ បង្កលក្ខណៈអំណោយផលដល់ស្ត្រី ក្នុងការប្រើប្រាស់សិទ្ធិសម្រេចចិត្តលើផែនការគ្រួសារ ការកាត់បន្ថយភាពងាយរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រលើស្ត្រីនិងក្មេងស្រី និងការលើកកម្ពស់ទំនាក់ទំនងអន្តរជំនាន់។

ឈរលើមូលដ្ឋាននេះ ក្រសួងកិច្ចការនារី ដែលជាសេនាធិការរាជរដ្ឋាភិបាលកម្ពុជា ក្នុងការដឹកនាំការសម្របសម្រួល ជំរុញ និងតាមដានការអនុវត្តការបញ្ជ្រាបយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រីនិងក្មេងស្រី បានរៀបចំ**ផែនការយុទ្ធសាស្ត្រនារីរតនៈទី៦ ឆ្នាំ២០២៤-២០២៨** ដោយផ្អែកលើវឌ្ឍនភាពក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈកន្លងមកនិងការវិវត្តថ្មីៗរបស់សង្គម ព្រមទាំងផ្សារភ្ជាប់ជាមួយក្របខណ្ឌ

ច្បាប់ គោលនយោបាយ កម្មវិធីកែទម្រង់ និងគោលនយោបាយតាមវិស័យ ដែលឆ្លើយតបនឹងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល រួមទាំងគោលការណ៍នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ និងរបៀបវារៈសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព «មិនទុកអ្នកណាម្នាក់ឱ្យនៅឯកោ»។

**នារីរតនៈទី៦** ផ្តោតលើការជំរុញការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ និងកម្មវិធីអភិវឌ្ឍន៍នៅគ្រប់វិស័យ និងគ្រប់កម្រិត ដោយប្រើប្រាស់អភិក្រមបរិវត្តកម្មយេនឌ័រ និងមានកម្មវិធីពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច សុខុមាលភាព កិច្ចការពារផ្លូវច្បាប់ អភិបាលកិច្ច ការប្រែប្រួលអាកាសធាតុ និងការលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារ។ កិច្ចការអាទិភាពទាំងនេះ នឹងទ្រទ្រង់ដោយកម្មវិធីពង្រឹងប្រសិទ្ធភាព និងអភិវឌ្ឍន៍សមិទ្ធកម្មស្ថាប័ន ព្រមទាំងការធ្វើទំនើបកម្មផ្នែកឌីជីថល ដែលជាកត្តាចាំបាច់ឆ្ពោះទៅសម្រេចបានការអនុវត្តផែនការយុទ្ធសាស្ត្រនេះ។

ជាមួយគ្នានេះ ក្នុងឆ្នាំ២០២៤ ក្រសួងនឹងត្រូវបញ្ចប់ និងដាក់ជូនរាជរដ្ឋាភិបាល ពិនិត្យ និងអនុម័ត **គោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ ឆ្នាំ២០២៤-២០៣៤** ដែលគោលនយោបាយនេះ ជាឯកសារគោល ក្នុងការធ្វើបរិវត្តកម្មយេនឌ័រនៅតាមវិស័យ ដើម្បីលើកកម្ពស់គណនេយ្យភាពរបស់ក្រសួង-ស្ថាប័ន ការធ្វើស្ថាបនូបនីយកម្មយេនឌ័រ ការពង្រឹងប្រព័ន្ធតាមដាននិងវាយតម្លៃ និងការផ្លាស់ប្តូរផ្នត់គំនិត និងឥរិយាបថរបស់សង្គម ដើម្បីលើកកម្ពស់សមភាពយេនឌ័រ។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ក្រសួង-ស្ថាប័ន ដៃគូពាក់ព័ន្ធ នឹងបន្តចូលរួមកិច្ចសហប្រតិបត្តិការក្នុងស្មារតីគាំទ្រការអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈទី៦ សម្រេចបានដោយជោគជ័យ និងមានប្រសិទ្ធភាព ដើម្បីសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី សម្រាប់ជាឧត្តមប្រយោជន៍ដល់សង្គមជាតិទាំងមូល។

ថ្ងៃសុក្រ ១៣រោចខែ មាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែ មីនា ឆ្នាំ២០២៤

**រដ្ឋមន្ត្រីក្រសួងកិច្ចការនារី**

**កិត្តិបណ្ឌិត អ៊ឹង កន្ថាផាវី**

# មាតិកា


**សេចក្តីផ្តើម**.......................................................................................................១

**ផ្នែកទី ១.** **វឌ្ឍនភាពចម្បងៗ បញ្ហាប្រឈម និងការអនុវត្តភាព**.............................................៣

**ផ្នែកទី ២.** **ទស្សនៈវិស័យ និងបេសកកម្ម**.........................................................................១៩

**ផ្នែកទី ៣.** **គោលបំណង**.........................................................................................២០

**ផ្នែកទី ៤.** **ក្របខណ្ឌយុទ្ធសាស្ត្រ**...............................................................................២១

យុទ្ធសាស្ត្រស្នូលៈ ក្របខណ្ឌបញ្ជ្រាបយេនឌ័រ ..........................................................២២

យុទ្ធសាស្ត្រ ទី១ៈ ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី ...................................២៣

យុទ្ធសាស្ត្រ ទី២ៈ ការលើកកម្ពស់តម្លៃសីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារ.................២៤

យុទ្ធសាស្ត្រ ទី៣ៈ ការលើកកម្ពស់សុខុមាលភាពស្ត្រី និងក្មេងស្រី.................................២៥

យុទ្ធសាស្ត្រ ទី៤ៈ កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រីនិងក្មេងស្រី...................................២៦

យុទ្ធសាស្ត្រ ទី៥ៈ ស្ត្រី ក្នុងភាពជាអ្នកដឹកនាំ និងអភិបាលកិច្ច...................................២៧

យុទ្ធសាស្ត្រ ទី៦ៈ ស្ត្រី និងការប្រែប្រួលអាកាសធាតុ................................................. ២៨

យុទ្ធសាស្ត្រគាំទ្រស្ថាប័នៈ ការពង្រឹងប្រសិទ្ធភាព និងអភិវឌ្ឍន៍សមិទ្ធកម្មស្ថាប័ន.................២៩

**ផ្នែកទី ៥.** **ផែនការសកម្មភាព**.....................................................................................៣១

**ផ្នែកទី ៦.** **យន្តការអនុវត្ត ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ**.........................................៩៩

**សន្ទានុក្រម**.........................................................................................................១១១

# សេចក្ដីផ្ដើម

រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវ**កម្មវិធីនយោបាយ**និង**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១** ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព ដើម្បីកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០។

**កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល** និង **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១** គឺជាក្របខ័ណ្ឌគោលនយោបាយគ្រប់ជ្រុងជ្រោយ សម្រាប់ការរៀបចំ**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០២៤-២០២៨** ផែនការអភិវឌ្ឍនតាមវិស័យ និងផែនការពាក់ព័ន្ធផ្សេងទៀត ដែលមានកំណត់សូចនាករ និងក្របខ័ណ្ឌពេលច្បាស់លាស់។

នៅក្នុងនោះ រាជរដ្ឋាភិបាល បានបន្តកំណត់**ការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចរបស់ស្ត្រីនិងក្មេងស្រីនៅគ្រប់វិស័យ ជាអាទិភាពក្នុងរបៀបវារៈគោលនយោបាយ** និង **យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១** តាមរយៈការពង្រឹងភាពជាពលរដ្ឋ ក្នុងសង្គមដែលមានអារ្យធម៌ខ្ពស់ ប្រកបដោយសីលធម៌ សមធម៌ និងបរិយាបន្ន ដែលក្នុងនោះ «**ស្ត្រី គឺជាស្នូល**»[1]។ រាជរដ្ឋាភិបាលកម្ពុជាបន្តលើកកម្ពស់សមភាពយេនឌ័រ តាមរយៈការបង្កើនការវិនិយោគលើយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រីនៅក្នុងវិស័យ សេដ្ឋកិច្ច អប់រំ សុខភាព និងការដឹកនាំសាធារណៈ ដើម្បីទាញយកអត្ថប្រយោជន៍ពីភាគលាភយេនឌ័រ បង្កលក្ខណៈអំណោយផលដល់ស្ត្រី ក្នុងការប្រើប្រាស់សិទ្ធិសម្រេចចិត្តលើផែនការគ្រួសារ ការកាត់បន្ថយភាពងាយរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រលើស្ត្រីនិងក្មេងស្រី និងការលើកកម្ពស់ទំនាក់ទំនងអន្តរជំនាន់។ ជាមួយគ្នានេះ រាជរដ្ឋាភិបាល នឹងបន្តពង្រឹងនិងពង្រីកវិសាលភាពសេវាសុខភាពបន្តពូជនិងសុខភាពផ្លូវភេទរបស់យុវវ័យ ជាពិសេសស្ត្រីនិងក្មេងស្រី ការបន្តការអនុវត្តកម្មវិធីគាំពារសង្គមដល់ស្ត្រីមានផ្ទៃពោះ និងកុមារនៃគ្រួសារក្រីក្រ និងការបន្តលើកកម្ពស់អាហារូបត្ថម្ភដល់ស្ត្រីមានផ្ទៃពោះ និងកុមារ។

ការតាក់តែងផែនការយុទ្ធសាស្ត្រនារីរតនៈទី ៦ ផ្អែកលើសមិទ្ធផល រួមទាំងមេរៀនបទពិសោធន៍ពីការអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈកន្លងមក និងឆ្លើយតបទៅនឹងការវិវត្តថ្មីៗរបស់សង្គម ព្រមទាំងស្របតាមក្របខ័ណ្ឌគោលនយោបាយជាតិ និងការប្ដេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ដូចមានកំណត់ក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅកម្ពុជា អនុសញ្ញាស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ សេចក្ដីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខ អង្គការសហប្រជាជាតិស្ដីពីស្ត្រី

[1] ស្រង់ពីសុន្ទរកថារបស់**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ថ្លែងក្នុងពិធីបើកមហាសន្និបាតមិត្តកាយឫទ្ធិនារីតំបន់អាស៊ីប៉ាស៊ីហ្វិក កាលពីថ្ងៃទី៥ ខែ វិច្ឆិកា ឆ្នាំ២០២៣ ខេត្តសៀមរាប

សន្តិភាពនិងសន្តិសុខ សេចក្តីប្រកាសនិងផែនការសកម្មភាពទីក្រុងប៉េកាំង និងការប្តេជ្ញាចិត្តនៅសន្និសីទអន្តរជាតិស្តីពីប្រជាជននិងការអភិវឌ្ឍ (ICPD+25) នៅទីក្រុងណៃរ៉ូប៊ី ជាដើម។

ផែនការយុទ្ធសាស្ត្រនេះ បានពិគ្រោះយោបល់ ជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូជាតិ និងអន្តរជាតិ វិស័យឯកជន សង្គមស៊ីវិល និងតំណាងនៅថ្នាក់ក្រោមជាតិ ចំនួន២លើក និងបានយកទៅពិគ្រោះយោបល់ នៅក្នុងសន្និបាតបូកសរុបការងាររបស់ក្រសួងកិច្ចការនារី ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី១០-១១ ខែមករា ឆ្នាំ២០២៤ តាមរយៈការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រី ក្រសួង និងមន្ទីរកិច្ចការនារីរាជធានី ខេត្ត ដៃគូជាតិ មកពីក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្រុមប្រឹក្សា-អភិបាលរងរាជធានី ខេត្ត ដៃគូអភិវឌ្ឍន៍អន្តរជាតិ វិស័យឯកជន និងសង្គមស៊ីវិល សរុបចំនួន ៥១០រូប (ស្ត្រី៣៥៧ រូប)។

នារីរតនៈទី ៦ គឺជាយុទ្ធសាស្ត្រគន្លឹះ និងជាកញ្ចប់វិធានការអាទិភាពរយៈពេល ៥ឆ្នាំ របស់ក្រសួងកិច្ចការនារី ដែលមានចំនួន៤១វិធានការគន្លឹះ ក្នុងការជំរុញនិងលើកកម្ពស់សមភាពយេនឌ័រ នៅក្នុងរបៀបវារៈនិងកម្មវិធីនយោបាយនៅគ្រប់កម្រិតនិងគ្រប់វិស័យ។ កិច្ចការអាទិភាពទាំងនេះ សំដៅលើកកម្ពស់សមភាពយេនឌ័រ និងដើម្បីទាញយកអត្ថប្រយោជន៍ពីភាគលាភយេនឌ័រ ចូលរួមក្នុងការពន្លឿនកំណើនសេដ្ឋកិច្ច ការលើកកម្ពស់សុខុមាលភាពនិងភាពធន់របស់សង្គម និងការពង្រឹងអភិបាលកិច្ចល្អប្រកបដោយបរិយាបន្ន និងចីរភាព។

នៅក្នុងឆ្នាំ២០២៤នេះ ក្រសួងកិច្ចការនារី នឹងបញ្ចប់ និងដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងអនុម័ត **គោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ** ដែលគោលនយោបាយនេះ ជាឯកសារគោល ក្នុងការធ្វើបរិវត្តកម្មយេនឌ័រនៅតាមវិស័យ ដើម្បីលើកកម្ពស់គណនេយ្យភាពរបស់ក្រសួង-ស្ថាប័ន ការរៀបចំអភិក្រមធ្វើស្ថាប័ននីយកម្មយេនឌ័រតាមក្រសួង-ស្ថាប័ន រួមទាំងកម្មវិធីថវិកាឆ្លើយតបនឹងយេនឌ័រ ការពង្រឹងប្រព័ន្ធតាមដាននិងវាយតម្លៃយេនឌ័រនៅតាមវិស័យ និងការកែប្រែផ្នត់គំនិតនិងឥរិយាបថរបស់សង្គមជាសាធារណៈ។

ផ្អែកលើយុទ្ធសាស្ត្របញ្ចកោណ និងចក្ខុវិស័យក្នុងគោលនយោបាយជាតិ ព្រមទាំងកញ្ចប់អាទិភាពនៅក្នុងនារីរតនៈទី៦ ក្រសួងក៏នឹងពិនិត្យ និងកែសម្រួលបេសកកម្មរបស់ខ្លួន រួមទាំងការរៀបចំរចនាសម្ព័ន្ធធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ ឱ្យស្របនិងឆ្លើយតបនឹងការវិវត្តរបស់សង្គម។

# ផ្នែកទី ១

## វឌ្ឍនភាពចម្បងៗ បញ្ហាប្រឈម និងកាលានុវត្តភាព

ការអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ ២០១៩-២០២៣ បានចូលរួមបញ្ជ្រាបយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី នៅក្នុងដំណើរការតាក់តែង អនុវត្ត និងតាមដានការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងកម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាល ព្រមទាំងវិស័យអាទិភាពសំខាន់ៗនានា។

របាយការណ៍អភិវឌ្ឍន៍ធនធានមនុស្សក្នុងតំបន់ ឆ្នាំ២០២៤ របស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) បានបញ្ជាក់ថា កម្ពុជាមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ក្នុងការលើកកម្ពស់សមភាពយេនឌ័រ ដោយផ្អែកលើភាគរយស្ត្រីនៅក្នុងរដ្ឋសភា ការអប់រំ កម្លាំងពលកម្ម ក៏ដូចជាអត្រាមរណភាពមាតា - ដោយគម្លាតយេនឌ័រ បានធ្លាក់ចុះ ពី ០.៦៧៩ ក្នុងឆ្នាំ១៩៩០ មកត្រឹម ០.៤៦១ នៅឆ្នាំ២០២៣។ ការណ៍នេះ ធ្វើឱ្យកម្ពុជា ស្ថិត ក្នុងចំណាត់ថ្នាក់ ១១៦ ក្នុងចំណោម១៧០ប្រទេសសម្រាប់សន្ទស្សន៍វិសមភាពយេនឌ័រ ឆ្នាំ ២០២៣។

វឌ្ឍនភាព និងលទ្ធផលគន្លឹះៗ ដែលសម្រេចបាន មានដូចខាងក្រោម៖

### ១. ក្របខណ្ឌបញ្ជ្រាបយេនឌ័រ

១.១. គោលនយោបាយជាតិ និងយុទ្ធសាស្ត្រតាមវិស័យ បានដាក់ចេញ និងអនុវត្តដែលឆ្លើយតបនឹងយេនឌ័រ និងការពារសិទ្ធិស្ត្រីនៅកម្ពុជា រួមមាន ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលនយោបាយជាតិប្រជាជន កម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ផែនការអភិវឌ្ឍន៍ស្ថិតិ ក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ក្របខណ្ឌគោលនយោបាយជាតិស្តីពីសេដ្ឋកិច្ចនិងសង្គមឌីជីថល គោលនយោបាយរដ្ឋាភិបាលឌីជីថល ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ផែនការយុទ្ធសាស្ត្រក្នុងការបង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់-ក្រោមជាតិ គោលនយោបាយស្តីពីការលើកកម្ពស់សមភាពយេនឌ័រសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិប-តេយ្យនៅថ្នាក់ក្រោមជាតិ ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព រួមទាំងកម្មវិធីជាតិ និងលិខិតបទដ្ឋានគតិយុត្តលើការងារកែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីកែទម្រង់ច្បាប់និងប្រព័ន្ធតុលាការ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីវិមជ្ឈការនិងវិសហមជ្ឈការ និងប្រព័ន្ធគ្រប់គ្រងទិន្នន័យមូលនិធិអភិវឌ្ឍផ្លូវការនៅកម្ពុជាជាដើម។

១.២. សេចក្តីព្រាងគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ ត្រូវបានតាក់តែង និងមានការពិគ្រោះយោបល់ជាមួយតំណាងក្រសួង-ស្ថាប័ន និងដៃគូពាក់ព័ន្ធ។

១.៣. យន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមមាន ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ក្រសួង-កិច្ចការនារី គណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រីនិងគ្រួសារខ្មែរ ក្រុមការងារបច្ចេកទេសយេនឌ័រ ក្រុមការងារបញ្ជ្រាបយេនឌ័រក្រសួង-ស្ថាប័ន ក្រុមការងារទទួលបន្ទុកការងារទប់ស្កាត់អំពើហិង្សា

ទាក់ទងនឹងយេនឌ័រ មន្ទីរកិច្ចការនារីរាជធានី-ខេត្ត គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមាររាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ-សង្កាត់ បានដំណើរការយ៉ាងសកម្ម ក្នុងការជំរុញការឆ្លើយតបយេនឌ័រ សិទ្ធិស្ត្រី និងការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រនៅគ្រប់កម្រិត ។

១.៤. ក្រសួង-ស្ថាប័ន ចំនួន១៧ បានធ្វើបច្ចុប្បន្នភាពក្រុមការងារបញ្ជ្រាបយេនឌ័រ ក្រសួង-ស្ថាប័ន ចំនួន ១៩ បានធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ និងក្រសួង-ស្ថាប័ន ចំនួន ១១ បានអនុវត្តកម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្តីពីការបញ្ជ្រាបយេនឌ័រតាមវិស័យ។

១.៥. ផ្តួចផ្តើមរៀបចំការសិក្សាស្រាវជ្រាវ និងចងក្រងមេរៀនបទពិសោធន៍លើការអនុវត្តវិធានការផ្នែកគោលនយោបាយឆ្លើយតបការងារថែទាំគ្មានប្រាក់កម្រៃ និងសេដ្ឋកិច្ចដែលគិតគូរពីសុខុមាលភាព (Care Economy) ព្រមទាំងបានពិគ្រោះយោបល់និងអភិវឌ្ឍន៍សមត្ថភាពជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធដើម្បីឈានទៅរៀបចំក្របខណ្ឌផែនការសកម្មភាពឆ្លើយតបតាមវិស័យ ព្រមទាំងរៀបចំសម្ភារៈនិងកម្មវិធីយុទ្ធនាការផ្សព្វផ្សាយជាសាធារណៈ។

១.៦. ឯកសារផែនទីបង្ហាញផ្លូវ ឯកសារសម្រាប់បណ្តុះបណ្តាល និងបានអភិវឌ្ឍន៍សមត្ថភាពសាកល្បងស្តីពីការរៀបចំផែនការនិងថវិកាឆ្លើយតបយេនឌ័រ ដល់មន្ត្រីជំនាញតាមក្រសួង-ស្ថាប័ន ចំនួន ៣៥រូប។ គ្រូបង្គោលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិស្តីពីថវិកាឆ្លើយតបនឹងយេនឌ័រនៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ-សង្កាត់ ចំនួន៤៥រូប បានអភិវឌ្ឍន៍សមត្ថភាព។ ក្រសួងបានអភិវឌ្ឍសមត្ថភាពគ្រូបង្គោលមន្ទីរកិច្ចការនារីរាជធានី-ខេត្ត លើជំនាញស្តីពីការលើកកម្ពស់យេនឌ័រ បរិយាបន្ន និងសមធម៌សង្គម ការស្វែងរកការគាំទ្រមតិ និងភាពជាអ្នកដឹកនាំ ព្រមទាំងការផ្តល់សេវាឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ សរុបចំនួន ៦៨០រូប។

**បញ្ហាប្រឈម និងកាលានុវត្តភាព៖**

- ការប្តេជ្ញាចិត្តនិងឯកទេសក្នុងការបញ្ចូលយេនឌ័រ និងការអនុវត្តគោលនយោបាយ គោលការណ៍ណែនាំ និងនីតិវិធីនានាដែលឆ្លើយតបនឹងយេនឌ័រ នៅតាមក្រសួង-ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធ នៅមានកម្រិត។
- តម្រូវការពន្លឿនការផ្លាស់ប្តូរ ឬធ្វើបរិវត្តកម្មឥរិយាបថនិងផ្នត់គំនិតរបស់សង្គម ក្នុងការគាំទ្រលើការលើកកម្ពស់សមភាពយេនឌ័រ ជាពិសេសការគាំទ្រពីក្រុមគ្រួសារ ក្នុងការចែករំលែកការទទួលខុសត្រូវលើបន្ទុកការងារផ្ទះ និងការងារមើលថែទាំសមាជិកគ្រួសារនិងកូនៗ។
- តម្រូវការក្នុងការគិតគូរដល់ការរៀបចំប្រព័ន្ធវិភាគឱ្យស៊ីជម្រៅលើបញ្ហាយេនឌ័រតាមវិស័យ ដើម្បីឈានទៅចាត់វិធានការក្នុងការឆ្លើយតប និងបង្កើនវិនិយោគលើសមភាពយេនឌ័រ នៅតាមវិស័យ និងការរៀបចំប្រព័ន្ធតាមដាន និងវាយតម្លៃ។

- ក្រុមការងារបញ្ជ្រាបយេនឌ័រនៅតាមវិស័យ និងនៅតាមក្រសួង-ស្ថាប័ន មានការផ្លាស់ប្តូរ នៅក្នុងរាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ដែលតម្រូវឱ្យមានការពិនិត្យមើលឡើងវិញនូវការរៀបចំ និងអនុវត្តការងារឱ្យឆ្លើយតបនឹងការវិវត្តថ្មីៗតាមវិស័យនិងសង្គម ជាពិសេសលើសមត្ថភាព និងវិធីសាស្ត្រការវិភាគយេនឌ័រ និងបញ្ជ្រាបយេនឌ័រ ក្នុងវិស័យខ្លួន។
- ការរៀបចំយុទ្ធនាការផ្សព្វផ្សាយជាសាធារណៈតាមបណ្តាញសង្គម និងប្រព័ន្ធឌីជីថល ដើម្បីលើកកម្ពស់សមភាពយេនឌ័រ នៅមានកម្រិត និងមិនទាន់មានភាពទាក់ទាញ។

## ២. ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី

២.១. អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចនៅកម្ពុជា ឆ្នាំ២០២១ បានបង្ហាញថា អត្រាចូលរួមកម្លាំងពលកម្មរបស់ស្ត្រី អាយុពី១៥-៦៤ ឆ្នាំ មាន៧៩%។ របាយការណ៍ជំរឿនសេដ្ឋកិច្ច ឆ្នាំ២០២២ បានបង្ហាញថា ស្ត្រី មានចំនួន ៦៩% ជាតំណាងអង្គភាពសេដ្ឋកិច្ចសរុប នៅកម្ពុជា។

២.២. មជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនភាពស្ត្រី ក្នុងភាពជាដៃគូជាមួយវិស័យឯកជន បានផ្តល់សេវាគាំទ្រការអភិវឌ្ឍអាជីវកម្ម ការបង្កើតនិងពង្រីកឱកាសទីផ្សារ លើកកម្ពស់ចំណេះដឹងផ្នែកឌីជីថលនិងហិរញ្ញវត្ថុ ជូនស្ត្រីជាសហគ្រិន កម្រិតមីក្រូ និងតូច (ចំនួន៦៧៨រូប)។ ទន្ទឹមនឹងនោះ បានគាំទ្របច្ចេកទេសដល់ការបង្កើត និងដំណើរការបណ្តាញសហគ្រិនស្ត្រីកម្ពុជា ដែលជាតំណាងស្ត្រីសហគ្រិន នៅលើឆាកអាស៊ាន ហើយកន្លងមក សហគ្រិនស្ត្រីកម្ពុជា ចំនួន៥៩រូប ទទួលបានពានរង្វាន់សហគ្រិនស្ត្រីឆ្នើមអាស៊ាន។

២.៣. មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីនៅតាមខេត្ត និងមន្ទីរកិច្ចការនារីរាជធានី-ខេត្ត បានធ្វើពិពិធកម្មមុខងារ និងបានបណ្តុះបណ្តាលដល់ស្ត្រី ចំនួន ១៨,៧០០នាក់ (ក្នុងនោះមានស្ត្រីមេម៉ាយ ស្ត្រីក្រីក្រ ទណ្ឌិតស្ត្រីបោះបង់ចោលការសិក្សា និងជនជាតិដើមភាគតិចជាដើម។) លើជំនាញវិជ្ជាជីវៈដូនតា ជំនាញផ្តួចផ្តើមនិងអភិវឌ្ឍន៍អាជីវកម្ម សហគ្រិនភាព ចំណេះដឹងឌីជីថលនិងការអភិវឌ្ឍមុខរបរ។ ជាមួយគ្នានេះ ក្រុមផលិតសិប្បកម្ម និងក្រុមសន្សំប្រាក់នៅតាមសហគមន៍ ដែលមានសមាជិកសរុបចំនួន ១២៥នាក់ បានចងក្រងនិងដំណើរការ។

២.៤. ក្រសួងកិច្ចការនារី បានចូលរួមគាំទ្រនិងពង្រីកបរិយាកាសអំណោយផល ក្នុងការលើកកម្ពស់សហគ្រិនភាពស្ត្រីជាបន្តបន្ទាប់ តាមរយៈការរៀបចំព្រឹត្តិការណ៍សាធារណៈនិងវេទិកាពិគ្រោះយោបល់រវាងវិស័យសាធារណៈ តំណាងសហជីព និងដៃគូពាក់ព័ន្ធ និងបានបង្កឱកាសក្នុងការពិភាក្សាអំពីបញ្ហាប្រឈមនិងតម្រូវការ ព្រមទាំងបានបង្កើនការយល់ដឹងលើវិធានការគោលនយោបាយដែលគាំទ្រស្ត្រីដែលធ្វើការនៅក្នុងសេដ្ឋកិច្ចក្នុងនិងក្រៅប្រព័ន្ធ។ របាយការណ៍ធនាគារពិភពលោកស្តីពីធុរកិច្ចនិងច្បាប់ ឆ្នាំ២០២២ បានបង្ហាញថា កម្ពុជាមានចំណាត់ថ្នាក់ខ្ពស់បំផុត ក្នុងចំណោមបណ្តាប្រទេសក្នុងពិភពលោក ដែលមានសេរីភាពសម្រាប់ស្ត្រី ក្នុងការចាប់ផ្តើមអាជីវកម្មនិងធុរកិច្ច។

២.៥. ភាពជាដៃគូរវាងក្រសួងកិច្ចការនារី និងធនាគារជាតិនៃកម្ពុជា គាំទ្រពីក្រុមហ៊ុនវីសា បានលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី ពីឆ្នាំ២០២០-២០២២ តាមរយៈកម្មវិធីបណ្តុះបណ្តាលចំណេះដឹង និងសមត្ថភាពគ្រប់គ្រង និងប្រើប្រាស់សេវាហិរញ្ញវត្ថុបែបឌីជីថល ដើម្បីអភិវឌ្ឍអាជីវកម្មដល់ស្ត្រី ចំនួន ១,៤៣១នាក់ នៅក្នុងខេត្តគោលដៅចំនួន៤។

២.៦. គម្រោងបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ក្នុងខេត្តចំនួន៥ បានអនុវត្តដោយផ្តល់ជំនាញនិងបច្ចេកទេសចិញ្ចឹមមាន់ ដាំបន្លែ សិប្បកម្ម សេវាកម្មទេសចរណ៍ និងសេវាកម្មផ្សេងៗ ក្នុងការលើកកម្ពស់សេដ្ឋកិច្ចគ្រួសាររបស់ស្ត្រី ចំនួន ៤៧៣នាក់(ស្រី ២៥៤នាក់)។

២.៧. ក្រសួងបានដឹកនាំអនុវត្តគម្រោងថ្នាក់តំបន់មេគង្គ-ឡានឆាងស្តីពីការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីនៅក្នុងយុគសម័យឌីជីថល ឆ្នាំ២០២២-២០២៣ ជាមួយប្រទេសវៀតណាម និងថៃឡង់ ដោយបានសិក្សាស្រាវជ្រាវ និងអនុវត្តគំនិតផ្តួចផ្តើមនានា ក្នុងការពង្រឹងសក្តានុពលផ្នែកសេដ្ឋកិច្ចរបស់ស្ត្រីនៅក្នុងយុគសម័យឌីជីថល នៅក្នុងប្រទេសទាំងបី (កម្ពុជា វៀតណាម និងថៃ)។

**បញ្ហាប្រឈម និងកាលានុវត្តភាព៖**

- នៅក្នុងចំណោម ៦៩% ដែលស្ត្រីជាអ្នកតំណាងអង្គភាពសេដ្ឋកិច្ចសរុបនៅកម្ពុជា ភាគច្រើនពួកគាត់ជាតំណាងនៅអង្គភាពសេដ្ឋកិច្ចដែលមានអ្នកចូលរួមការងារ ពី១ ទៅ១០នាក់ (៦៨%) និងមិនទាន់បានក្នុងការចុះបញ្ជី ឬនៅក្រៅប្រព័ន្ធ។

- ក្រោយពីវិបត្តិកូវីដ-១៩ មាននិន្នាការថ្មី ក្នុងការរៀបចំសេដ្ឋកិច្ចដែលគិតគូរពីសុខុមាលភាព (Care Economy) នៅក្នុងបណ្តាប្រទេសនានា ដែលនេះជាមធ្យោបាយ ក្នុងការកាត់បន្ថយភាពងាយរងគ្រោះរបស់ស្ត្រី នៅក្នុងសកម្មភាពសេដ្ឋកិច្ចផង និងជាកាលានុវត្តភាពថ្មីផង ក្នុងការបង្កើតការងារថ្មីដែលអាចជួយជំរុញកំណើនសេដ្ឋកិច្ច និងកិច្ចអភិវឌ្ឍសង្គមប្រកបដោយចីរភាព។

- គម្លាតយេនឌ័រនៅក្នុងការចាប់យកជំនាញនិងការងារនៅតែបន្តកើតមាន ជាពិសេសចំនួនស្ត្រីនៅក្នុងប្រភេទការងារនិងមុខរបរដែលពាក់ព័ន្ធនឹងវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងឌីជីថល រួមទាំងសេដ្ឋកិច្ចបៃតង។

- នៅពេលដែលការវិវត្តសង្គមកាន់តែលឿន ស្ត្រីនិងក្មេងស្រីនៅតាមជនបទ ត្រូវការការបង្កើនការទទួលបានចំណេះដឹង និងលទ្ធភាពផ្នែកឌីជីថលនិងហិរញ្ញវត្ថុ រួមទាំងការអភិវឌ្ឍសហគ្រិនភាពសម្រាប់ស្ត្រី និងក្មេងស្រី។

- នៅក្នុងបរិបទសេដ្ឋកិច្ចឌីជីថល ត្រូវការឱ្យបង្កើនកម្មវិធីឌីជីថលសម្រាប់សហគ្រិនជាស្ត្រីបន្ថែមទៀត និងការពិនិត្យមើលឡើងវិញនូវកម្មវិធីបណ្តុះបណ្តាលជំនាញថ្មី (Re-skilling) និងបង្កើនជំនាញ (Upskilling) សម្រាប់ស្ត្រី ក្នុងវិស័យឌីជីថល។

## ៣. ការលើកកម្ពស់សីលធម៌សង្គម និងការអប់រំរបស់ស្ត្រី និងក្មេងស្រី

៣.១. គណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ បានយកចិត្តទុកដាក់ចំពោះការលើកកម្ពស់សីលធម៌សង្គម និងបានផ្ដល់បទអន្តរាគមន៍ រួមចំណែកលើកកម្ពស់ការគោរពសិទ្ធិមនុស្ស សិទ្ធិស្ត្រី កុមារ សិទ្ធិជនដែលមានពិការភាព និងក្រុមងាយរងគ្រោះដទៃទៀតក្នុងសង្គម និងបានរៀបចំនីតិវិធីប្រតិបត្តិស្តង់ដារ (SOP) ស្តីពីការឆ្លើយតបរបស់ក្រសួង-ស្ថាប័ន ក្នុងការលើកកម្ពស់សីលធម៌សង្គមតាមប្រព័ន្ធអនឡាញ ដើម្បីចូលរួមកាត់បន្ថយហានិភ័យ និងផលប៉ះពាល់ជាអវិជ្ជមាននានា មកលើសីលធម៌សង្គមដែលបានកើតឡើងពីបណ្ដាញសង្គម និងបច្ចេកវិទ្យា ដែលជាសកម្មភាពមិនសមរម្យប្រាសចាកសីលធម៌ដែលតម្រូវឱ្យមាននអន្តរាគមន៍ជាចាំបាច់ និងភ្លាមៗពីសំណាក់ស្ថាប័នពាក់ព័ន្ធ។

៣.២. ផែនការយុទ្ធសាស្ត្រជាតិវិស័យអប់រំបានឆ្លើយតបយេនឌ័រ និងគម្លាតយេនឌ័រនៅក្នុងវិស័យអប់រំត្រូវបានកាត់បន្ថយគួរឱ្យកត់សម្គាល់ ជាពិសេសនៅកម្រិតបឋមសិក្សា មធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ។ ឆ្នាំសិក្សា២០២២-២០២៣ សិស្សស្រី ដែលប្រឡងជាប់មធ្យមសិក្សាទុតិយភូមិ មាន ៥៧,៣៧% ធៀបនឹងសិស្សប្រឡងជាប់សរុប (ក្នុងនោះ សិស្សស្រីដែលទទួលបាននិទ្ទេស A មាន ៥៦,៦០%) និងនិស្សិតស្រី នៅឧត្តមសិក្សាមានការកើនឡើងដល់ ៤៩,៧%។

៣.៣. ស្ត្រីកម្ពុជា បាន និងកំពុងចូលរួមយ៉ាងសកម្ម ក្នុងវិស័យកីឡាគ្រប់ប្រភេទ និងបានចូលរួមក្នុងឆាកអន្តរជាតិ ព្រមទាំងទទួលបាននូវមេដាយជូនជាតិ និងមាតុភូមិជាបន្តបន្ទាប់។

៣.៤. ក្រសួងកិច្ចការនារី បានដឹកនាំនិងសម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងការអភិវឌ្ឍនិងអនុវត្តផែនការសកម្មភាព ស្តីពីការបង្ការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារនៅកម្ពុជា ឆ្នាំ ២០១៧-២០២១។

៣.៥. យុទ្ធសាស្ត្រ និងកញ្ចប់ឧបករណ៍ស្តីពីការចិញ្ចឹមកូនបែបវិជ្ជមាន បានអនុវត្តនៅខេត្តទាំង១២ (ភ្នំពេញ កណ្ដាល ព្រះសីហនុ សៀមរាប បាត់ដំបង រតនគិរី ក្រចេះ ព្រៃវែង កំពត កោះកុង កំពង់ឆ្នាំង ត្បូងឃ្មុំ) ដើម្បីកែប្រែផ្នត់គំនិតនិងផ្លាស់ប្ដូរឥរិយាបថអំពីការចិញ្ចឹមកូនតាមបែបវិជ្ជមាននិងវប្បធម៌អហិង្សា និងចូលរួមលើកកម្ពស់សីលធម៌សង្គម និងបានអភិវឌ្ឍសមត្ថភាពមាតាបិតា អាណាព្យាបាល និងអ្នកថែទាំ ចំនួន ២០.៥៤៩នាក់ (ស្រី១៧.៣៦៧នាក់)។

៣.៦. តាមរយៈមេរៀននិងបទពិសោធន៍ ក្នុងការបង្កើតនិងដំណើរការទារកដ្ឋានសម្រាប់គាំទ្រដល់មន្ត្រីរាជការក្រសួងកិច្ចការនារី សេចក្ដីណែនាំស្តីពីដំណើរការថ្នាក់ទារកដ្ឋាន បានរៀបចំ និងសម្រាប់ការចែករំលែកនិងលើកទឹកចិត្តដល់ការបង្កើតនៅតាមក្រសួង-ស្ថាប័នសាធារណៈនានា។

**បញ្ហាប្រឈម និងកាលានុវត្តភាព៖**

- ផ្នត់គំនិតរបស់គ្រួសារនិងសង្គម ក្នុងការលើកទឹកចិត្តដល់ស្ត្រីនិងក្មេងស្រី ដើម្បីទទួលបានជំនាញនិងឱកាសការងារស្របតាមតម្រូវការទីផ្សារសេដ្ឋកិច្ចនិងសង្គមឌីជីថល នៅមិនទាន់បានទូលំទូលាយនៅ

ឡើយ ដែលធ្វើឱ្យមានគម្លាតយេនឌ័រ ដូច្នេះគួរគិតគូរពីការបន្តលើកកម្ពស់ការអប់រំរបស់ក្មេងស្រីនិងកុមារីឱ្យទទួលបានការអប់រំនៅកម្រិតខ្ពស់ និងការអប់រំផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈច្នៃប្រឌិត និងគណិតវិទ្យា (STEAM) ស្របតាមការវិវត្តរបស់សង្គម។

- ក្នុងអំឡុងប៉ុន្មានឆ្នាំចុងក្រោយនេះ អត្រាពិតនៃការសិក្សានៅថ្នាក់បឋមសិក្សារបស់សិស្សស្រី នៅបឋមសិក្សាមានការកើនឡើងខ្ពស់ជាង សិស្សប្រុស ។ ឆ្នាំសិក្សា២០២២-២០២៣ អត្រាបញ្ចប់នៃការសិក្សានៅបឋមសិក្សារបស់សិស្សស្រី មានដល់ ៩៤,៣% ខណៈសិស្សប្រុសសម្រេចបានត្រឹមតែ ៨៩,២%។
- ទោះបីយុទ្ធសាស្ត្រស្តីពីការចិញ្ចឹមកូនបែបវិជ្ជមាន បានដាក់ឱ្យអនុវត្តយ៉ាងណាក៏ដោយ ក៏ការដាក់បញ្ចូលយុទ្ធសាស្ត្រនេះ ទៅក្នុងផែនការថ្នាក់ក្រោមជាតិមិនទាន់បានទូលំទូលាយនៅឡើយ ដែលនេះជាកិច្ចការអាទិភាពដែលត្រូវការការយកចិត្តទុកដាក់បន្ថែម។
- ការអនុវត្តកម្មវិធីទារកដ្ឋាន និងការបំបៅដោះកូនដោយទឹកដោះម្តាយ នៅកន្លែងធ្វើការ តាមគ្រឹះស្ថានសាធារណៈ និងឯកជន កម្មវិធីចិញ្ចឹមកូនបែបវិជ្ជមាន និងកម្មវិធីអប់រំមាតាបិតានៅមានកម្រិត ដូច្នេះត្រូវតែពង្រឹង និងពង្រីកកម្មវិធីនេះឱ្យបានទូលំទូលាយ។

## ៤. លើកកម្ពស់សុខភាពស្ត្រី និងក្មេងស្រី

៤.១. អត្រាមរណភាពមាតាបានថយចុះ ពី១៧០នាក់ ក្នុងឆ្នាំ២០១៤ មកនៅ ១៥៤នាក់ ក្នុងចំណោម ១០០.០០០កំណើតរស់ ឆ្នាំ២០២២។ មរណភាពកុមារអាយុក្រោម ៥ឆ្នាំ ថយចុះពី ៣៥នាក់ ឆ្នាំ២០១៤ មកត្រឹម១៦នាក់ ឆ្នាំ២០២២ ក្នុងចំណោម១.០០០កំណើតរស់ និងមរណភាពទារកថយចុះពី២៨នាក់ ឆ្នាំ២០១៤ មកត្រឹម១២នាក់ឆ្នាំ២០២២ ក្នុងចំណោម១.០០០កំណើតរស់ ។

៤.២. ក្រសួងនិងមន្ទីរកិច្ចការនារី បានចូលរួមបង្កើនការយល់ដឹងដល់មន្ត្រីថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម គណកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់ ភូមិ និងប្រជាពលរដ្ឋ អំពីសុខភាពបន្តពូជ សុខភាពផ្លូវភេទ សុខភាពភ្នែក យេនឌ័រ និងជំងឺមហារីកមាត់ស្បូន មហារីកសុដន់ អាហារូត្ថម្ភ និងចំណេះដឹងហិរញ្ញវត្ថុ ការថែទាំអនាម័យខ្លួនប្រាណពេលពេញវ័យ។ អ្នកទទួលផលសរុបពីកម្មវិធីនេះ មានចំនួន ១២.៣៧៥ នាក់ (ស្ត្រី ៦.៩៧៣នាក់) ពីកម្មវិធីយេនឌ័រ និងសុខភាពភ្នែក ចំនួន ១០.២៩៨នាក់ (ស្ត្រី ៨.១៨៥នាក់) ពីកម្មវិធីយេនឌ័រ និងជំងឺមហារីកមាត់ស្បូន មហារីកសុដន់ អាហារូត្ថម្ភ និងចំណេះដឹងហិរញ្ញវត្ថុ និង ចំនួន ២៤១១នាក់ (ស្ត្រី១.៧៣៩នាក់) ពីកម្មវិធីយេនឌ័រសុខភាពបន្តពូជ អាហារូបត្ថម្ភ ជំងឺឆ្លង ជំងឺមិនឆ្លង ការថែទាំអនាម័យខ្លួនប្រាណពេលពេញវ័យ។

៤.៣. បានផលិតស្ពត់វីដេអូ និងសារអប់រំខ្លីៗចំនួន ១៥ ស្តីពីយេនឌ័រនិងសុខភាព (ជំងឺមហារីកមាត់ស្បូន មហារីកសុដន់ អាហារូបត្ថម្ភ សុខភាពភ្នែក ជាដើម) និងសម្ភារៈអប់រំចំនួន ៥០.០០០ សន្លឹកចែកចាយជូនប្រជាជននៅសហគមន៍ និងផលិត និងផ្សព្វផ្សាយល្ខោននិយាយសម្រាប់ផ្សព្វផ្សាយក្នុងវិទ្យុ បានចំនួន៦រឿង (ទី១.យុវវ័យនិងសិទ្ធិក្នុងការទទួលបានសុខភាពផ្លូវភេទ សុខភាពបន្តពូជ ២.ឱកាសមាស១.០០០ថ្ងៃ

ដំបូងនៃជីវិត ទី៣.របៀបផ្តល់អាហារបន្ថែមដល់ទារកអាយុ៦ខែឡើង ទី៤.សុខភាពផ្លូវចិត្ត មេរោគអេដស៍ ការប្រើប្រាស់គ្រឿងញៀន និងគ្រឿងស្រវឹង ទី៥.ការបង្ការជំងឺមហារីកមាត់ស្បូន និងទី៦.ការស្ទាបពិនិត្យសុដន់ដោយខ្លួនឯងដើម្បីបង្ការមហារីកសុដន់)។

៤.៤. តាមរយៈការអនុវត្តវិធានការនិងកម្មវិធី ក្រោមក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ស្ត្រីបានទទួលអត្ថប្រយោជន៍ជាបន្តបន្ទាប់ ជាពិសេសសម្រាប់ស្ត្រីដែលមានផ្ទៃពោះ។

**បញ្ហាប្រឈម និងកាលានុវត្តភាពៈ**

- ស្ត្រីនិងក្មេងស្រីទទួលបានព័ត៌មាន ចំណេះដឹង និងការអនុវត្តបានពេញលេញនូវសិទ្ធិ ស្តីពីសុខភាពបន្តពូជ និងសុខភាពផ្លូវភេទនៅមានកម្រិត ដែលតម្រូវឱ្យមានការពង្រឹង និងពង្រីកវិធានការបន្ថែមឱ្យបានទូលំទូលាយ ជាពិសេសនៅក្នុងចំណោមក្រុមស្ត្រី និងក្មេងស្រីដែលងាយរងគ្រោះ។
- ការយល់ដឹងអំពីសារៈសំខាន់នៃការថែទាំសុខភាព អនាម័យ សន្តិសុខស្បៀង និងអាហារូបត្ថម្ភរបស់ស្ត្រីនិងក្មេងស្រី នៅមានកម្រិត ដូច្នេះត្រូវការយកចិត្តទុកដាក់បន្ថែមទៀត ជាពិសេសនៅតំបន់ដាច់ស្រយាល។
- តម្រូវការក្នុងការស្វែងរកនិងពង្រីកបន្ថែមទៀតនូវវិធានការទប់ស្កាត់ និងដោះស្រាយបញ្ហាពាក់ព័ន្ធនឹងជំងឺឆ្លង និងជំងឺមិនឆ្លង ជាពិសេសជំងឺមហារីកមាត់ស្បូន និងមហារីកសុដន់។

## ៥. កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រី និងក្មេងស្រី

៥.១. ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៩-២០២៣ បានអនុវត្តដោយជោគជ័យ និងដោយមានការចូលរួមពីក្រសួង-ស្ថាប័ន និងដៃគូពាក់ព័ន្ធ។ ផ្អែកលើលទ្ធផលអង្កេតប្រជាសាស្ត្រ និងសុខភាព បានបង្ហាញថាអត្រាប្រេវ៉ាឡង់នៃអំពើហិង្សាលើស្ត្រីពីសំណាក់ដៃគូស្និទ្ធស្នាលក្នុងមួយជីវិតមានការថយចុះពី ២៩% នៅឆ្នាំ (២០១៤) មក២១% នៅឆ្នាំ២០២១។

៥.២. បញ្ចប់ផែនទីបង្ហាញផ្លូវ ឆ្ពោះទៅធ្វើវិសោធនកម្មច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ។

៥.៣. ស្ត្រីរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ចំនួន ៣.៦៥៩ករណី ទទួលបានសេវាប្រឹក្សាយោបល់ផ្លូវចិត្ត និងផ្នែកច្បាប់ នៅទូទាំង២៥រាជធានី-ខេត្ត (ក្នុងនោះជនរងគ្រោះ ចំនួន ៥៦៩ករណី ទទួលបានជំនួយផ្នែកច្បាប់ពីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា តាមរយៈក្រុមប្រឹក្សាជាតិដើម្បីស្ត្រី និង ១៦៣ករណី ទទួលបានការការពារផ្នែកច្បាប់ពីមេធាវីស្ម័គ្រចិត្តសម្តេចតេជោ)។ ជាមួយគ្នានេះ ក្រសួងក៏បានសម្របសម្រួល និងផ្តល់សេវាជូនដល់ស្ត្រីនិងក្មេងស្រីរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ចំនួន ៣.០៤៥ករណី (អំពើហិង្សាក្នុងគ្រួសារ ចំនួន១.៧៥៧ករណី ករណីរំលោភសេពសន្ថវៈចំនួន ១.២៥៨ករណី និងករណីអំពើជួញដូរមនុស្ស ចំនួន ៣០ករណី)។

៥.៤. កន្លែងផ្តល់សេវាចម្រុះជួយជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ (One Stop Service Unit) ក្នុងរាជធានី-ខេត្ត ចំនួន ៦ បានបង្កើត និងដំណើរការ ព្រមទាំងបានរៀបចំក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងខេត្តចំនួន១០ និងស្រុកចំនួន៣៩។

៥.៥. សេវាជំនួយតាមទូរស័ព្ទ (Help Line) និងឌីជីថល ដូចជា កម្មវិធី GBV-Safe App, Chatbot និងប្រមូលទិន្នន័យតាមប្រព័ន្ធឌីជីថល GBV Digital Data Collection, E-Learning កំពុងអនុវត្តសាកល្បងក្នុងគោលបំណងបង្ការទប់ស្កាត់ និងឆ្លើយតបទាន់ពេលវេលាចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

៥.៦. គម្រោងបង្ការទប់ស្កាត់អាពាហ៍ពិពាហ៍វ័យកុមារ និងការមានផ្ទៃពោះវ័យជំទង់ខេត្តរតនគិរីបានអនុវត្តគ្រប់ស្រុកទូទាំងខេត្ត ដើម្បីបន្តនិរន្តរភាពរដ្ឋបាលខេត្ត បានដាក់បញ្ចូលកម្មវិធីនេះទៅក្នុងផែនការវិនិយោគរបស់ខេត្តនិងបានបែងចែកកញ្ចប់ថវិកាសម្រាប់អនុវត្ត ព្រមទាំងកំពុងពិនិត្យលទ្ធភាពក្នុងការរៀបចំផែនការសកម្មភាពថ្នាក់ជាតិស្តីពីការបង្ការទប់ស្កាត់អាពាហ៍ពិពាហ៍វ័យកុមារនិងការមានផ្ទៃពោះវ័យជំទង់។

៥.៧. ក្នុងនាមជាអនុប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) និងជាប្រធានក្រុមការងារសហប្រតិបត្តិការអន្តរជាតិ ក្រសួងបានដឹកនាំគណៈប្រតិភូអន្តរក្រសួង ចូលរួមប្រជុំទ្វេភាគីជាមួយស្ថានទូតសហរដ្ឋអាមេរិក ដើម្បីឆ្លើយតប និងបំភ្លឺលើរបាយការណ៍វាយតម្លៃការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងបានដឹកនាំកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់និងក្រុមការងារបច្ចេកទេសថ្នាក់តំបន់នៃប្រទេសសមាជិកខមមីត (COMMIT)។

៥.៨. មន្ត្រីក្រសួងនិងមន្ទីរកិច្ចការនារី និងអ្នកផ្តល់សេវាពាក់ព័ន្ធទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិចំនួន ៣១.៣៥៧នាក់ (ស្រី ៨.៧៣៩នាក់) ទទួលបានកម្មវិធីអភិវឌ្ឍសមត្ថភាពទាក់ទងនឹងជំនាញស្តីពីការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការផ្តល់សេវាឆ្លើយតបជូនស្ត្រីនិងក្មេងស្រីដែលរងគ្រោះដោយហិង្សាទាក់ទងនឹងយេនឌ័រ បរិយាបន្នពិការភាព ការទប់ស្កាត់ការការរំលោភបំពានផ្លូវភេទ ការជួញដូរមនុស្ស និងការប្រើប្រាស់គ្រឿងញៀន ។

៥.៩. ក្រសួងកិច្ចការនារី និងក្រសួងព័ត៌មាន បានចេញសេចក្តីប្រកាសរួមស្តីពីក្រមប្រតិបត្តិប្រព័ន្ធផ្សព្វផ្សាយសម្រាប់ការរាយការណ៍អំពើហិង្សាលើស្ត្រី និងបានបណ្តុះបណ្តាលនិងចងបណ្តាញទំនាក់ទំនងជាមួយបណ្តាញសារព័ត៌មាននិងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដើម្បីជំរុញប្រសិទ្ធភាពក្នុងការអនុវត្តក្រមប្រតិបត្តិប្រព័ន្ធផ្សព្វផ្សាយសម្រាប់រាយការណ៍អំពើហិង្សាលើស្ត្រី។

៥.១០. ប្រព័ន្ធផ្សព្វផ្សាយតាមអនឡាញរបស់ក្រសួង បានដាក់ឱ្យដំណើរការតាមរយៈបណ្តាញទំនាក់ទំនងសង្គម ដោយរៀបចំយុទ្ធនាការឌីជីថល យុទ្ធនាការ១៦ថ្ងៃបំពាក់បូពណ៌ស បញ្ឈប់អំពើហិង្សាលើស្ត្រីនិងក្មេងស្រី ដល់មហាជន ចំនួនជាង៣,៩លាននាក់ និងអ្នកដែលចូលរួម ចំនួនជាង ១,៥លាននាក់។

បញ្ហាប្រឈម និងកាលានុវត្តភាព៖

- ស្ត្រីមួយចំនួននៅតែប្រឈមនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដែលបញ្ហានេះបានដាក់បន្ទុកផ្នែកសេដ្ឋកិច្ច និងសង្គមដល់គ្រួសារ សហគមន៍ និងសង្គមជាតិ ដោយគ្រួសារ និងរដ្ឋត្រូវចំណាយលើសេវាសុខភាព ការបាត់បង់ផលិតភាព ជម្រកសុវត្ថិភាពសម្រាប់ស្ត្រីរងគ្រោះនិងកូនៗ សេវាសង្គមកិច្ច សេវាច្បាប់ និងសេវាចាំបាច់ផ្សេងៗទៀត ដើម្បីស្តារនីតិសម្បទាស្ត្រីរងគ្រោះ។ ក្នុងន័យនេះ ការលុបបំបាត់រាល់ទម្រង់នៃអំពើហិង្សាលើស្ត្រី នៅតែជាបញ្ហាអាទិភាពចម្បង ក្នុងការអភិវឌ្ឍមូលធនមនុស្ស និងភាពសុខដុមរមនាក្នុងគ្រួសារ និងសង្គមជាតិ។
- សកលភាវូបនីយកម្មនិងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាខុសគោលដៅ បណ្តាលឱ្យមានការលេចឡើងនូវរូបភាពថ្មីៗនៃអំពើហិង្សានិងការកេងប្រវ័ញ្ចលើស្ត្រីនិងកុមារ ដែលបានជះឥទ្ធិពលអវិជ្ជមានទៅដល់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ។

## ៦. ស្ត្រីក្នុងវិស័យសាធារណៈ នយោបាយ និងភាពជាអ្នកដឹកនាំ

៦.១. ស្ត្រីជាសមាជិការដ្ឋសភា បច្ចុប្បន្នមានចំនួន ១៣,៦០% (ឆ្នាំ២០២៣)។ កម្ពុជា មានស្ត្រី ១រូប ជាប្រធានរដ្ឋសភា ស្ត្រី២រូប ជាប្រធានគណៈកម្មការជំនាញ។ ស្ត្រីជាសមាជិកាព្រឹទ្ធសភា បានកើនឡើងពី១៤,៧៥% (ឆ្នាំ១៩៩៩) ដល់១៦,១៣% (ឆ្នាំ២០១៩) ក្នុងនោះ មានស្ត្រី២រូប ជាប្រធានគណៈកម្មការជំនាញ។ បច្ចុប្បន្ន ស្ត្រី ៣រូប ជារដ្ឋមន្ត្រី ស្ត្រី ១រូប ជាអគ្គសវនករ និងស្ត្រី ១រូបជាអគ្គទេសាភិបាលធនាគារជាតិ (ឋានៈស្មើទេសរដ្ឋមន្ត្រី)។

៦.២. សហគមន៍អន្តរជាតិ បានវាយតម្លៃខ្ពស់ ចំពោះការចូលរួមរបស់ស្ត្រីកម្ពុជា ក្នុងកងកម្លាំងរក្សាសន្តិភាពដែលបាននឹងកំពុងបំពេញបេសកកម្មក្រៅប្រទេស។ កម្ពុជាទទួលបានចំណាត់ថ្នាក់លេខ ៩ ក្នុងចំណោម ១២៣ប្រទេស និងចំណាត់ថ្នាក់លេខ ១ ក្នុងក្របខណ្ឌអាស៊ាន។

៦.៣. សមាមាត្រស្ត្រីនៅក្នុងថ្នាក់ធ្វើសេចក្តីសម្រេច នៅក្នុងវិស័យសាធារណៈ មានការកើនឡើងជាបន្តបន្ទាប់។ ក្រសួង-ស្ថាប័នភាគច្រើន បានអនុវត្តគោលការណ៍ជ្រើសរើសមន្ត្រីរាជការថ្មី ដែលយកចិត្តទុកដាក់បង្កើនចំនួនមន្ត្រីរាជការជាស្ត្រី ជាពិសេសលើការកំណត់ជ្រើសរើសមន្ត្រីរាជការជាស្ត្រីពី២០% ទៅ៥០% ក្នុងក្របខ័ណ្ឌថ្មី។ មន្ត្រីរាជការជាស្ត្រីបានកើនឡើងពី៤១% នៅឆ្នាំ២០១៨ ដល់៤២% នៅឆ្នាំ២០២២។ ស្ត្រីជាមន្ត្រីរាជការក្នុងតួនាទីធ្វើសេចក្តីសម្រេច ចាប់ពីអនុប្រធានការិយាល័យ ដល់អគ្គនាយកនិងឋានៈស្មើ បានកើនឡើងពី២៤.៣៣% នៅឆ្នាំ២០១៨ ដល់២៧% នៅឆ្នាំ២០២២។

៦.៤. នៅថ្នាក់ក្រោមជាតិ មានស្ត្រី ២រូប ជាអភិបាលខេត្ត (៨%) មានស្ត្រី ៧រូប ជាអភិបាលក្រុងស្រុក ខណ្ឌ (៣.៤៣%)។ ស្ត្រី ជាមេឃុំ-ចៅសង្កាត់ មានចំនួន ១៣០រូប (៧,៨៩%) ក្នុងឆ្នាំ២០១៧ និងកើនឡើងដល់ចំនួន ១៧៦រូប (១០.៦៥%) ក្នុងឆ្នាំ២០២២ និងស្ត្រីជាសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ បានកើនឡើងពី១៧,៧% នៅឆ្នាំ២០១៧ ដល់ ២២% នៅឆ្នាំ២០២២។

៦.៥. ក្រសួងកិច្ចការនារី បានដឹកនាំការសម្របសម្រួលជាមួយក្រសួង-ស្ថាប័ន សង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍និងដៃគូពាក់ព័ន្ធ បានផ្តួចផ្តើមកម្មវិធីអភិវឌ្ឍភាពជាអ្នកដឹកនាំដល់ស្ត្រី និងយុវជនរបស់ក្រសួងជាបន្តបន្ទាប់ទាំងនៅថ្នាក់ជាតិនិងក្រោមជាតិ។ នៅក្នុងនោះ ក្រុមការងារបច្ចេកទេសស្តីពីស្ត្រីក្នុងភាពជាអ្នកដឹកនាំនិងអភិបាលកិច្ច បានបង្កើតនៅឆ្នាំ២០១៥ និងបានដំណើរការកិច្ចប្រជុំជាទៀងទាត់ ដើម្បីពិនិត្យមើលលើវឌ្ឍនភាព បញ្ហាប្រឈម និងលើកទិសដៅក្នុងការលើកកម្ពស់ស្ត្រីក្នុងថ្នាក់ធ្វើសេចក្តីសម្រេច និងសមភាពយេនឌ័រក្នុងដំណើរការអភិបាលកិច្ច រួមទាំងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ និងការអនុវត្តផែនការជ្រើសរើសក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលជាស្ត្រីតាមក្រសួង-ស្ថាប័ន ពី២០% ទៅ៥០% ជាដើម។

៦.៦. ក្រសួង ក្នុងភាពជាដៃគូជាមួយសាលាភូមិន្ទរដ្ឋបាល បានផ្តល់វគ្គបណ្តុះបណ្តាលថ្នាក់ដឹកនាំនិងគណៈគ្រប់គ្រងជាស្ត្រីដែលមានរយៈពេល១២០ម៉ោង សម្រាប់ស្ត្រីជាថ្នាក់ដឹកនាំមានឋានៈចាប់ពីអគ្គនាយករងដល់រដ្ឋលេខាធិការ សរុបចំនួន១៦៤រូប។ ក្រសួងបានសហការជាមួយសាលាជាតិរដ្ឋបាលមូលដ្ឋានបានផ្តល់វគ្គភាពជាអ្នកដឹកនាំសម្រាប់ស្ត្រីជាអភិបាល អភិបាលរងក្រុង ស្រុក ខណ្ឌ សរុបចំនួន១៩០រូប។

៦.៧. នៅឆ្នាំ២០២១ ដល់ឆ្នាំ២០២៣ ក្រសួងកិច្ចការនារី បានសហការជាមួយក្រសួងមុខងារសាធារណៈ ក្រសួងការពារជាតិ ក្រសួងបរិស្ថាន និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រៀបចំវគ្គបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំរបស់ស្ត្រី និងសិល្បៈនៃការប្រាស្រ័យទាក់ទងប្រកបដោយឥទ្ធិពល ដល់ស្ត្រីជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ដែលមានតួនាទីចាប់ពីប្រធាននាយកដ្ឋាន ដល់អគ្គនាយក អគ្គនាយករង អគ្គាធិការ អគ្គាធិការរង ចំនួន ៣៦៧រូប។

៦.៨. ក្រសួងបានរៀបចំវេទិកាជាតិស្តីពីស្ត្រីក្នុងភាពជាអ្នកដឹកនាំនិងអភិបាលកិច្ច ដែលជាព្រឹត្តិការណ៍ជាតិប្រចាំឆ្នាំ និងបានពិនិត្យលើវឌ្ឍនភាពនិងកំណត់ទិសដៅបន្ត ក្នុងការលើកកម្ពស់តួនាទីស្ត្រីក្នុងភាពជាអ្នកដឹកនាំនៅគ្រប់កម្រិត។ សមាសភាពអ្នកចូលរួម រួមមាន ថ្នាក់ដឹកនាំជាស្ត្រី ថ្នាក់ជាតិ-អន្តរជាតិ មកពីអង្គនីតិបញ្ញត្តិ អង្គនីតីប្រតិបត្តិ អង្គទូត សង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍អន្តរជាតិ និងថ្នាក់ដឹកនាំរដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសិក្សា ក្រុមយុវជន និងតំណាងគណបក្សនយោបាយ។

៦.៩. កម្មវិធីអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំរបស់យុវជនដើម្បីសមភាពយេនឌ័រ ចំនួន ២វគ្គរដូវកាល ដែលមានយុវជន ចំនួន ៤០រូប បានរៀបចំដើម្បីអភិវឌ្ឍយុវជននៅតាមគ្រឹះស្ថានឧត្តមសិក្សា និងស្ថាប័នសាធារណៈ ឱ្យក្លាយទៅជាអ្នកដឹកនាំដែលចូលរួមលើកកម្ពស់សមភាពយេនឌ័រ និងលុបបំបាត់នូវការរើសអើងលើស្ត្រីនៅក្នុងគ្រួសារ សហគមន៍ និងសង្គម។

៦.១០. កម្មវិធីលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ក្មេងស្រី បានរៀបចំតាមរយៈកញ្ចប់យុទ្ធនាការទិវាអន្តរជាតិក្មេងស្រី និងកម្មវិធីរត់ដើម្បីក្មេងស្រី វេទិកាជជែកពិភាក្សា កម្មវិធីបាល់ទាត់ស្ត្រី និងវីដេអូខ្លីៗ ខិតប័ណ្ណ បានផ្សព្វផ្សាយតាមប្រព័ន្ធបណ្តាញសង្គមនានា ដើម្បីលើកកម្ពស់ការគាំទ្រពីសំណាក់ក្រុមគ្រួសារ

សហគមន៍ និងដៃគូពាក់ព័ន្ធ រួមទាំងបុរសនិងក្មេងប្រុស ក្នុងការលើកកម្ពស់ការទទួលបានសិទ្ធិពេញលេញរបស់ក្មេងស្រី និងការចូលរួមរបស់ក្មេងស្រីនៅក្នុងកិច្ចអភិវឌ្ឍសង្គមសេដ្ឋកិច្ចលើគ្រប់វិស័យ។

បញ្ហាប្រឈម និងកាលានុវត្តភាព៖

- សមភាពយេនឌ័រ ក្នុងតួនាទីធ្វើសេចក្ដីសម្រេច នៅក្នុងវិស័យដែលមានគម្លាតខ្ពស់ រួមមាន វិស័យនយោបាយ ឌីជីថល វិទ្យាសាស្ត្រ ព័ត៌មាន ការគ្រប់គ្រងគ្រោះមហន្តរាយ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ។
- ត្រូវការបន្ថែមទៀត ក្នុងការដាក់ចេញនូវវិធានការនិងមធ្យោបាយដើម្បីគាំទ្របរិយាកាសមេត្រីភាពនិងសុវត្ថិភាពនៅកន្លែងធ្វើការ និងនៅតាមសហគមន៍ ដូចជាទារកដ្ឋានជាដើម ដែលជាចំណែកជួយគាំទ្រដល់ស្ត្រី ក្នុងការចូលរួមក្នុងភាពជាអ្នកដឹកនាំ ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឱ្យពេញលេញ។
- ផ្នត់គំនិត ឥរិយាបថគ្រួសារ និងសង្គម នៅបន្តរើសអើងលើតួនាទីស្ត្រីក្នុងភាពជាអ្នកដឹកនាំ ដែលជាកត្តារាំងដល់ការអភិវឌ្ឍសក្តានុពលរបស់ស្ត្រី ក្នុងការចូលរួមពេញលេញក្នុងតួនាទីធ្វើសេចក្ដីសម្រេចក្នុងវិស័យសេដ្ឋកិច្ច សង្គមកិច្ច សាធារណៈ និងនយោបាយ។ នៅក្នុងនោះ ត្រូវការការគាំទ្រនិងចូលរួមបន្ថែមទៀតពីបុរសនិងក្មេងប្រុស លើការលើកកម្ពស់សមភាពយេនឌ័រ ដែលជាកិច្ចការនិងគុណតម្លៃរួម និងការបណ្តុះភាពជាអ្នកដឹកនាំរបស់ក្មេងស្រីនៅកម្រិតគ្រួសារ និងសហគមន៍។
- ភាពជាគំរូ និងការចងក្រងបណ្តាញស្ត្រីជាអ្នកដឹកនាំ ព្រមទាំងប្រព័ន្ធផ្តល់ការគាំទ្រ ការអភិវឌ្ឍសមត្ថភាព និងហ្វឹកហ្វឺន ក្នុងភាពជាអ្នកដឹកនាំ គឺជាកត្តាចាំបាច់ ខណៈស្ត្រីនិងក្មេងស្រីត្រូវចាប់យកឱកាសនិងបណ្តុះភាពជាអ្នកដឹកនាំរបស់ខ្លួនឯង ដោយផ្អែកលើសក្តានុពលនិងទេពកោសល្យរបស់ខ្លួននីមួយៗ។
- វត្តមានរបស់ស្ត្រីនៅក្នុងភាពជាអ្នកដឹកនាំ ជាផ្នែកដ៏សំខាន់នៅក្នុងការពន្លឿនការអភិវឌ្ឍវិស័យផ្សេងៗទៀត។ ជាក់ស្តែង របាយការណ៍ UNDP ស្តីពីចំណេះដឹងក្នុងការជំរុញឱ្យសម្រេចគោលដៅអភិវឌ្ឍប្រកបដោយចីរភាព (SDGs PUSH INSIGHTS REPORT CAMBODIA)[2] បានរកឃើញថា នៅបណ្តាប្រទេសនានា ក៏ដូចជាកម្ពុជា ការសម្រេចគោលដៅ ៥.៥ ស្តីពីការសម្រេចការចូលរួមពេញលេញនិងឱកាសស្មើភាពរបស់ស្ត្រីក្នុងភាពជាអ្នកដឹកនាំនៅគ្រប់កម្រិត ជាគោលដៅអន្តរវិស័យ និងជួយជំរុញឱ្យឆាប់សម្រេចដល់គោលដៅផ្សេងៗទៀត នៃ SDGs។

## ៧. ការបញ្ជ្រាបយេនឌ័រ ក្នុងកម្មវិធីប្រែប្រួលអាកាសធាតុ

៧.១. ក្រសួងកិច្ចការនារី បានដឹកនាំការរៀបចំ និងសម្របសម្រួលផែនការមេស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ ឆ្នាំ២០១៨-២០៣០។ នៅក្នុងនោះ គម្រោងសាកល្បងចំនួន៤ បានអនុវត្តដោយជោគជ័យ ដែលគាំទ្រអាជីវកម្មខ្នាតតូចចម្រុះ និងផ្នែកកសិកម្ម លើកកម្ពស់ជីវភាពគ្រួសាររបស់ស្ត្រី

[2] https://sdgpush-insights.undp.org/cambodia

ក្នុងបរិបទនៃការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ គម្រោងសាកល្បង ចំនួន ៣ បានអនុវត្តដោយជោគជ័យ ក្នុងខេត្ត ៣ ដោយសមត្ថភាពធន់របស់សហគមន៍មានភាពប្រសើរឡើង តាមរយៈលទ្ធភាពទទួលបានអនាម័យជនបទ ការប្រើប្រាស់ទឹកស្អាតដោយសុវត្ថិភាព ការគ្រប់គ្រងធនធានទឹក និងលទ្ធភាពក្នុងការបង្កបង្កើនផលកសិកម្មបានកើនឡើង។

៧.២. បានផ្សព្វផ្សាយការបញ្ជ្រាបយេនឌ័រក្នុងគម្រោងវិនិយោគបន្សាំនឹងការប្រែប្រួលអាកាសធាតុ ដល់សាស្ត្រាចារ្យនិងនិស្សិតនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ចំនួន ២៧៥នាក់ (ស្រី១៥៤នាក់) ដើម្បីលើកកម្ពស់ការចូលរួមជាសាធារណៈ តាមរយៈការបញ្ជ្រាបយេនឌ័រ និងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី និងក្មេងស្រី ក្នុងភាពធន់នឹងអាកាសធាតុ ការគ្រប់គ្រងគ្រោះមហន្តរាយនិងការកាត់បន្ថយរាល់ទម្រង់នៃការរើសអើងនានា។

៧.៣. ក្រសួង មន្ទីរកិច្ចការនារី មន្ទីរពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រជាពលរដ្ឋនៅក្នុងខេត្តគោលដៅចំនួន ២៤៩នាក់ (ស្រី ១២៤នាក់) ត្រូវបានកសាងសមត្ថភាព ស្ដីពីការគណនាតម្លៃបន្ថែម និងគិតគូរពីផលចំណេញផ្នែកសេដ្ឋកិច្ចឆ្លើយតបនឹងយេនឌ័រ ក្នុងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ តាមរយៈការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ការលើកកម្ពស់អនាម័យជនបទ ការគ្រប់គ្រងធនធានទឹក ការប្រើប្រាស់ទឹកស្អាត និងលទ្ធភាពក្នុងការបង្កបង្កើនផលកសិកម្ម ក្នុងការលើកម្ពស់ភាពធន់របស់សហគមន៍ជនបទក្នុងខេត្តកំពត កំពង់ធំ ព្រៃវែង និងខេត្តបាត់ដំបង។

៧.៤. មន្ត្រីមន្ទីរកិច្ចការនារី និងមជ្ឈមណ្ឌលភិវឌ្ឍន៍ស្ត្រីខេត្ត ចំនួន ២៩៦នាក់(ស្រី ២៥១នាក់) ទទួលបានការបណ្តុះបណ្តាលស្តីពីយេនឌ័រក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតងនិងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ ជាពិសេសការផ្សារភ្ជាប់នឹងការអភិវឌ្ឍសេដ្ឋកិច្ចគ្រួសារសម្រាប់ស្ត្រី លើការសន្សំសំចៃនិងចំណេះដឹងពីថាមពលកកើតឡើងវិញ។

៧.៥. បានរៀបចំឯកសារណែនាំស្តីពីវិធីសាស្ត្រក្នុងការបញ្ចូលយេនឌ័រ ទៅក្នុងការគ្រប់គ្រងស្ថិតិពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុនិងការគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា និងបានអភិវឌ្ឍសមត្ថភាពដល់ក្រុមការងារបញ្ជ្រាបយេនឌ័រតាមក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងការប្រើប្រាស់ឯកសារណែនាំនេះ ដើម្បីលើកកម្ពស់ការរៀបចំស្ថិតិតាមវិស័យពាក់ព័ន្ធ បានឆ្លើយតបនឹងយេនឌ័រ។

**បញ្ហាប្រឈម និងកាលានុវត្តភាព៖**

- ក្នុងបរិការណ៍នៃការប្រែប្រួលអាកាសធាតុ និងការធ្វើចំណាកស្រុក ស្ត្រីនៅតាមមូលដ្ឋាន ត្រូវទទួលបន្ទុកការងារផ្ទះ ការងារកសិកម្ម និងពឹងផ្អែកខ្លាំងលើធនធានធម្មជាតិសម្រាប់ទ្រទ្រង់គ្រួសារ ប៉ុន្តែស្ត្រីជាច្រើនពុំទាន់ទទួលបានឱកាសចូលរួមក្នុងការសម្រេច និងទទួលបានព័ត៌មានពេញលេញនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចគ្រួសារ ដែលផ្សារភ្ជាប់នឹងការថែទាំបរិស្ថាន ការជំរុញភាពធន់នឹងការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍសេដ្ឋកិច្ចបៃតង។

- ស្ថិតិយេនឌ័រ និងអំណះអំណាង សម្រាប់គាំទ្រដល់ការវិភាគយេនឌ័រ និងការរៀបចំគោលនយោបាយ និងកម្មវិធីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ នៅមានកម្រិត រួមទាំងប្រព័ន្ធ និងយន្តការ ក្នុងការគ្រប់គ្រង និងចែករំលែកព័ត៌មាន ក្នុងកិច្ចការនេះ នៅមានកម្រិត។
- សមាសភាពនិងតួនាទីស្ត្រីក្នុងថ្នាក់ធ្វើសេចក្តីសម្រេចនៅក្នុងកម្រិតក្នុងវិស័យពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ និងអភិវឌ្ឍន៍បៃតង នៅមានចំនួនតិច រួមទាំងសហគ្រិននិងអាជីករ ដែលប្រកប មុខរបរក្នុងសេដ្ឋកិច្ចបៃតង។

## ៨. ការគាំទ្រ ការពង្រឹងសមត្ថភាព និងការអភិវឌ្ឍស្ថាប័នកិច្ចការនារី

៨.១. ក្រសួងកិច្ចការនារី បានចូលរួមអនុវត្តការងារកែទម្រង់ស្ថាប័ន និងអភិបាលកិច្ច ដូចជាកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ ក្នុងការពង្រឹងសមត្ថភាពស្ថាប័ន និងប្រសិទ្ធភាពសេវាសាធារណៈរបស់ក្រសួង កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងការអនុវត្តនិងគ្រប់គ្រងថវិកាប្រកបដោយប្រសិទ្ធភាព និងកម្មវិធីវិមជ្ឈការនិងវិសហមជ្ឈការ ក្នុងការផ្ទេរមុខងារទៅរដ្ឋបាលនៅថ្នាក់ក្រោមជាតិ។ នៅក្នុងក្របខ័ណ្ឌវិមជ្ឈការនិងវិសហមជ្ឈការ ក្រសួងបានផ្ទេរមុខងារចំនួន ៣ ទៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ នៅក្នុងនោះ មន្ត្រីការិយាល័យកិច្ចការនារីក្រុង ស្រុក ខណ្ឌ ចំនួន ២៧០នាក់ ( ស្ត្រីចំនួន ២៦១នាក់) និងមន្ត្រីជាប់កិច្ចសន្យាចំនួន១៨នាក់ ជាស្ត្រី បានធ្វើសមាហរណកម្មមុខតំណែងគ្រប់គ្រង ទៅក្នុងរចនាសម្ព័ន្ធនៃរដ្ឋបាលក្រុង ស្រុក-ខណ្ឌ។

៨.២. ផែនការសកម្មភាពរួម គ្រប់ដំណាក់កាល ផែនការយុទ្ធសាស្ត្រថវិកា (BSP) និងផែនការចំណាយថវិកាប្រចាំឆ្នាំ បានរៀបចំជាប្រចាំ ក្នុងការគាំទ្រដល់ការអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈទី៥។ ប្រព័ន្ធគ្រប់គ្រងរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS) និងអនុវត្តប្រតិបត្តិការហិរញ្ញវត្ថុ តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) បាននិងកំពុងដំណើរក្នុងក្រសួងកិច្ចការនារី។

៨.៣. ក្រសួងបានបង្កើត និងប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវទារកដ្ឋាន តាំងពីឆ្នាំ២០១៨ និងបន្ទប់បំបៅដោះកូន នៅចុងឆ្នាំ២០២២ ដើម្បីជួយសម្រួលដល់មន្ត្រីរាជការ និងបុគ្គលិក នៅក្នុងក្រសួងកិច្ចការនារី ដែលមានកូនតូច។

៨.៤. ថ្នាក់ដឹកនាំនិងមន្ត្រីក្រសួង និងមន្ទីរកិច្ចការនារីរាជធានី-ខេត្ត ទទួលបានកម្មវិធីអភិវឌ្ឍន៍សមត្ថភាពពាក់ព័ន្ធសំខាន់ៗ ដូចជាភាពជាអ្នកដឹកនាំនិងនវានុវត្តន៍ ការបញ្ជ្រាបយេនឌ័រ ជំនាញស្វែងរកការគាំទ្រមតិ សហគ្រិនភាពស្ត្រី សិទ្ធិជនមានពិការភាព វិធីសាស្ត្របង្ការ និងឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រ ការរៀបចំផែនការ ស្ថិតិ តាមដាននិងវាយតម្លៃ ការគ្រប់គ្រងរដ្ឋបាល ការកែទម្រង់ថវិកា ការប្រើប្រាស់បច្ចេកទេសឌីជីថល ភាពជាអ្នកដឹកនាំ និងស្ត្រីអាស៊ាន។

៨.៥. មន្ត្រីរាជការក្រសួងកិច្ចការនារី ត្រូវបានតែងតាំង ប្រគល់ភារកិច្ច ចំនួន១៨៧នាក់ (ស្ត្រី ១៣៨នាក់) តម្លើង ឋានន្តរស័ក្តិ ថ្នាក់ និងធ្វើនិយ័តកម្មសរុប ចំនួន១៨០នាក់ (ស្ត្រី១៤០នាក់) និងជាការលើកទឹកចិត្តដល់មន្ត្រីរាជការ តាមរយៈការផ្តល់គ្រឿងឥស្សរិយយសចំនួន ៥៥៨នាក់ (ស្ត្រី៤៧៨នាក់)។ ជាមួយនឹងការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ សរុបចំនួន ១០៥នាក់ (ស្ត្រី១០០នាក់)។ ក្រសួងក៏បានធ្វើការជ្រើសរើសក្របខណ្ឌមន្ត្រីរាជការ ចំនួន ៨៦នាក់ ស្ត្រី ៥៩នាក់ និងបានអភិវឌ្ឍសមត្ថភាពលើការងារគ្រប់គ្រងរដ្ឋបាលដល់មន្ត្រីរាជការសរុប ចំនួន ៤៣១នាក់ (ស្ត្រី ៣៦៨នាក់)។

៨.៦. ក្រុមការងារទទួលបន្ទុកក្រុមងាយរងគ្រោះជាស្ត្រីនិងក្មេងស្រីប្រកបដោយបរិយាបន្ន បានបង្កើត និងដាក់ឱ្យដំណើរការ នៅឆ្នាំ២០១៩ នៅក្នុងការដឹកនាំសម្របសម្រួលផ្ទៃក្នុង និងជាមួយអង្គភាពពាក់ព័ន្ធ លើការឆ្លើយតបប្រកបដោយបរិយាបន្ន នៅក្នុងវិស័យជាអាទិភាពនីមួយៗរបស់នារីរតនៈទី៥ និងបានដើរតួនាទី ក្នុងការបញ្ជ្រាបយេនឌ័រ និងបរិយាបន្ន នៅក្នុងបរិបទ និងរបៀបវារៈគោលនយោបាយ និងកម្មវិធីពាក់ព័ន្ធនឹងពិការភាព សហគមន៍មូស្លីម ស្ត្រីចាស់ជរា ស្ត្រីស្រឡាញ់ភេទដូចគ្នា និងស្ត្រីនិងក្មេងស្រីជនជាតិដើមភាគតិច។ នៅក្នុងនោះ ក្រុមការងារសកម្មភាពជនពិការរបស់ក្រសួងកិច្ចការនារី បានរៀបចំកម្មវិធីអភិវឌ្ឍន៍សមត្ថភាពពាក់ព័ន្ធនឹងការស្វែងរកការគាំទ្រមតិលើបញ្ហាយេនឌ័រ និងជនដែលមានពិការដល់ក្រសួង-ស្ថាប័ន និងដៃគូពាក់ព័ន្ធ និងបានចូលរួមសហការជាមួយក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធក្នុងការលើកកម្ពស់តួនាទីនិងសិទ្ធិរបស់ស្ត្រី និងជនដែលមានពិការ។

៨.៧. ក្រោយពីបានទទួលជោគជ័យ ក្នុងការរៀបចំនិងដឹកនាំកិច្ចប្រជុំកម្រិតខ្ពស់ ក្នុងឆ្នាំ២០២២ ដូចជាវេទិកាស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ នៅក្នុងកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប កិច្ចប្រជុំឧត្តមមន្ត្រី COMMIT នៃអនុតំបន់មេគង្គ កិច្ចប្រជុំរៀបចំយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងក្របខ័ណ្ឌអាស៊ាន កិច្ចប្រជុំកំពូលស្ត្រីអាស៊ាន លើកទី២ និងព្រឹត្តិការណ៍អម ដូចជាពិធីប្រគល់ពានរង្វាន់សហគ្រិនស្ត្រី ក្រសួងកិច្ចការនារី បានដឹកនាំជំរុញការអនុវត្តសកម្មភាពដែលមានចែងក្នុងឯកសារដែលបានអនុម័ត នៅក្នុងកិច្ចប្រជុំកម្រិតខ្ពស់ខាងលើ ដូចជាបានចាប់ផ្តើមដំណើរការធ្វើមូលដ្ឋានីយកម្មនៃរបៀបវារៈ ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ។

៨.៨. ក្នុងកិច្ចសហប្រតិបត្តិការនិងភាពជាដៃគូជាមួយក្រសួង ស្ថាប័នដៃគូពាក់ព័ន្ធ ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ ក្រសួងបានរៀបចំកិច្ចព្រមព្រៀងអនុស្សរណៈយោគយល់ និងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងវិស័យឯកជន ចំនួន ៣៨ ដែលបច្ចុប្បន្នកំពុងមានសុពលភាព និងកំពុងអនុវត្តការងារជាប្រចាំ ចំនួន៣០។

៨.៩. ក្រសួងបានដាក់ធាតុចូលក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ រៀបចំកម្មវិធីវិនិយោគ៣ឆ្នាំរំកិល គោលដៅទី៥នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (២០១៥-២០៣០) និងបានដាក់បញ្ចូលជំពូកស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងអង្កេតប្រជាសាស្ត្រនិងសុខភាពនៅកម្ពុជា ឆ្នាំ២០២១-២០២២។

៨.១០.ឯកសារជំរឿននិងអង្កេតនានាឆ្លើយតបយេនឌ័រ ផ្នត់ស្ថិតិស្តីពីយេនឌ័រថ្នាក់ជាតិ និងសៀវភៅស្ថិតិយេនឌ័រ ចំនួន ៥ខេត្ត បានផលិត និងផ្សព្វផ្សាយដល់ដៃគូពាក់ព័ន្ធ។

៨.១១.ក្រសួងបានផលិតកម្មវិធីវិទ្យុនារីរតនៈ ចំនួន១២៤ប្រធានបទ និងល្ខោនវិទ្យុចំនួន១៤៦រឿង និងបានផ្សព្វផ្សាយវិទ្យុជាតិ និងឯកជន ចំនួន១៣៥០២លើក ព្រមទាំងបានបញ្ចូលនៅក្នុងប្រព័ន្ធបណ្តាញសង្គមរបស់ក្រសួង ចំនួន៥៥០។ បោះពុម្ពនិងផ្សព្វផ្សាយព្រឹត្តិបត្រនារីរតនៈស្តីពីវឌ្ឍនភាពរបស់ស្ត្រីតាមវិស័យ ចំនួន១៥លេខ និងបានផ្សព្វផ្សាយតាមប្រព័ន្ធអេឡិចត្រូនិក។

៨.១២.ក្រសួងបានប្រើប្រាស់**ប្រព័ន្ធបណ្តាញសង្គម** ដើម្បីផ្សព្វផ្សាយបេសកកម្មរបស់ខ្លួន ដល់សាធារណៈជន ដែលបច្ចុប្បន្ន ហ្វេសប៊ុកក្រសួង មានចំនួន **១៦៦៣ន់** followers។ ក្នុងអំឡុង និងក្រោយពីវិបត្តិកូវីដ-១៩ ក្រសួងបានពង្រឹងសមត្ថភាពផ្នែកបច្ចេកវិទ្យាឌីជីថលនិងព័ត៌មាននៅថ្នាក់ជាតិនិងក្រោមជាតិ និងបានប្រើប្រាស់ប្រព័ន្ធបណ្តាញសង្គម ដើម្បីផ្សព្វផ្សាយបេសកកម្មរបស់ខ្លួននិងតួនាទីស្ត្រីតាមវិស័យ ដល់សាធារណៈជន។

**បញ្ហាប្រឈម និងកាលានុវត្តភាព៖**

- ការរីករាលដាលជាសកលនៃជំងឺកូវីដ-១៩ បានតម្រូវឱ្យក្រសួងមានការច្នៃប្រឌិត និងនវានុវត្តន៍ ដោយងាកមកប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថលក្នុងការផ្តល់សេវារបស់ខ្លួន។ ទន្ទឹមនឹងនេះ វិសាលភាពការងារដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមថ្មីៗមានការកើនឡើង ខណៈដែលធនធានថវិកាប្រចាំឆ្នាំរបស់ក្រសួងកិច្ចការនារី និងដៃគូ សម្រាប់ការអនុវត្តការងារក្រសួងនិងមន្ទីរកិច្ចការនារីរាជធានី ខេត្ត នៅមានកម្រិតនៅឡើយ។ ជាមួយគ្នានេះ ក្រសួងក៏តម្រូវឱ្យមានការពិនិត្យមើលឡើងវិញលើរចនាសម្ព័ន្ធ និងមុខងាររបស់អង្គភាពចំណុះនីមួយៗ ព្រមទាំងរៀបចំនិងគ្រប់គ្រងធនធានមនុស្ស ឱ្យឆ្លើយតបនឹងតម្រូវការចំពោះមុខ និងស្ថានភាពនៃការវិវត្តលឿនសង្គម និងជាសកល។
- ចរន្តនៃការរីកចម្រើនបច្ចេកវិទ្យាឌីជីល ក្រសួងកិច្ចការនារីត្រូវធ្វើទំនើបកម្មស្ថាប័នខ្លួន និងអភិវឌ្ឍសមត្ថភាពខ្លួនផងលើជំនាញឌីជីថល ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមថ្មីៗរបស់ស្ត្រីនិងក្មេងស្រី ឱ្យស្របតាមការវិវត្តន៍របស់សង្គម។ នៅក្នុងនោះ ស្របតាមគោលការណ៍របស់រដ្ឋាភិបាលឌីជីថល តម្រូវឱ្យក្រសួងបង្កើតអង្គភាពបច្ចេកទេសជាក់លាក់ ដើម្បីគាំទ្រដល់ការធ្វើបរិវត្តកម្មឌីជីថលនៅក្នុងស្ថាប័នទាំងថ្នាក់ជាតិ និងក្រោមជាតិ។
- ប្រព័ន្ធគ្រប់គ្រងនិងដំណើរការស្ថិតិនិងទិន្នន័យសមិទ្ធកម្ម និងលទ្ធផលការងាររបស់ក្រសួង និងនៅថ្នាក់ក្រោមជាតិ រួមទាំងស្ថិតិយេនឌ័រនៅតាមវិស័យ នៅមិនទាន់ដំណើរការដោយប្រសិទ្ធភាព និងតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលនៅឡើយ។
- ប្រព័ន្ធតាមដាន និងវាយតម្លៃរបស់ផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ អនុវត្តមិនទាន់បានពេញលេញ ដែលតម្រូវឱ្យមានការកំណត់យន្តការនិងប្រព័ន្ធការងារឱ្យបានច្បាស់លាស់ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

- មូលនិធិដៃគូអភិវឌ្ឍន៍សម្រាប់គាំទ្រនាយកដ្ឋាននិងអង្គភាពជំនាញរបស់ក្រសួងកិច្ចការនារី មានការថយចុះ ដែលតម្រូវឱ្យមានការស្វែងរកប្រភពថ្មីៗ ពង្រឹងភាពជាដៃគូប្រកបដោយយុទ្ធសាស្ត្រ និងពង្រីកប្រសិទ្ធភាពក្នុងការអនុវត្តវិធីដែលគាំទ្រដោយថវិកាជាតិ។
- វិសាលភាពនៃប្រព័ន្ធបណ្តាញសង្គមក្រសួងនៅមានកម្រិត ព្រមទាំងសមត្ថភាពក្រសួងក្នុងការរៀបចំមាតិកាឌីជីថលនិងព័ត៌មានដែលមានការទាក់ទាញ និងចូលរួមពីមហាជននៅបណ្តាញសង្គម ត្រូវការយកចិត្តទុកដាក់ជាអាទិភាព។
- តម្រូវឱ្យមានការបង្កើនការយល់ដឹង និងការចូលរួមអនុវត្តលើកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកែទម្រង់រដ្ឋបាលសាធារណៈ ពីថ្នាក់ដឹកនាំនិងមន្ត្រីរាជការគ្រប់ៗរូបគ្រប់កម្រិត។

## ផ្នែកទី២៖ ចក្ខុវិស័យ និងបេសកកម្ម

### ចក្ខុវិស័យ

ប្រជាពលរដ្ឋខ្មែរគ្រប់រូប មានសិទ្ធិស្មើគ្នាស្របតាមច្បាប់ ជាពិសេសស្ត្រីនិងក្មេងស្រី ទទួលបានសុវត្ថិភាពផ្ទាល់ខ្លួន ព្រមទាំងអាចចូលរួមយ៉ាងពេញលេញ នៅក្នុងកិច្ចការសង្គម មានភាពអង់អាចនិងការធ្វើសេចក្តីសម្រេចនៅគ្រប់កម្រិត និងគ្រប់វិស័យ ដោយស្មើភាពគ្នាជាមួយបុរសនិងក្មេងប្រុស ដើម្បីជានាបាននូវភាពម្ចាស់ការលើខ្លួនឯង និងមានសុខុមាលភាពពេញលេញក្នុងគ្រួសារ សហគមន៍ និងសង្គមជាតិ។

### បេសកកម្ម

ក្រសួងកិច្ចការនារី មានបេសកកម្ម ក្នុងការដឹកនាំភាពជាដៃគូ និងកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធ ក្នុងដំណើរឆ្ពោះទៅសម្រេចសមភាពយេនឌ័រ និងលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីនិងក្មេងស្រីគ្រប់រូបភាព នៅក្នុងសង្គម តាមរយៈ៖

- ការបញ្ជ្រាបយេនឌ័រទៅក្នុងដំណើរការតាក់តែង និងអនុវត្តច្បាប់ គោលនយោបាយ កម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល ផែនការយុទ្ធសាស្ត្រជាតិ និងកម្មវិធីតាមវិស័យ
- ការដឹកនាំកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូជាមួយក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធ រួមទាំងដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល វិស័យឯកជន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំ អនុវត្ត និងពិនិត្យតាមដានការអនុវត្តកម្មវិធីនិងវិធានការគោលនយោបាយជាក់លាក់ ដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រីនិងក្មេងស្រីគ្រប់រូប
- ការពង្រឹងសមត្ថភាព ប្រសិទ្ធភាព និងសមិទ្ធកម្ម ក្នុងការអនុវត្តមុខងាររបស់យន្តការ និងស្ថាប័ននៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ក្នុងការជំរុញការបញ្ជ្រាបយេនឌ័រ និងលើកកម្ពស់ស្ថានភាពស្ត្រី
- ការជំរុញនិងលើកទឹកចិត្តក្នុងការអនុវត្តវិធានការជាក់លាក់និងគំនិតផ្តួចផ្តើមនានាសំដៅលើកកម្ពស់សមធម៌យេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី នៅក្នុងរបៀបវារៈកំណើនសេដ្ឋកិច្ច អភិវឌ្ឍសង្គម និងអភិបាលកិច្ចល្អ
- ពង្រីកកម្មវិធីសិក្សាស្រាវជ្រាវ អំពីផលប៉ះពាល់យេនឌ័រតាមវិស័យ និងក្រុមគោលដៅដែលឆ្លើយតបបរិយាបន្ន និងស្របតាមបរិបទថ្មីៗរបស់សង្គម ដើម្បីស្វែងរកលទ្ធភាព និងវិធានការឆ្លើយតប។

## ផ្នែកទី៣៖ គោលបំណង

ផែនការយុទ្ធសាស្ត្រនារីរតនៈទី ៦ មានគោលបំណងចម្បងៗ ដូចខាងក្រោម៖

១. ពង្រីកវិសាលភាព ក្នុងការបញ្ជ្រាបយេនឌ័រ នៅក្នុងក្របខណ្ឌគោលនយោបាយ និងកម្មវិធីជាតិ រួមទាំងកម្មវិធីកែទម្រង់ស្ថាប័ននិងអភិបាលកិច្ច វិស័យសេដ្ឋកិច្ច វិស័យសុខភាព វិស័យអប់រំ កម្មវិធីគាំពារសង្គម កម្មវិធីប្រែប្រួលអាកាសធាតុ និងសេដ្ឋកិច្ចបៃតង ប្រកបដោយបរិយាបន្ន

២. ពង្រីកកម្មវិធីផ្លាស់ប្តូរឥរិយាបថនិងផ្នត់គំនិតសង្គម ក្នុងការលើកកម្ពស់សមភាពយេនឌ័រនិងលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីនិងក្មេងស្រីគ្រប់រូបនៅក្នុងគ្រួសារ សហគមន៍ និងសង្គម

៣. លើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅគ្រប់កម្រិត ក្នុងវិស័យសាធារណៈ វិស័យឯកជន និងនយោបាយ

៤. ពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី រួមទាំងការលើកកម្ពស់សេដ្ឋកិច្ចគ្រួសាររបស់ស្ត្រី ការអភិវឌ្ឍសហគ្រិនភាព ការដោះស្រាយគម្លាតយេនឌ័រក្នុងការចាប់យកជំនាញនិងមុខរបរ និងកម្មវិធីសេដ្ឋកិច្ចដែលគិតគូរសុខុមាលភាព

៥. លើកកម្ពស់ការការពារសិទ្ធិនិងកាត់បន្ថយរាល់ទម្រង់នៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ ជាពិសេសក្រុមងាយរងគ្រោះ ព្រមទាំងបង្កើនការផ្តល់សេវាដល់ស្ត្រី និងក្មេងស្រីរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រឱ្យកាន់តែមានប្រសិទ្ធភាព គុណភាព និងទាន់ពេលវេលា។

៦. លើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រីនិងគ្រួសារខ្មែរ តាមរយៈការលើកកម្ពស់យន្តការអន្តរក្រសួងស្ថាប័ននិងវិធានការពហុវិស័យ និងការអនុវត្តកម្មវិធីភាពជាមាតានិងបិតានិងការអប់រំកូនតាមបែបវិជ្ជមាន ការពង្រឹងវប្បធម៌អហិង្សា និងកសាងគ្រួសារប្រកបដោយសុភមង្គល។

៧. ការលើកកម្ពស់សុខុមាលភាពរបស់ស្ត្រីនិងក្មេងស្រី រួមទាំងការយល់ដឹងនិងការប្រតិបត្តិត្រឹមត្រូវក្នុងការបង្ការនិងគ្រប់គ្រងជំងឺ ឬបញ្ហាសុខភាពសាធារណៈ អាហារូបត្ថម្ភ ព្រមទាំងការស្វែងរក និងការប្រើប្រាស់សេវាថែទាំសុខភាពបានត្រឹមត្រូវ

៨. លើកកម្ពស់តួនាទីស្ត្រី ក្នុងការអភិវឌ្ឍបៃតង និងការបន្សាំនិងភាពធន់នឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយ

៩. ការពង្រឹងអភិបាលកិច្ចនិងការធ្វើទំនើបកម្មស្ថាប័នក្រសួងកិច្ចការនារី និងអង្គភាពចំណុះ ឱ្យក្លាយជារដ្ឋបាលសាធារណៈឌីជីថលនិងទំនើប ប្រកបដោយសមត្ថភាពខ្ពស់ ខ្លាំង ឆ្លាតវៃ និងស្អាតស្អំ ព្រមទាំងលើកកម្ពស់ប្រសិទ្ធភាព នៅក្នុងគ្រប់ទិដ្ឋភាពនៃកិច្ចប្រតិបត្តិការរបស់ខ្លួន ទាំងការដឹកនាំស្ថាប័ន ការគ្រប់គ្រងព័ត៌មាន ទំនាក់ទំនងសាធារណៈ កិច្ចសហប្រតិបត្តិការជាមួយដៃគូ និងការត្រួតពិនិត្យនិងវាយតម្លៃ។

## ផ្នែកទី៤៖

# ក្របខណ្ឌយុទ្ធសាស្ត្រ

ផែនការយុទ្ធសាស្ត្រនារីរតនៈទី ៦ ២០២៤-២០២៨ ផ្តោតលើកម្មវិធីបញ្ជ្រាបយេនឌ័រ តាមរយៈការធ្វើបរិវត្តកម្មយេនឌ័រ នៅក្នុងក្របខ័ណ្ឌច្បាប់ គោលនយោបាយ និងកម្មវិធីជាតិ និងការផ្លាស់ប្តូរឥរិយាបថសាធារណៈ ដើម្បីលើកកម្ពស់សមភាពយេនឌ័រ ជាយុទ្ធសាស្ត្រស្នូល និងមានកម្មវិធីអាទិភាព ចំនួន ៦ រួមមាន៖ ១).ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី ២).ការលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារ ៣).ការលើកកម្ពស់សុខុមាលភាពរបស់ស្ត្រីនិងក្មេងស្រី ៤).កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រីនិងក្មេងស្រី ៥). ស្ត្រីក្នុងភាពជាអ្នកដឹកនាំនិងអភិបាលកិច្ច និង ៦). ស្ត្រីនិងការប្រែប្រួលអាកាសធាតុ ព្រមទាំងគាំទ្រដោយយុទ្ធសាស្ត្រ ស្តីពីការពង្រឹងប្រសិទ្ធភាព និងអភិវឌ្ឍន៍សមិទ្ធកម្មស្ថាប័ន។

## ផែនការយុទ្ធសាស្ត្រនារីរតនៈទី៦

ដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងភាពអង់អាចរបស់ស្ត្រី និងក្មេងស្រី

**ក្របខ័ណ្ឌបញ្ជ្រាបយេនឌ័រ**

តាមរយៈការធ្វើបរិវត្តកម្មយេនឌ័រ នៅក្នុងក្របខ័ណ្ឌច្បាប់ គោលនយោបាយ កម្មវិធីជាតិ និងតាមវិស័យ និងការផ្លាស់ប្តូរឥរិយាបថជាសាធារណៈ

| យុទ្ធសាស្ត្រទី១ | យុទ្ធសាស្ត្រទី២ | យុទ្ធសាស្ត្រទី៣ | យុទ្ធសាស្ត្រទី៤ | យុទ្ធសាស្ត្រទី៥ | យុទ្ធសាស្ត្រទី៦ |
|---|---|---|---|---|---|
| ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី | ការលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារ | ការលើកកម្ពស់សុខុមាលភាពរបស់ស្ត្រី និងក្មេងស្រី | កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រី និងក្មេងស្រី | ស្ត្រី ក្នុងភាពជាអ្នកដឹកនាំ និងអភិបាលកិច្ច | ស្ត្រី និងការប្រែប្រួលអាកាសធាតុ |

**ការពង្រឹងប្រសិទ្ធភាព និងអភិវឌ្ឍន៍សមិទ្ធកម្មស្ថាប័ន**

ការអនុវត្តកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ វិមជ្ឈការនិងវិសហមជ្ឈការ ការធ្វើទំនើបកម្មស្ថាប័ន ឌីជីថលូបនីយកម្ម ការអភិវឌ្ឍធនធានមនុស្ស ការពង្រឹងប្រព័ន្ធតាមដាននិងវាយតម្លៃ ការគ្រប់គ្រងព័ត៌មាន ទំនាក់ទំនងសាធារណៈ និងកិច្ចសហប្រតិបត្តិការ

## យុទ្ធសាស្រ្តស្នូល៖ ក្របខ័ណ្ឌបញ្រ្ជាបយេនឌ័រ

រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា បន្តបង្កើនការវិនិយោគលើយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រីនិងក្មេងស្រី នៅគ្រប់វិស័យ។ ការណ៍នេះ ក្របខ័ណ្ឌបញ្ជ្រាបយេនឌ័រនៃនារីរតនៈទី ៦ នឹងផ្តោតលើ **ការពង្រីកវិសាលភាពនៃការអនុវត្តការបញ្ជ្រាបយេនឌ័រ** តាមរយៈ**ការធ្វើបរិវត្តកម្មយេនឌ័រ** (Gender Transformative Approach) នៅក្នុងដំណើរការតាក់តែង អនុវត្ត និងតាមដានការអនុវត្តច្បាប់ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ កម្មវិធី និងតាមវិស័យ និងការលើកកម្ពស់ការផ្លាស់ប្តូរឥរិយាបថ និងផ្នត់គំនិតសង្គម ដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីនិងក្មេងស្រី នៅក្នុងគ្រួសារ សហគមន៍ និងសង្គម។

ការដាក់ចេញនូវ**គោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ ឆ្នាំ២០២៤-២០៣៤** គឺជាឯកសារគោល ក្នុងការពង្រឹងនិងពង្រីកការងារបញ្ជ្រាបយេនឌ័រ ព្រមទាំងការធ្វើបរិវត្តកម្មយេនឌ័រនៅតាមវិស័យ តាមរយៈលើកកម្ពស់គណនេយ្យភាពរបស់ក្រសួង-ស្ថាប័ន ការធ្វើស្ថាបនូបនីយកម្មយេនឌ័រ ការពង្រឹងប្រព័ន្ធតាមដាន និងវាយតម្លៃ និងការផ្លាស់ប្តូរផ្នត់គំនិតនិងឥរិយាបថសង្គម ដើម្បីលើកកម្ពស់សមភាពយេនឌ័រ។

ក្នុងបរិការណ៍នេះ **នារីរតនៈទី ៦** ផ្តោតលើអាទិភាព និងវិធានការគន្លឹះ ដូចខាងក្រោម៖

១. ពង្រីកកម្មវិធីសិក្សាស្រាវជ្រាវ អំពីស្ថានភាពយេនឌ័រនៅតាមវិស័យនិងថ្មីៗ ស្របតាមការវិវត្តន៍របស់សង្គម និងរៀបចំគំនិតផ្តួចផ្តើមលើវិធានការគាំទ្រនិងកម្មវិធីនានា។

២. ពង្រឹង និងពង្រីកការបញ្ជ្រាបយេនឌ័រ នៅក្នុងដំណើរការរៀបចំ និងអនុវត្តគោលនយោបាយ និង កម្មវិធីតាមវិស័យ រួមទាំងវិស័យសុខាភិបាល អប់រំ យុវជន កីឡា ពិការភាព និងឌីជីថល។

៣. រៀបចំ និងចាប់ផ្តើមអនុវត្តកម្មវិធីនិងអភិក្រមបរិវត្តកម្មយេនឌ័រ និងបន្តពង្រឹងយន្តការបញ្ជ្រាបយេនឌ័រនៅគ្រប់កម្រិត។

៤. សម្របសម្រួល និងគាំទ្រដល់ក្រសួង-ស្ថាប័ន និងដៃគូពាក់ព័ន្ធ ក្នុងការធ្វើស្ថាប័នូបនីយកម្មយេនឌ័រតាមវិស័យ រួមទាំងការអនុវត្តកម្មវិធីរៀបចំថវិកាឆ្លើយតបនឹងយេនឌ័រ។

៥. ពង្រឹងប្រព័ន្ធ និងយន្តការតាមដានត្រួតពិនិត្យនិងវាយតម្លៃលើការបញ្ជ្រាបយេនឌ័រតាមវិស័យ។

៦. អនុវត្តកម្មវិធីបង្កើនការយល់ដឹងជាសាធារណៈ ការផ្លាស់ប្តូរផ្នត់គំនិតអវិជ្ជមាន និងការស្វែងរកគាំទ្រមតិដើម្បីលើកកម្ពស់សមភាពយេនឌ័រ រួមទាំងការបញ្ជ្រាបយេនឌ័រនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ និងសារព័ត៌មាន។

## យុទ្ធសាស្ត្រ ទី១. ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី

ការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី គឺជាកិច្ចការអាទិភាពមួយ ដើម្បីឈានទៅសម្រេចសមភាពយេនឌ័រនិងសិទ្ធិស្ត្រី ដែលក្នុងនោះ ក៏បានបញ្ជាក់នៅក្នុង**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១** និងក្នុងក្របខ័ណ្ឌគោលនយោបាយនិងកម្មវិធីតាមវិស័យផងដែរ។ អភិក្រមគន្លឹះៗ ដើម្បីពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី គឺការគាំទ្រនិងដាក់ចេញនូវវិធានការនានា សំដៅធានាថា សិទ្ធិ និងឱកាសស្មើភាពក្នុងការទទួលបានការអប់រំនិងជំនាញ មុខរបរនិងការងារ និងសហគ្រិនភាព។

ការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី មានគោលដៅ មិនត្រឹមតែជាការគាំទ្រដល់ស្ត្រីនិងក្មេងស្រី ឱ្យទទួលបាននិងអនុវត្តបានពេញលេញនូវសិទ្ធិ ជម្រើស និងសក្តានុពលរបស់ខ្លួនប៉ុណ្ណោះទេ ហើយក៏ជាផ្នែកដ៏សំខាន់មួយ ក្នុងការជំរុញកំណើនសេដ្ឋកិច្ចនិងកិច្ចអភិវឌ្ឍសង្គម ប្រកបដោយបរិយាបន្ន និងចីរភាព។ ការណ៍នេះ ការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ត្រូវធ្វើឡើងឱ្យស្របនិងឆ្លើយតបនឹងក្របខ័ណ្ឌនៃសេដ្ឋកិច្ចជាតិ និងការវិវត្តនានារបស់សង្គម ហើយចាំបាច់ត្រូវវិភាគឱ្យកាន់តែស៊ីជម្រៅ និងស្វែងរកកាលានុវត្តភាពនានាដែលកើតចេញពីគម្លាតយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី នៅក្នុងបរិការណ៍ទាំងនេះ។

ជាមួយគ្នានេះ ក្រសួងកិច្ចការនារី នឹងបន្តដឹកនាំ និងសម្របសម្រួលជាមួយក្រសួង-ស្ថាប័ន និងដៃគូពាក់ព័ន្ធ រួមទាំងវិស័យឯកជន នៅក្នុងការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី រួមទាំងការលើកកម្ពស់សេដ្ឋកិច្ចគ្រួសាររបស់ស្ត្រី ការអភិវឌ្ឍសហគ្រិនភាព ការដោះស្រាយគម្លាតយេនឌ័រក្នុងការចាប់យកជំនាញ និងមុខរបរ និងការលើកកម្ពស់កម្មវិធីសេដ្ឋកិច្ចដែលគិតគូរសុខុមាលភាព។

ក្នុងបរិការណ៍នេះ នារីរតនៈទី ៦ ផ្តោតលើអាទិភាព និងវិធានការគន្លឹះ ដូចខាងក្រោម៖

១. ពង្រីកបរិយាកាសគាំទ្រ និងការវិនិយោគប្រកបដោយបរិយាបន្ន ដើម្បីបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី។

២. ការអភិវឌ្ឍសហគ្រិនភាពស្ត្រី និងគាំទ្រដល់ស្ត្រីដែលដឹកនាំនិងគ្រប់គ្រងអាជីវកម្មខ្នាតមីក្រូ តូច និងមធ្យម ប្រកបដោយនវានុវត្តន៍ ច្នៃប្រឌិត និងបរិយាបន្ន។

៣. ពង្រីកបរិយាកាសសម្រាប់ស្ត្រី តាមរយៈការដោះស្រាយគម្លាតយេនឌ័រក្នុងជំនាញ និងមុខរបរ និងការអភិវឌ្ឍជំនាញវិជ្ជាជីវៈដូនតា និងជំនាញផ្សេងៗដល់ស្ត្រី ស្របតាមតម្រូវការទីផ្សារនិងការវិវត្តរបស់សង្គម។

៤. លើកកម្ពស់សេដ្ឋកិច្ចដែលគិតគូរពីសុខុមាលភាព កម្មវិធីតុល្យភាពជីវិត គ្រួសារ និងការងារ និងបរិយាកាសមេត្រីភាពនៅកន្លែងការងារសម្រាប់ស្ត្រី នៅក្នុងសកម្មភាពសេដ្ឋកិច្ច។

៥. លើកកម្ពស់សេដ្ឋកិច្ចគ្រួសាររបស់ស្ត្រីនៅតាមសហគមន៍ តាមរយៈការទទួលបានបច្ចេកវិទ្យាឌីជីថល ការអភិវឌ្ឍអាជីវកម្ម និងបរិយាបន្នហិរញ្ញវត្ថុ។

## យុទ្ធសាស្ត្រ ទី២. ការលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារ

អាទិភាពមួយនៃយុទ្ធសាស្ត្របញ្ចកោណនៅក្នុងការអភិវឌ្ឍមូលធនមនុស្ស គឺផ្ដោតលើការពង្រឹងភាពជាពលរដ្ឋក្នុងសង្គម ដែលមានអារ្យធម៌ខ្ពស់ ប្រកបដោយសីលធម៌ សមធម៌ និងបរិយាបន្ន (មុំទី៥ បញ្ចកោណទី១ នៃយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១)។ នៅក្នុងនោះ រាជរដ្ឋាភិបាល នឹងផ្ដោតអាទិភាពលើការពង្រឹងនិងការបង្កើនកិច្ចសហការ ក្នុងការអប់រំអំពីសីលធម៌ និងសុជីវធម៌ដល់សិស្ស និស្សិត និងយុវជនទាំងក្នុងនិងក្រៅប្រព័ន្ធអប់រំ រួមទាំងការបន្តលើកកម្ពស់ការគោរពសីលធម៌ តម្លៃស្ត្រី សេចក្ដីថ្លៃថ្នូរ ក្នុងគ្រួសារ និងសង្គមខ្មែរ។ ការណ៍នេះ តាមរយៈគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ក្រសួងកិច្ចការនារី នឹងផ្ដោតលើការដឹកនាំសម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ លើការងារពហុវិស័យនេះ និងចូលរួមអប់រំផ្សព្វផ្សាយដល់សាធារណៈជន សំដៅលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ។

នៅក្នុងបរិការណ៍នេះ នារីរតនៈទី ៦ ផ្ដោតលើអាទិភាព និងវិធានការគន្លឹះ ដូចខាងក្រោម៖

១. ដឹកនាំ និងសម្របសម្រួលយន្តការអន្តរស្ថាប័ន នៅថ្នាក់ជាតិ និងក្រោមជាតិ ក្នុងលើកកម្ពស់ការអនុវត្តវិធានការពហុវិស័យ ក្នុងការបង្ការនិងទប់ស្កាត់គ្រប់ទិដ្ឋភាពអវិជ្ជមាន ដើម្បីចូលរួមលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ។

២. ជំរុញការអនុវត្តវិធានការទប់ស្កាត់ និងឆ្លើយតបរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ នៅតាមប្រព័ន្ធអនឡាញ និងតាមបច្ចេកវិទ្យាឌីជីថល។

៣. រៀបចំ និងសម្របសម្រួល ក្នុងការអនុវត្តកម្មវិធីអប់រំផ្សព្វផ្សាយ លើការលើកកម្ពស់សីលធម៌ តម្លៃស្ត្រី និងគ្រួសារខ្មែរ តាមប្រព័ន្ធទំនើប និងគ្រប់រូបភាព។

៤. លើកកម្ពស់ការអប់រំសុខុមាលភាពនៅក្នុងគ្រួសារ តាមរយៈកម្មវិធីចិញ្ចឹមកូនតាមបែបវិជ្ជមាន និងកម្មវិធីទារកដ្ឋាននៅកន្លែងធ្វើការ តាមគ្រឹះស្ថានសាធារណៈនិងឯកជន ទាំងនៅថ្នាក់ជាតិ និងក្រោមជាតិ។

## យុទ្ធសាស្ត្រទី ៣. ការលើកកម្ពស់សុខុមាលភាពរបស់ស្ត្រី និងក្មេងស្រី

រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា បានចាត់ទុកការលើកកម្ពស់សុខភាព និងសុខុមាលភាពប្រជាជន ជាអាទិភាពមួយ (មុំទី៣) នៃបញ្ចកោណទី១ ស្តីពីការអភិវឌ្ឍធនធានមនុស្ស។ នៅក្នុងនោះ ពាក់ព័ន្ធនឹងការលើកម្ពស់សុខភាពរបស់ស្ត្រីនិងក្មេងស្រី និងការលើកកម្ពស់សមភាពយេនឌ័រ **យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១** ក្នុងមុំទី១នៃបញ្ចកោណទី៤ ស្តីពីការអភិវឌ្ឍប្រកបដោយភាពធន់ ចីរភាព និងបរិយាបន្ន ក៏បាន ចង្អុលបង្ហាញឱ្យបន្តពង្រឹងនិងពង្រីកវិសាលភាពសុខភាពបន្តពូជ និងសុខភាពផ្លូវភេទរបស់យុវវ័យ ជាពិសេសស្ត្រីនិងក្មេងស្រី បន្តអនុវត្តកម្មវិធីគាំពារសង្គមដល់ស្ត្រីមានផ្ទៃពោះនិងកុមារនៃគ្រួសារក្រីក្រ និងការបន្តលើកកម្ពស់អាហារូបត្ថម្ភដល់ស្ត្រីមានផ្ទៃពោះនិងកុមារ។ ការណ៍នេះ ក្រសួងកិច្ចការនារី បន្តដើរតួនាទីក្នុងការចូលរួមបញ្ជ្រាបយេនឌ័រនៅក្នុងវិស័យពាក់ព័ន្ធនឹងសុខភាព និងសុខុមាលភាពប្រជាជន ដោយរួមចំណែកក្នុងការបង្កើនភាពអង់អាចដល់ស្ត្រីនិងក្មេងស្រី អំពីការយល់ដឹងនិងការប្រតិបត្តិត្រឹមត្រូវ ក្នុងការបង្ការ និងគ្រប់គ្រងជំងឺ ឬបញ្ហាសុខភាពសាធារណៈ អាហារូបត្ថម្ភ ព្រមទាំងការស្វែងរកនិងការប្រើប្រាស់សេវាថែទាំសុខភាពបានត្រឹមត្រូវ។

ជាមួយគ្នានេះ ក្នុងនាមសមាជិករបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម ក្រសួងកិច្ចការនារីនឹងបន្តចូលរួមផ្តល់ធាតុចូល និងចូលរួមចំណែកសម្របសម្រួលការអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈទី៦ ក្នុងការឈានទៅសម្រេចគោលដៅរួមរបស់កម្មវិធីជាតិ ក៏ដូចជាការពង្រីកការគ្របដណ្តប់នៃសេវាថែទាំសុខភាពដល់ស្ត្រីនិងក្រុមជនងាយរងគ្រោះប្រកបដោយបរិយាបន្ន។

ក្នុងបរិការណ៍នេះ នារីរតនៈទី ៦ នឹងផ្តោតលើអាទិភាព និងវិធានការគន្លឹះដូចខាងក្រោម៖

១. ធ្វើបរិវត្តកម្មយេនឌ័រនៅក្នុងវិស័យសុខាភិបាល រួមមានគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងកម្មវិធីនានា ដូចជាកម្មវិធីសុខភាពបន្តពូជ សុខភាពមាតា-ទារក សុខភាពផ្លូវចិត្ត សុខភាពភ្នែក អាហារូបត្ថម្ភ សន្តិសុខស្បៀង ជំងឺឆ្លងនិងជំងឺមិនឆ្លង គ្រឿងញៀន និងគ្រឿងស្រវឹង។

២. លើកកម្ពស់ការយល់ដឹងជាសាធារណៈស្តីពីយេនឌ័រនិងសុខភាព និងបង្កើនភាពអង់អាចដល់ស្ត្រី ក្មេងស្រី ទៅទទួលយកសេវាសុខភាពប្រកបដោយគុណភាព។

៣. អភិវឌ្ឍសមត្ថភាពមន្ត្រីនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ក្នុងការទទួលខុសត្រូវលើការងារអប់រំផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីយេនឌ័រនិងសុខភាព។

៤. ចូលរួមក្នុងលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី នៅក្នុងដំណើររៀបចំ និងអនុវត្តក្របខ័ណ្ឌកិច្ចគាំពារសង្គម។

## យុទ្ធសាស្ត្រទី ៤៖ កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រីនិងក្មេងស្រី

អំពើហិង្សាលើស្ត្រី គឺជាការរំលោភសិទ្ធិស្ត្រីដែលជាសិទ្ធិមនុស្ស និងបានបង្កឧបសគ្គដ៏ចម្បងរារាំងដល់ការចូលរួមរបស់ស្ត្រីក្នុងកិច្ចអភិវឌ្ឍន៍ជាតិ ដែលប្រការនេះផ្តល់ផលប៉ះពាល់ជាអវិជ្ជមានយូរអង្វែងផ្នែករាងកាយ ប្រាជ្ញាស្មារតី សុខភាពផ្លូវចិត្ត ផ្លូវភេទ និងសុខភាពបន្តពូជរបស់ស្ត្រីរងគ្រោះនិងកូនៗផងដែរ។ ផលវិបាកទាំងនេះ បានដាក់បន្ទុកផ្នែកសេដ្ឋកិច្ច និងសង្គមយ៉ាងធ្ងន់ធ្ងរដល់គ្រួសារ សហគមន៍ និងសង្គម។ ការណ៍នេះ ការលុបបំបាត់អំពើហិង្សាលើស្ត្រី នៅតែបន្តជាកិច្ចការអាទិភាពចម្បងនៅក្នុងរបៀបវារៈនៃការអភិវឌ្ឍមូលធនមនុស្ស និងភាពសុខដុមរមនាក្នុងគ្រួសារ ក៏ដូចជាសង្គមជាតិ។

ក្នុងន័យនេះ ក្រសួងកិច្ចការនារី បន្តដឹកនាំ និងសម្របសម្រួលជាមួយក្រសួង-ស្ថាប័ន ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល ប្រព័ន្ធផ្សព្វផ្សាយ និងផ្នែកឯកជន ក្នុងការតាក់តែងនិងអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី លើកទី៤ ២០២៤-២០៣០។ ការទប់ស្កាត់និងឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រ រួមទាំងការបំពារបំពាននិងការកេងប្រវ័ញ្ចផ្លូវភេទ អំពើជួញដូរមនុស្ស ជាពិសេសលើស្ត្រីនិងកុមារ ជាកិច្ចការដ៏ចាំបាច់សំដៅលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីនិងក្មេងស្រី ដើម្បីធានាថា ការលើកកម្ពស់ និងការពារសិទ្ធិរបស់ពួកគេ។

ក្នុងបរិការណ៍នេះ នារីរតនៈទី ៦ នឹងផ្តោតលើអាទិភាពនិងវិធានការគន្លឹះ ដូចខាងក្រោម៖

១. បញ្ជ្រាបយេនឌ័រ នៅក្នុងដំណើរការតាក់តែង និងអនុវត្តច្បាប់និងកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។

២. រៀបចំនិងជំរុញការអនុវត្តក្របខ័ណ្ឌច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធនឹងការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងអំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងក្មេងស្រី។

៣. រៀបចំ សម្របសម្រួល គាំទ្រ និងជំរុញការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ២០២៤-២០៣០ និងផែនការថ្នាក់ជាតិ តំបន់ អនុតំបន់ពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការរំលោភបំពាន អំពើធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចនានានិងការប្រើប្រាស់គ្រឿងញៀន និងយន្តការឆ្លើយតបសេវាពហុវិស័យជួយជនរងគ្រោះនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងពិនិត្យតាមដាន និងវាយតម្លៃឱ្យមានប្រសិទ្ធភាព។

៤. ពង្រឹងនិងពង្រីកការអនុវត្តកម្មវិធីពង្រឹងសមត្ថភាព និងយុទ្ធនាការបង្ការទប់ស្កាត់អំពើហិង្សាលើស្ត្រីនិងក្មេងស្រី និងកម្មវិធីតាមប្រព័ន្ធឌីជីថលដើម្បីទប់ស្កាត់និងឆ្លើយតបសេវាជួយជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

៥. រៀបចំ សម្របសម្រួល គាំទ្រ និងជំរុញការអនុវត្តផែនការសកម្មភាពជាតិស្តីពីការបង្ការទប់ស្កាត់អាពាហ៍ពិពាហ៍វ័យកុមារ និងការមានផ្ទៃពោះវ័យជំទង់ និងពិនិត្យតាមដាន និងវាយតម្លៃ។

## យុទ្ធសាស្ត្រ ទី៥៖ ស្ត្រី ក្នុងភាពជាអ្នកដឹកនាំ និងអភិបាលកិច្ច

រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា នឹងបន្តលើកកម្ពស់ការវិនិយោគលើសមភាពយេនឌ័រនិងបង្កើនភាពអង់អាចដល់ស្ត្រីនិងក្មេងស្រី នៅក្នុងការដឹកនាំសាធារណៈ ដែលជាផ្នែកសំខាន់មួយ ក្នុងការលើកកម្ពស់ការអភិវឌ្ឍប្រកបដោយភាពធន់ ចីរភាព និងបរិយាបន្ន (ស្រង់ចេញពីមុំទី១បញ្ចកោណទី៤ នៃយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១)។

អភិបាលកិច្ចល្អ គឺជាតួអង្គស្នូលក្នុងការធានាថាសមភាពយេនឌ័រ ជាតម្លៃ និងកិច្ចការរបស់យើងទាំងអស់គ្នា។ អភិបាលកិច្ចល្អ និងភាពជាអ្នកដឹកនាំប្រកបដោយបរិយាប័ន្ន សំដៅលើកិច្ចការដែលចាត់ទុកការពង្រឹងសមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី ជាអភិក្រមដ៏ចាំបាច់ ក្នុងការបង្កើនប្រសិទ្ធភាពនិងគណនេយ្យភាពរបស់អ្នកដឹកនាំនិងគ្រប់តួអង្គដែលពាក់ព័ន្ធ។ ជាមួយគ្នានេះ ការពង្រឹង និងពង្រីកភាពជាអ្នកដឹកនាំរបស់ស្ត្រីនិងក្មេងស្រីនៅគ្រប់កម្រិត នៅក្នុងវិស័យដែលនៅមានគម្លាតខ្ពស់ គឺជាកិច្ចការអាទិភាពដើម្បីធានាថាប្រជាជនគ្រប់រូបមានសិទ្ធិ និងឱកាសពេញលេញ ក្នុងការទទួលបានជម្រើស ឬមានជម្រើសនិងទទួលបានតំណាងដែលគាត់ចង់បាន ឬមានភាពជាតំណាងប្រកបដោយសក្តានុពល ចូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិប្រកបដោយចីរភាព និងបរិយាប័ន្ន។

ក្រសួងកិច្ចការនារី នឹងបន្តសម្របសម្រួលក្នុងការអនុវត្តកម្មវិធីនិងគំនិតផ្តួចផ្តើមនានា ក្នុងការលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ស្ត្រី រួមទាំងស្ត្រីវ័យក្មេងនិងក្មេងស្រី លើកកម្ពស់ការបញ្ជ្រាបយេនឌ័រនៅក្នុងកម្មវិធីកែទម្រង់និងការពង្រឹងអភិបាលកិច្ច ព្រមទាំងបន្តដំណើរការក្រុមការងារបច្ចេកទេស ស្តីពីស្ត្រីក្នុងភាពជាអ្នកដឹកនាំនិងអភិបាលកិច្ច ដែលជាយន្តការបច្ចេកទេសក្នុងការលើកកម្ពស់ការចូលរួម និងទទួលខុសត្រូវរួមលើការលើកកម្ពស់តួនាទីរបស់ស្ត្រី នៅក្នុងភាពជាអ្នកដឹកនាំ និងអភិបាលកិច្ច។

ក្នុងបរិការណ៍នេះ **នារីរតនៈទី ៦** ផ្តោតលើអាទិភាព និងវិធានការគន្លឹះ ដូចខាងក្រោម៖

១. ពង្រឹងការគាំទ្រផ្នែកគោលនយោបាយ យន្តការគាំទ្រ និងបរិយាកាសនៅកន្លែងធ្វើការ ក្នុងការលើកកម្ពស់ការចូលរួមរបស់ស្ត្រីជាថ្នាក់ដឹកនាំ និងអភិបាលកិច្ចគ្រប់កម្រិត។

២. ពង្រីកកម្មវិធីអភិវឌ្ឍភាពជាអ្នកដឹកនាំនិងបណ្តាញរបស់ស្ត្រី នៅក្នុងវិស័យសាធារណៈ និងនយោបាយ។

៣. បង្កើនការយល់ដឹង និងការគាំទ្រជាសាធារណៈ លើភាពជាអ្នកដឹកនាំរបស់ស្ត្រី និងក្មេងស្រីនៅគ្រប់កម្រិត។

៤. លើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ក្មេងស្រី តាមរយៈការអនុវត្តកម្មវិធី និងការផ្តួចផ្តើមថ្មីៗនៅតាមគ្រឹះស្ថានសិក្សា និងនៅសហគមន៍។

## យុទ្ធសាស្ត្រ ទី៦៖ ស្ត្រី និងការប្រែប្រួលអាកាសធាតុ

ការជំរុញភាពធន់នឹងការប្រែប្រួលអាកាសធាតុនិងការអភិវឌ្ឍបៃតង ត្រូវបានចាត់ទុកជាអាទិភាពក្នុងរបៀបវារៈដ៏ចម្បងមួយរបស់រាជរដ្ឋាភិបាលកម្ពុជា។ ការចូលរួមរបស់ស្ត្រីនិងក្មេងស្រី ដែលអាចក្លាយទៅជាភ្នាក់ងារនៃការផ្លាស់ប្តូរ តាមរយៈតួនាទីរបស់ស្ត្រីក្នុងការអប់រំគ្រួសារ សហគមន៍ និងផ្លាស់ប្តូរទស្សនៈរបស់សង្គម។ ក្នុងន័យនេះ ភាពចាំបាច់ក្នុងការបញ្ជ្រាបយេនឌ័រទៅក្នុងវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ រួមទាំងគោលនយោបាយ ច្បាប់ និងផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ តាមវិស័យ ដើម្បីឱ្យកិច្ចការអន្តរវិស័យនេះ ត្រូវការការគាំទ្រនិងចូលរួមពីស្ថាប័ននិងដៃគូពាក់ព័ន្ធ។ ជាមួយគ្នានេះ យើងក៏ចាំបាច់ត្រូវបន្តស្វែងរកលទ្ធភាពនានា ដើម្បីជំរុញនិងលើកកម្ពស់តួនាទីស្ត្រី នៅក្នុងសកម្មភាពសេដ្ឋកិច្ចបៃតង កសិឧស្សាហកម្មបៃតង និងអេកូទេសចរណ៍ ដើម្បីចូលរួមលើកកម្ពស់សេដ្ឋកិច្ចគ្រួសារផង និងឆ្លើយតបនឹងប្រែប្រួលអាកាសធាតុនិងការអភិវឌ្ឍបៃតងផង។ ក្រសួងកិច្ចការនារី បន្តពង្រឹងឯកទេសបច្ចេកទេស ក្នុងការចូលរួមនៅក្នុងរបៀបវារៈរបស់កម្មវិធីអភិវឌ្ឍន៍ដោយចីរភាព និងជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ តាមរយៈបន្តអនុវត្តផែនការមេស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ ឆ្នាំ២០១៨-២០៣០ និងនិងលើកកម្ពស់តួនាទីរបស់ស្ត្រី នៅក្នុងការប្រែប្រួលអាកាសធាតុ និងវិស័យពាក់ព័ន្ធ។

ក្នុងមូលដ្ឋាននេះ នារីរតនៈទី៦ ផ្តោតអាទិភាព និងវិធានការគន្លឹះ ដូចខាងក្រោម៖

១. ពង្រឹងសមត្ថភាពបច្ចេកទេស និងការគាំទ្រពីថ្នាក់ដឹកនាំនិងមន្ត្រីពាក់ព័ន្ធ ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ ការកសាងសមត្ថភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ។

២. បន្តបញ្ជ្រាបយេនឌ័រក្នុងដំណើរការតាក់តែងនិងអនុវត្តគោលនយោបាយ កម្មវិធី និងផែនការយុទ្ធសាស្ត្រពាក់ព័ន្ធការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ រួមទាំង តំបន់ជុំវិញទន្លេសាប និងទន្លេមេគង្គ

៣. គាំទ្រ និងបង្កើតគំនិត ផ្តួចផ្តើមក្នុងការលើកកម្ពស់តួនាទីស្ត្រី និងការឆ្លើយតបតម្រូវការស្ត្រី និងក្រុមស្ត្រីនិងក្មេងស្រីដែលងាយរងគ្រោះ ក្នុងកម្មវិធីប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ រួមទាំងក្នុងក្របខ័ណ្ឌកិច្ចគាំពារសង្គម ដើម្បីឆ្លើយតបនឹងគ្រោះអាសន្ន។

៤. រៀបចំកម្មវិធីគ្រប់គ្រង និងចែករំលែកព័ត៌មាន ស្តីពីផលប៉ះពាល់យេនឌ័រ ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។

## យុទ្ធសាស្ត្រគាំទ្រស្ថាប័ន៖ ការពង្រឹងប្រសិទ្ធភាព និងអភិវឌ្ឍសមិទ្ធកម្មស្ថាប័ន

នៅក្នុងនីតិកាលទី៧នៃរដ្ឋសភា រាជរដ្ឋាភិបាល នឹងផ្តោតអាទិភាពលើការកែទម្រង់ និងការពង្រឹងអភិបាលកិច្ច និងការធ្វើទំនើបកម្មស្ថាប័នរដ្ឋ ឱ្យក្លាយជារដ្ឋបាលសាធារណៈទំនើបប្រកបដោយសមត្ថភាពខ្ពស់ ខ្លាំង វៃឆ្លាត និងស្អាតស្អំ ដើម្បីបម្រើផលប្រយោជន៍ជូនប្រជាជន។

ភាពចាំបាច់ និងកត្តាជោគជ័យនៃការអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈទី៦ អាស្រ័យលើភាពខ្លាំងរឹងមាំ និងប្រសិទ្ធភាពការងាររបស់ក្រសួងនិងមន្ទីរកិច្ចការនារី។ ការណ៍នេះ កម្មវិធីអភិវឌ្ឍសមត្ថភាពនិងសមិទ្ធកម្មស្ថាប័ន ត្រូវធ្វើឡើងដោយឆ្លុះបញ្ចាំង និងឆ្លើយតបនឹងការប្រែប្រួលយ៉ាងឆាប់រហ័សនៃការវិវត្ត និងបរិបទថ្មីៗរបស់សកលលោក និងនៅក្នុងប្រទេស ក៏ដូចជាការឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្ម ទី៤ និងការធ្វើឌីជីថលភាវូនីយកម្ម។ ផ្អែកលើយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ក្រសួងក៏កំពុងពិនិត្យនិងកែសម្រួលរចនាសម្ព័ន្ធ ធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ ឱ្យស្របនិងឆ្លើយតបនឹងការវិវត្តរបស់សង្គម។ ក្រសួងនឹងពង្រឹងសមិទ្ធកម្មរបស់ស្ថាប័ននិងប្រសិទ្ធភាព ក្នុងការពិនិត្យតាមដាននិងវាយតម្លៃលើការអនុវត្តការងារ និងរៀបចំអង្គភាពបរិវត្តកម្មឌីជីថលក្នុងស្ថាប័ន ព្រមទាំងពង្រឹងយន្តការគ្រប់គ្រងនិងផ្សព្វផ្សាយព័ត៌មានឱ្យរស់រវើកឆ្លើយតបនឹងតម្រូវការរបស់សង្គម។

ជាមួយគ្នានេះ ការលើកកម្ពស់ការឆ្លើយតបប្រកបដោយបរិយាបន្ននិងសមធម៌ ដល់ស្ត្រីនិងក្មេងស្រីដែលស្ថិតនៅក្នុងក្រុមជនងាយរងគ្រោះនៅក្នុងសង្គម ជាកិច្ចការអន្តរវិស័យរបស់ក្រសួង និងអង្គភាពចំណុះដែលជំរុញឱ្យបញ្ជ្រាប និងមានចាត់វិធានការឆ្លើយតបជាក់លាក់នៅតាមអង្គភាព និងយុទ្ធសាស្ត្រនីមួយៗព្រមទាំងលើកទឹកចិត្ត គិតគូរ និងជំរុញឱ្យមានវិធានការប្រកបដោយសមធម៌ នៅក្នុងការអនុវត្តសកម្មភាពប្រចាំថ្ងៃរបស់ក្រសួង។

ក្នុងមូលដ្ឋាននេះ នារីរតនៈទី៦ ផ្តោតអាទិភាព និងវិធានការគន្លឹះ ដូចខាងក្រោម៖

១. អនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ និងប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានក្នុងរដ្ឋបាលសាធារណៈ ការអភិវឌ្ឍធនធានមនុស្ស និងនវានុវត្តន៍ ដើម្បីលើកកម្ពស់គុណភាពការងារប្រកបដោយវិន័យ សីលធម៌វិជ្ជាជីវៈ ប្រសិទ្ធភាព និងសក្ដិសិទ្ធភាព។

២. អនុវត្តកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ក្នុងការពង្រឹងប្រសិទ្ធភាពការងារស្ថាប័ន។

៣. អនុវត្តកម្មវិធីវិមជ្ឈការនិងវិសហមជ្ឈការ ក្នុងការលើកកម្ពស់មុខងារនិងសេវាសាធារណៈរបស់ក្រសួងនៅថ្នាក់ក្រោមជាតិ។

៤. ពង្រីកការអនុវត្តកម្មវិធីតុល្យភាពជីវិត គ្រួសារ និងការងារ និងបរិយាកាសមេត្រីភាពឆ្លើយតបនឹងយេនឌ័រនៅកន្លែងការងារ ក្នុងស្ថាប័ន និងអង្គភាពចំណុះ។

៥. ពង្រឹងប្រព័ន្ធរៀបចំផែនការ ស្ថិតិ តាមដានត្រួតពិនិត្យ និងវាយតម្លៃ ។

៦. ពង្រឹងសមត្ថភាព និងប្រសិទ្ធភាព ក្នុងការអនុវត្តយន្តការនៅថ្នាក់ជាតិនិងក្រោមជាតិ ក្នុងការប្រាស្រ័យទាក់ទងនិងទំនាក់ទំនងសាធារណៈ និងប្រព័ន្ធព័ត៌មានផ្សព្វផ្សាយរបស់ក្រសួងកិច្ចការនារី តាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថល និងស្របតាមបរិបទសង្គម។

៧. រៀបចំ និងសម្របសម្រួលផែនការសកម្មភាពជាតិ ស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខ ព្រមទាំងពង្រឹងយន្តការក្នុងការពង្រីកកិច្ចសហប្រតិបត្តិការថ្នាក់ជាតិ ថ្នាក់តំបន់ សកល និងភាពជាដៃគូជាមួយនឹងក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ដើម្បីលើកកម្ពស់និងការពារសិទ្ធិស្ត្រី និងកុមារ។

៨. ពង្រឹងសមត្ថភាព និងប្រសិទ្ធភាពស្ថាប័ន ក្នុងការឆ្លើយតបប្រកបដោយបរិយាបន្ន និងសមធម៌ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈទី៦ ដោយមិនទុកអ្នកណាម្នាក់ឱ្យនៅឯកា។

៩. ធ្វើស្ថាប័នីយកម្មឌីជីថល នៅក្នុងក្របខណ្ឌស្ថាប័ននៅថ្នាក់ជាតិ និងក្រោមជាតិ រួមទាំងការគាំទ្រស្ថាប័ន ក្នុងការធ្វើទំនើបកម្មផ្នែកឌីជីថល នៅក្នុងការអនុវត្តការងារប្រចាំថ្ងៃ និងបំពេញសេវាជាសាធារណៈ។

# ផ្នែកទី៥៖ សកម្មភាពការងារ

## យុទ្ធសាស្ត្រស្នូល៖ ក្របខណ្ឌបញ្ជ្រាបយេនឌ័រ

គោលបំណង៖ ពង្រឹង និងពង្រីកវិសាលភាពក្នុងការបញ្ជ្រាបយេនឌ័រ តាមរយៈការធ្វើបរិវត្តកម្មយេនឌ័រ ក្នុងក្របខណ្ឌច្បាប់ គោលនយោបាយ និងកម្មវិធីជាតិ និងការផ្លាស់ប្តូរឥរិយាបថជាសាធារណៈដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី និងក្មេងស្រី។

| វិធានការគន្លឹះ | សូចនាករសមិទ្ធកម្មគន្លឹះ | សកម្មភាពគន្លឹះ | ដៃគូពាក់ព័ន្ធ | ពេលវេលា (២០២៤-២០២៨) | | | | | ធនធាន | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ២៤ | ២៥ | ២៦ | ២៧ | ២៨ | ជាតិ | ដៃគូ |
| ១. ពង្រីកកម្មវិធីសិក្សាស្រាវជ្រាវ អំពីស្ថានភាពយេនឌ័រ នៅតាមវិស័យ និងថ្មីៗ ដែលស្របតាមការវិវត្តរបស់សង្គម និងរៀបចំគំនិតផ្តួចផ្តើមលើវិធានការ និងកម្មវិធីឆ្លើយតប | ក្របខណ្ឌបង្ហាញផ្លូវនៃការសិក្សាស្រាវជ្រាវអំពីស្ថានភាពយេនឌ័រតាមវិស័យ ដែលបានរៀបចំ | រៀបចំក្របខណ្ឌបង្ហាញផ្លូវ ក្នុងការសិក្សាស្រាវជ្រាវ អំពីស្ថានភាពយេនឌ័រ តាមវិស័យ និងថ្មីៗ ដែលស្របតាមការវិវត្តរបស់សង្គម | ក្រសួងកិច្ចការនារី<br>ក្រសួង-ស្ថាប័ន<br>ស្ថាប័នស្រាវជ្រាវ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | **ចំនួនប្រធានបទ និងការសិក្សាស្រាវជ្រាវ និងរបាយការណ៍អំពីស្ថានភាពយេនឌ័រតាមវិស័យ** (ប្រចាំឆ្នាំនីមួយៗ និងក្នុងរយៈពេល ៥ឆ្នាំ) | សិក្សាស្រាវជ្រាវ អំពីស្ថានភាពយេនឌ័រតាមវិស័យ និងថ្មីៗ ដែលស្របតាមការវិវត្តរបស់សង្គម តាមរយៈកិច្ចសហការជាមួយក្រសួង-ស្ថាប័ន វិទ្យាស្ថានស្រាវជ្រាវ និងដៃគូពាក់ព័ន្ធ | ក្រសួងកិច្ចការនារី<br>ក្រសួង-ស្ថាប័ន<br>ដៃគូអភិវឌ្ឍ<br>សង្គមស៊ីវិល<br>វិស័យឯកជន<br>ស្ថាប័នស្រាវជ្រាវ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | ចំនួនរបាយការណ៍មេរៀនបទពិសោធន៍ និងឧត្តមានុវត្តន៍ក្នុងការបញ្ជ្រាបយេនឌ័រនៅកម្ពុជា ដែលបានចងក្រង | ចងក្រងមេរៀនបទពិសោធន៍ និងឧត្តមានុវត្តន៍ លើការអនុវត្តការងារបញ្ជ្រាបយេនឌ័រនៅ ក្នុងក្របខណ្ឌគោលនយោបាយ កម្មវិធី និងតាមវិស័យ ព្រមទាំងចែករំលែកនិងផ្លាស់ប្តូរមេរៀនបទពិសោធន៍ | ក្រសួងកិច្ចការនារី<br>ក្រសួង-ស្ថាប័ន<br>ដៃគូអភិវឌ្ឍ<br>សង្គមស៊ីវិល<br>វិស័យឯកជន | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | **ចំនួនកម្មវិធីផ្សព្វផ្សាយ និងកិច្ចសន្ទនាកម្រិតគោលនយោបាយ** លើរបកគំហើញ នៃការសិក្សាស្រាវជ្រាវពីស្ថានភាពយេនឌ័រតាមវិស័យ | រៀបចំកម្មវិធីផ្សព្វផ្សាយ និងកម្មវិធីកិច្ចសន្ទនាកម្រិតគោលនយោបាយ លើរបកគំហើញ នៃការសិក្សាស្រាវជ្រាវពីស្ថានភាពយេនឌ័រតាមវិស័យ ដើម្បីជាមូលដ្ឋាន ក្នុងការតាក់តែងគោលនយោបាយ រៀបចំកម្មវិធីលិខិតបទដ្ឋានគតិយុត្តិនិងវិធានការឆ្លើយតប | ក្រសួងកិច្ចការនារី ក្រសួង-ស្ថាប័ន ដៃគូអភិវឌ្ឍ សង្គមស៊ីវិល វិស័យឯកជន | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | **ចំនួនគោលនយោបាយ និងវិធានការតាមវិស័យ និងរបស់ក្រសួង-ស្ថាប័ន ដែលបានឆ្លើយតបយេនឌ័រ** ស្របតាមរបកគំហើញ ក្នុងការសិក្សាស្រាវជ្រាវ ស្តីពីស្ថានភាពយេនឌ័រតាមវិស័យ | ដឹកនាំសម្របសម្រួល និងជំរុញការឆ្លើយតប និងការដាក់ចេញនូវវិធានការគោលនយោបាយ កម្មវិធី និងលិខិតបទដ្ឋានគតិយុត្តិ ស្របតាមរបកគំហើញនៃការសិក្សាស្រាវជ្រាវអំពីស្ថានភាពយេនឌ័រ តាមវិស័យ | ក្រសួងកិច្ចការនារី ក្រសួង-ស្ថាប័ន ដៃគូអភិវឌ្ឍ សង្គមស៊ីវិល វិស័យឯកជន | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | **អង្កេតប្រជាសាស្ត្រនិងសុខភាពប្រជាជននៅកម្ពុជា និងរបាយការណ៍សិក្សាស្រាវជ្រាវនិងអង្កេតនានា ដែលបានដាក់បញ្ចូលយេនឌ័រ** | បញ្ជ្រាបយេនឌ័រទៅក្នុងបញ្ជីសំណួរនៃការអង្កេតប្រជាសាស្ត្រ និងសុខភាពប្រជាជននៅកម្ពុជា និងកម្មវិធីរបស់វិទ្យាស្ថានជាតិស្ថិតិ<br>រៀបចំការវិភាគលទ្ធផលនៃការអង្កេតប្រជាសាស្ត្រ និងសុខភាពប្រជាជននៅកម្ពុជា ជំពូកអំពើហិង្សាក្នុងគ្រួសារ | ក្រសួងកិច្ចការនារី វិទ្យាស្ថានជាតិស្ថិតិ អង្គការដៃគូពាក់ព័ន្ធ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | របាយការណ៍សិក្សាស្រាវជ្រាវ និងវិភាគលើកត្តាគ្រោះថ្នាក់នានានិងទំហំនៃការ | វិភាគលើទិន្នន័យដែលមានស្រាប់ ដើម្បីកំណត់រកកត្តាគ្រោះថ្នាក់ និងទំហំនៃការខាតបង់ផ្នែកសេដ្ឋកិច្ច | ក្រសួងកិច្ចការនារី ក្រសួង-ស្ថាប័ន ថ្នាក់ក្រោមជាតិ | | ✓ | | | | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ខាតបង់ផ្នែកសេដ្ឋកិច្ចដែលបណ្តាលមកពីករណីអំពើហិង្សាទាក់ទងយេនឌ័រ | ដែលបណ្តាលមកពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ | ដៃគូអភិវឌ្ឍន៍<br>អង្គការសង្គមស៊ីវិល | | | | | | | |
| ២. ពង្រឹង និងពង្រីកបញ្ជ្រាបយេនឌ័រ នៅក្នុងដំណើរការរៀបចំ និងអនុវត្តគោលនយោបាយ និងកម្មវិធីតាមវិស័យ រួមទាំងវិស័យអប់រំ យុវជន កីឡា ពិការភាព និងឌីជីថល។ | **ចំនួនរបាយការណ៍សិក្សាស្រាវជ្រាវ អំពីស្ថានភាពនិងនិងសេចក្តីស្នើគោលនយោបាយពាក់ព័ន្ធនឹងយេនឌ័រ** នៅក្នុងវិស័យអប់រំ យុវជន កីឡា ពិការភាព បច្ចេកវិទ្យាឌីជីថល និងវិទ្យាសាស្ត្របានរៀបចំ<br><br>**ចំនួនគោលនយោបាយ និងកម្មវិធីជាតិពាក់ព័ន្ធវិស័យខាងលើបានឆ្លើយតបនឹង**យេនឌ័រ តាមរយៈជាតុចូលពីក្រសួងកិច្ចការនារី<br><br>**ចំនួនកម្មវិធី និងវិធានការជាក់លាក់នានា ក្នុងការកាត់បន្ថយគម្លាតយេនឌ័រ** នៅក្នុងវិស័យអាទិភាពខាងលើក្រោមការដឹកនាំការអនុវត្តដោយក្រសួងកិច្ចការនារី | សិក្សាស្រាវជ្រាវ អំពីស្ថានភាព និងបញ្ហាថ្មីៗពាក់ព័ន្ធស្ថានភាពស្ត្រី និងគម្លាតយេនឌ័រ នៅក្នុងវិស័យអប់រំ យុវជន កីឡា ពិការភាព បច្ចេកវិទ្យាឌីជីថល និងវិទ្យាសាស្ត្រ (ដាក់បញ្ចូលជាកិច្ចការអាទិភាព ក្នុងវិធានការគន្លឹះទី១ ខាងលើ)<br><br>រៀបចំឯកសារអនុសាសន៍ និងសេចក្តីស្នើសម្រាប់ការរៀបចំគោលនយោបាយ ស្តីពីយេនឌ័រនិងរៀបចំក្រុមការងារ និងអ្នកទទួលបន្ទុកច្បាស់លាស់ ដើម្បីធ្វើឱ្យមានឥទ្ធិពល និងឆ្លើយតបយេនឌ័រក្នុងវិស័យពាក់ព័ន្ធខាងលើ<br><br>សិក្សាស្រាវជ្រាវ និងកំណត់រកវិធានការឆ្លើយតបជាក់លាក់ ដើម្បីដោះស្រាយគម្លាតយេនឌ័រក្នុងវិស័យឌីជីថល ជាពិសេសបង្កើនការចូលរួមរបស់ស្ត្រី និងក្មេងស្រីក្នុងវិស័យឌីជីថល ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងការអប់រំចំណេះដឹងនិងជំនាញ ផ្នែក | ក្រសួងកិច្ចការនារី<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ<br>ដៃគូអភិវឌ្ឍន៍<br><br>អង្គការសង្គមស៊ីវិល | | √ | | | | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈច្នៃប្រឌិត និងគណិតវិទ្យា | | | | | | | | |
| ៣. រៀបចំ និងអនុវត្ត គោលនយោបាយ កម្មវិធី និងអភិក្រម ក្នុងការធ្វើបរិវត្តកម្មយេនឌ័រ និងពង្រឹងយន្តការ បញ្ជ្រាបយេនឌ័រ នៅគ្រប់កម្រិត | **គោលនយោបាយជាតិ ស្តីពីសមភាពយេនឌ័រ ឆ្នាំ ២០២៤-២០៣៤** ត្រូវបាន អនុម័ត ដោយរាជរដ្ឋាភិបាល និងផ្សព្វផ្សាយ | បញ្ចប់សេចក្តីព្រាងគោលនយោ-បាយជាតិ ស្តីពីសមភាពយេនឌ័រ ឆ្នាំ២០២៤-២០៣៤ និងរបាយ-ការណ៍ជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងអនុម័ត (គោលនយោបាយនេះ នឹងមានបញ្ចូលនូវអភិក្រមធ្វើបរិវត្តកម្មយេនឌ័រ)<br>រៀបចំ និងអនុវត្តកម្មវិធីផ្សព្វផ្សាយគោលនយោបាយជាតិ ស្តីពីសមភាពយេនឌ័រ | ក្រសួងកិច្ចការនារី<br>ទីស្តីការគណៈ-រដ្ឋមន្ត្រី | ✓ | ✓ | | | | ✓ | ✓ |
| | **កម្មវិធី ស្តីពីការធ្វើស្ថាបនូប-នីយកម្មយេនឌ័រ** និងកម្មវិធីថវិកាឆ្លើយតបនឹងយេនឌ័រ បានរៀបចំ និងផ្សព្វផ្សាយ | រៀបចំកម្មវិធី ស្តីពីការធ្វើស្ថាបនូប-នីយកម្មយេនឌ័រ និងកម្មវិធីថវិកាឆ្លើយតបយេនឌ័រ (ដែលបញ្ជាក់ពីចក្ខុវិស័យ លទ្ធផលរំពឹងទុក និងអភិក្រមក្នុងការធ្វើបរិវត្តកម្មយេនឌ័រនៅតាមវិស័យ) | ក្រសួងកិច្ចការនារី<br>ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>ក្រសួង-ស្ថាប័នដៃគូអភិវឌ្ឍ | ✓ | ✓ | | | | ✓ | ✓ |
| | **កញ្ចប់ឯកសារបណ្តុះបណ្តាល និងឧបករណ៍ ស្តីពីការបញ្ជ្រាបយេនឌ័រ ការរៀបចំថវិកាឆ្លើយតបនឹងយេនឌ័រ និងការធ្វើបរិវត្តកម្មយេនឌ័រ** បានរៀបចំ និងធ្វើ | រៀបចំ និងធ្វើបច្ចុប្បន្នភាពកញ្ចប់ឯកសារ និងឧបករណ៍សម្រាប់ការបណ្តុះបណ្តាល (បញ្ជីមេរៀន ឯកសារគ្រូបង្គោល សម្ភារៈ បង្រៀនទាំងផ្ទាល់ និងតាមបច្ចេកវិទ្យាឌីជីថល) ស្តីពីការបញ្ជ្រាបយេនឌ័រ | ក្រសួងកិច្ចការនារី<br>ក្រសួងសេដ្ឋកិច្ច និង-ហិរញ្ញវត្ថុ<br>ក្រសួង-ស្ថាប័នដៃគូអភិវឌ្ឍ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | បច្ចុប្បន្នភាព សម្រាប់បណ្តុះបណ្តាលផ្ទាល់ និងតាមបច្ចេកវិទ្យាឌីជីថល | ការរៀបចំថវិកាឆ្លើយតបយេនឌ័រ និងការធ្វើបរិវត្តកម្មយេនឌ័រ | | | | | | | | |
| | **ចំនួនអ្នកឯកទេសយេនឌ័រ នៅក្រសួងកិច្ចការនារី និង ក្រសួង-ស្ថាប័ន ដែលបាន**ទទួលកម្មវិធីអភិវឌ្ឍសមត្ថភាព ក្នុងការធ្វើបរិវត្តកម្មយេនឌ័រតាមវិស័យ | រៀបចំកម្មវិធីអភិវឌ្ឍន៍សមត្ថភាព រួមទាំងផ្តល់វគ្គបណ្តុះបណ្តាលហ្វឹកហ្វឺន និងបំប៉នដល់ក្រុមឯកទេសយេនឌ័រ នៅក្រសួងកិច្ចការនារី ដើម្បីក្លាយជាអ្នកធ្វើបរិវត្តកម្មយេនឌ័រនៅតាមវិស័យ | ក្រសួងកិច្ចការនារី<br>ក្រសួងសេដ្ឋកិច្ច និង-ហិរញ្ញវត្ថុ<br>ក្រសួង-ស្ថាប័នដៃគូអភិវឌ្ឍ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | *(ប្រព័ន្ធគ្រប់គ្រងជាក់លាក់លើសមិទ្ធកម្មវឌ្ឍនភាព នៃកម្មវិធីអភិវឌ្ឍសមត្ថភាព និងសមិទ្ធកម្មរបស់ក្រុមអ្នកឯកទេស ត្រូវបានរៀបចំ ដើម្បីជាអំណះអំណាង ដល់សូចនាករខាងលើ)* | រៀបចំកម្មវិធីជាប្រព័ន្ធ និងមានការគ្រប់គ្រងជាក់លាក់លើសមិទ្ធកម្មក្នុងការផ្តល់វគ្គបណ្តុះបណ្តាលហ្វឹកហ្វឺន និងបំប៉នដល់គ្រូបង្គោល និងអ្នកឯកទេសយេនឌ័រ រួមទាំងរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យគ្រូបង្គោល និងអ្នកឯកទេសយេនឌ័រ នៅក្រសួង-ស្ថាប័ន ដើម្បីក្លាយ ជាអ្នកធ្វើបរិវត្តកម្មយេនឌ័រ និងអនុវត្តកម្មវិធីថវិកាឆ្លើយតបនឹងយេនឌ័រ | ក្រសួងកិច្ចការនារី<br>ក្រសួងសេដ្ឋកិច្ច និង-ហិរញ្ញវត្ថុ<br>ក្រសួង-ស្ថាប័នដៃគូអភិវឌ្ឍ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | ចំនួនក្រសួង-ស្ថាប័ន ដែលបានអភិវឌ្ឍសមត្ថភាព និងគាំទ្រក្នុងការធ្វើស្ថាបនូបនីយកម្មតាមវិស័យ និងកម្មវិធីថវិកាឆ្លើយតបនឹងយេនឌ័រ | គាំទ្រដល់ក្រសួង-ស្ថាប័នដែលជ្រើសរើស ក្នុងការរៀបចំស្ថាបនូប-នីយកម្មយេនឌ័រ និងកម្មវិធីរៀបចំថវិកាឆ្លើយតបនឹងយេនឌ័រតាមវិស័យ | ក្រសួងកិច្ចការនារី<br>ក្រសួងសេដ្ឋកិច្ច និង-ហិរញ្ញវត្ថុ<br>ក្រសួង-ស្ថាប័នដៃគូអភិវឌ្ឍ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ<br>ប្រភេទ និងចំនួនសេចក្តី**ណែនាំនិងឧបករណ៍ ក្នុងពង្រឹងយន្តការ និងការ-បញ្ជ្រាបយេនឌ័រ តាមវិស័យ** បានរៀបចំ និងផ្សព្វផ្សាយជាផ្លូវការ | រៀបចំសេចក្តីណែនាំនិងឧបករណ៍ក្នុងពង្រឹងយន្តការ និងការបញ្ជ្រាបយេនឌ័រ តាមវិស័យ និងគាំទ្រដល់ការអនុវត្ត | | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | | អភិវឌ្ឍសមត្ថភាពដល់ក្រុមការងារបញ្ជ្រាបយេនឌ័រក្រសួង-ស្ថាប័នទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អំពីការលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី | | | | | | | | |
| ៤. សម្របសម្រួល និងគាំទ្រក្រសួង-ស្ថាប័ន និងដៃគូពាក់ព័ន្ធ ក្នុងការធ្វើស្ថាប័នូបនីយកម្មយេនឌ័រ តាមវិស័យ រួមទាំងការអនុវត្តកម្មវិធីរៀបចំថវិកាឆ្លើយតបនឹងយេនឌ័រ | ចំនួនកម្មវិធី ដើម្បីពង្រឹងបណ្តាញទំនាក់ទំនង ជំរុញនិងតាមដានការអនុវត្តការងារជាមួយក្រុមការងារបញ្ជ្រាបយេនឌ័រ តាមវិស័យ និងក្រសួង-ស្ថាប័ន | រៀបចំកិច្ចប្រជុំប្រចាំឆ្នាំ និងពង្រឹងបណ្តាញក្រុមការងារបញ្ជ្រាបយេនឌ័រក្រសួង-ស្ថាប័នដើម្បីពិនិត្យវឌ្ឍនភាព បញ្ហាប្រឈម និងលើកទិសដៅបន្ត | ក្រសួងកិច្ចការនារី<br>ក្រសួង-ស្ថាប័ន<br>ដៃគូអភិវឌ្ឍ | ✓ | ✓ | ✓ | ✓ | ✓ | | |
| | ចំនួនវិធានការឆ្លើយតបនឹងការពង្រឹងនិងពង្រីកកម្មវិធីបញ្ជ្រាបយេនឌ័រ និងការធ្វើបរិវត្តកម្មយេនឌ័រ ដែលកើតចេញពីលទ្ធផលនៃកិច្ចប្រជុំក្រុមការងារបច្ចេកទេសយេនឌ័រ(TWG-G) (ស្រង់ | រៀបចំកិច្ចប្រជុំ និងជំរុញការអនុវត្តមុខងារក្រុមការងារបច្ចេកទេសយេនឌ័រ (TWG-G) ក្នុងការអនុវត្តអភិក្រមបរិវត្តកម្មយេនឌ័រ ក្នុងក្របខ័ណ្ឌដៃគូអភិវឌ្ឍ និងនៅតាមវិស័យ | ក្រសួងកិច្ចការនារី<br>ក្រសួង-ស្ថាប័ន<br>ដៃគូអភិវឌ្ឍ<br>សង្គមស៊ីវិល<br>វិស័យឯកជន | ✓ | ✓ | ✓ | ✓ | ✓ | | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | និងរាយការណ៍ ជាប្រចាំឆ្នាំ និង៥ឆ្នាំ) | | | | | | | | | |
| | ចំនួនគាំទ្របច្ចេកទេសដល់ក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ រួមទាំងប្រភេទនិងចំនួនវិធានការឆ្លើយតបនានាដែលកើតឡើង (សមិទ្ធកម្ម) | គាំទ្របច្ចេកទេសដល់ក្រសួង-ស្ថាប័ននៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ រួមទាំងការរៀបចំផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រតាមវិស័យ ដែលឆ្លើយតបនឹងគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ ក្របខ័ណ្ឌអភិក្រមបរិវត្តកម្មយេនឌ័រ និងរបកគំហើញនៃការសិក្សាស្រាវជ្រាវ (វិធានការគន្លឹះទី១ខាងលើ) | ក្រសួងកិច្ចការនារី<br>ក្រសួង-ស្ថាប័ន<br>មន្ទីរកិច្ចការនារី<br>ដៃគូអភិវឌ្ឍ<br>សង្គមស៊ីវិល | ✓ | ✓ | ✓ | ✓ | ✓ | | |
| | **ឯកសារផ្លូវការ ស្តីពីកម្មវិធីថវិកាឆ្លើយតបនឹងយេនឌ័រ** រៀបចំ និងជាផ្នែកមួយ នៅក្នុងក្របខ័ណ្ឌការងាររបស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ<br><br>**ចំនួនក្រសួង-ស្ថាប័ន ដែលបានអនុវត្តកម្មវិធីថវិកាឆ្លើយតបនឹងយេនឌ័រ** ក្នុងកម្មវិធីកែទម្រង់ការគ្រង់គ្រងហិរញ្ញវត្ថុសាធារណៈ | រៀបចំ និងអនុវត្តកម្មវិធីថវិកាឆ្លើយតបនឹងយេនឌ័រ និងចូលរួមបញ្ជ្រាបយេនឌ័រ នៅក្នុងកម្មវិធីកែការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈកិច្ចសហការនិងការទទួលបានការគាំទ្រពីអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br><br>រៀបចំកម្មវិធីនិងឯកសារអភិវឌ្ឍន៍សមត្ថភាពស្តីពីការរៀបចំថវិកាឆ្លើយបតនឹងយេនឌ័រ (ជាផ្នែកមួយ | ក្រសួងកិច្ចការនារី<br>ក្រសួងសេដ្ឋកិច្ចនិង-ហិរញ្ញវត្ថុ<br>គណៈកម្មាធិការជាតិកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ<br>ក្រសួង-ស្ថាប័ន<br>ដៃគូអភិវឌ្ឍ | ✓ | ✓ | ✓ | ✓ | ✓ | | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ឯកសារនិងកម្មវិធីអភិវឌ្ឍន៍សមត្ថភាព ក្នុងការអនុវត្តកម្មវិធីថវិកាឆ្លើយតបយេនឌ័រ បានរៀបចំ និងប្រើប្រាស់ | នៃការធ្វើបរិវត្តកម្មយេនឌ័រ ដូចមានក្នុងវិធានការគន្លឹះទី៣ខាងលើ) | | | | | | | | |
| | **ចំនួនវិធានការ កម្មវិធី និងសកម្មភាពឆ្លើយតបយេនឌ័រ ដែលបានអនុវត្តកម្មវិធីជាតិ** សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ<br><br>**ចំនួនវិធានការបញ្ជ្រាបយេនឌ័រនៅថ្នាក់ក្រោមជាតិ** ដែលបែងចែងតាមរាជធានីខេត្តនីមួយៗ<br><br>**ចំនួនគ្រូបង្គោលយេនឌ័ររបស់មន្ទីរកិច្ចការនារីរាជធានី-ខេត្ត** បានរៀបចំ និងមានសមត្ថភាព ក្នុងការអនុវត្តវិធានការ និងកម្មវិធីបញ្ជ្រាបយេនឌ័រនៅថ្នាក់ក្រោមជាតិ | អនុវត្តកម្មវិធី និងសកម្មភាព ក្នុងការបញ្ជ្រាបយេនឌ័រ ក្នុងដំណើរការអនុវត្ត តាមដាន និងវាយតម្លៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រួមទាំងកញ្ចប់សកម្មភាព នៅក្នុងកិច្ចព្រមព្រៀងប្រចាំរវាងក្រសួងកិច្ចការនារី និងលេខាធិការដ្ឋាន គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមប្រជាធិបតេយ្យនៅថ្នាក់ក្រោម ជាតិ (គ.ជ.អ.ប)<br><br>មន្ទីរកិច្ចការនារី គាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងដៃគូពាក់ព័ន្ធក្នុងការបញ្ជ្រាបយេនឌ័រនៅថ្នាក់ក្រោមជាតិ រួមទាំងប្រសិទ្ធភាពនៃការអនុវត្តមុខងាររបស់គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រីនិងកុមារ និងការអនុវត្តមុខងារកិច្ចការនារី ដែលបានផ្ទេរដល់រដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌ | ក្រសួងកិច្ចការនារី<br>លេខាធិការដ្ឋាន គ.ជ.អ.ប<br>ក្រសួង-ស្ថាប័ន<br>រដ្ឋបាលថ្នាក់ក្រោមជាតិ<br>ដៃគូអភិវឌ្ឍ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៥. ពង្រឹងប្រព័ន្ធ និងយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការបញ្ជ្រាបយេនឌ័រតាមវិស័យ | **ឧបករណ៍ត្រួតពិនិត្យ និងតាមដានការអនុវត្តគោលនយោបាយជាតិ ស្តីពីសមភាពយេនឌ័រ** និងគោលនយោបាយពាក់ព័ន្ធ រួមទាំងការអនុវត្តអនុសញ្ញាស៊ី-ដ<br><br>របាយការណ៍វឌ្ឍនភាពប្រចាំ ស្តីពីការអនុវត្តគោលនយោបាយ ស្តីពីសមភាពយេនឌ័រតាមវិស័យ (ជាផ្នែកមួយនៃរបាយការណ៍ជូនរាជរដ្ឋាភិបាល) | សហការជាមួយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីក្នុងការរៀបចំ និងជំរុញការអនុវត្តប្រព័ន្ធនិងឧបករណ៍ត្រួតពិនិត្យ និងតាមដានការអនុវត្តគោលនយោបាយជាតិ ស្តីពីសមភាពយេនឌ័រ និងគោលនយោបាយពាក់ព័ន្ធ រួមទាំងការអនុវត្តអនុសញ្ញាស៊ី-ដ | ក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីស្ត្រី<br>ក្រសួងកិច្ចការនារី<br>ក្រសួង-ស្ថាប័ន<br>ដៃគូអភិវឌ្ឍ | ✓ | ✓ | ✓ | ✓ | ✓ | | |
| | **ចំនួនក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលរៀបចំ និងដំណើរការកម្មវិធីពិនិត្យតាមដាន និងវាយតម្លៃ** លើការអនុវត្តគោលនយោបាយជាតិ ស្តីពីសមភាពយេនឌ័រ | គាំទ្រ និងអភិវឌ្ឍសមត្ថភាពដល់ក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំ និងដំណើរការកម្មវិធីតាមដាន និងវាយតម្លៃលើការអនុវត្តគោលនយោបាយស្តីពីសមភាពយេនឌ័រតាមវិស័យ និងនៅថ្នាក់ក្រោមជាតិ | ក្រសួងកិច្ចការនារី<br>ក្រុមការងារបញ្ជ្រាបយេនឌ័រតាមក្រសួង-ស្ថាប័ន<br>រដ្ឋបាលថ្នាក់ក្រោមជាតិ<br>ដៃគូអភិវឌ្ឍ | ✓ | ✓ | ✓ | ✓ | ✓ | | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៦. អនុវត្តកម្មវិធីបង្កើនការយល់ដឹងជាសាធារណៈ ការផ្លាស់ប្តូរផ្នត់គំនិតអវិជ្ជមាន និងការស្វែងរកគាំទ្រមតិដើម្បីគាំទ្រលើសមភាពយេនឌ័រ រួមទាំងការបញ្ជ្រាបយេនឌ័រ នៅក្នុងប្រព័ន្ធផ្សព្វផ្សាយ និងសារព័ត៌មាន។ | **យុទ្ធសាស្ត្រ និងសកម្មភាពស្តីពីការស្វែងរកការគាំទ្រមតិលើការលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី** បាន រៀបចំ និងអនុវត្ត<br><br>ចំនួនវិធានការ និងកម្មវិធីនៅក្នុងយុទ្ធសាស្ត្រខាងលើបានអនុវត្ត (ប្រចាំឆ្នាំ) | សម្របសម្រួលរៀបចំ និងដឹកនាំការអនុវត្តយុទ្ធសាស្ត្រ និង សកម្មភាពស្តីពីការស្វែងរកការគាំទ្រមតិលើការលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី (យោងរបកគំហើញថ្មីៗ ក្នុងវិធានការគន្លឹះទី១ ខាងលើ និងប្រើប្រាស់សម្រាប់ការលើកកម្ពស់ ការគាំទ្រពីថ្នាក់ដឹកនាំ និងដៃគូពាក់ព័ន្ធលើការងាររបស់យុទ្ធសាស្ត្រ និងវិធានការគន្លឹះរបស់នារីរតនៈទី៦ទាំងមូល) | ក្រសួងកិច្ចការនារី<br>ក្រុមការងារបញ្ជ្រាបយេនឌ័រតាមក្រសួង-ស្ថាប័ន<br>ដៃគូអភិវឌ្ឍ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | ចំនួន**កម្មវិធីអប់រំផ្សព្វផ្សាយ** របស់ក្រសួងកិច្ចការនារី និងមន្ទីរកិច្ចការនារី ក្នុងការលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងផ្លាស់ប្តូរឥរិយាបថ ផ្នត់គំនិតអវិជ្ជមានរបស់សង្គមដែលរើសអើងលើស្ត្រីនិងក្មេងស្រីគ្រប់រូបភាព<br><br>**ចំនួនមហាជនដែលទទួលបាន និងចូលរួម ឬទស្សនា** | រៀបចំ និងអនុវត្តកម្មវិធីផ្សព្វផ្សាយគ្រប់មធ្យោបាយ ក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងរួមចំណែកផ្លាស់ប្តូរឥរិយាបថ និងផ្នត់គំនិតអវិជ្ជមានរបស់សង្គមដែលរើសអើងលើស្ត្រីនិងក្មេងស្រី<br><br>បង្កើតមាតិកាព័ត៌មានយេនឌ័រសម្រាប់ការផ្សព្វផ្សាយ ក្នុងព័ត៌មានឌីជីថល ដោយផ្អែកលើការសិក្សាស្រាវជ្រាវ ពីទស្សនៈមហាជននិងរបកគំហើញ សិក្សាស្រាវជ្រាវយេន | ក្រសួងកិច្ចការនារី<br>មន្ទីរកិច្ចការនារី<br>ដៃគូអភិវឌ្ឍ<br>សង្គមស៊ីវិល | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ក្នុងកម្មវិធីអប់រំផ្សព្វផ្សាយខាងលើ (ប្រចាំឆ្នាំ)<br><br>**ចំនួន និងប្រភេទមាតិកាព័ត៌មានយេនឌ័រ**ដែលបានបង្កើត និងទទួលបានការការគាំទ្រពីមហាជន | ឌ័រតាមវិស័យ និងថ្មីៗ (ក្នុងវិធានការគន្លឹះទី១ខាងលើ)<br><br>ពង្រឹងបណ្តាញជាមួយអ្នកមានឥទ្ធិពល និងប្រជាប្រិយ នៅក្នុងបណ្តាញសង្គម និងបណ្តាញយេនឌ័រគ្រប់កម្រិតដើម្បីផ្សព្វផ្សាយមាតិកាព័ត៌មានយេនឌ័រខាងលើ | | | | | | | | |
| | **ចំនួនអ្នកសារព័ត៌មានដែលចូលរួមក្នុងកម្មវិធីអភិវឌ្ឍន៍សមត្ថភាពនិងពង្រឹងបណ្តាញ** ក្នុងកម្មវិធីរបស់ក្រសួងកិច្ចការនារី | រៀបចំ និងអនុវត្តកម្មវិធីអភិវឌ្ឍសមត្ថភាព ស្តីពីយេនឌ័រនិងអ្នកសារព័ត៌មាន<br><br>បញ្ចូលយេនឌ័រ ទៅក្នុងកម្មវិធីសិក្សារបស់គ្រឹះស្ថានបណ្តុះបណ្តាលអ្នកសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ<br><br>រៀបចំកម្មវិធីលើកទឹកចិត្ត ការចូលរួម និងពង្រឹងបណ្តាញទំនាក់ទំនងជាមួយសារព័ត៌មាន និងអ្នកផ្សព្វផ្សាយ ក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រីនិងក្មេងស្រី | ក្រសួងកិច្ចការនារី<br>ក្រសួង-ស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ<br>ដៃគូអភិវឌ្ឍ<br>សង្គមស៊ីវិល | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

## យុទ្ធសាស្ត្រទី១៖ ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី

**គោលបំណង៖** ការពង្រីកវិសាលភាពការបញ្ជ្រាបយេនឌ័រ នៅក្នុងក្របខណ្ឌគោលនយោបាយនិងកម្មវិធីជាតិពាក់ព័ន្ធវិស័យសេដ្ឋកិច្ច និងការលើកកម្ពស់ការអនុវត្តកម្មវិធីនិងវិធានការក្នុងការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី រួមទាំងការលើកកម្ពស់សេដ្ឋកិច្ចគ្រួសាររបស់ស្ត្រី ការអភិវឌ្ឍសហគ្រិនភាព ការដោះស្រាយគម្លាតយេនឌ័រក្នុងការចាប់យកជំនាញនិងមុខរបរ និងកម្មវិធីសេដ្ឋកិច្ចដែលគិតគូរសុខុមាលភាព។

| វិធានការគន្លឹះ | សូចនាករសមិទ្ធកម្មគន្លឹះ | សកម្មភាពគន្លឹះ | ដៃគូពាក់ព័ន្ធ | ពេលវេលា (២០២៤-២០២៨) | | | | | ធនធាន | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ២៤ | ២៥ | ២៦ | ២៧ | ២៨ | ជាតិ | ដៃគូ |
| ១. ពង្រឹងបរិយាកាសគាំទ្រនិងការវិនិយោគប្រកបដោយបរិយាប័ន្នក្នុងការគាំទ្រការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី | **ចំនួនគោលនយោបាយ និងកម្មវិធី ដែលចូលរួមដល់ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី និងឆ្លើយតបយេនឌ័រ ក្នុងវិស័យពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច**<br><br>ចំនួនវិធានការណ៍ កម្មវិធី ឬភាពជាដៃគូនានា ស្តីពីការលើកកម្ពស់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី បានតាក់តែង និងអនុវត្ត | សិក្សាស្រាវជ្រាវ និងចងក្រងធាតុចូលស្តីពីបញ្ហាយេនឌ័រ ក្នុងការអភិវឌ្ឍវិស័យពាក់ព័ន្ធសេដ្ឋកិច្ច (ជាផ្នែកមួយ នៃវិធានការគន្លឹះទី១ នៃយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ)<br><br>ស្វែងរកការគាំទ្រមតិ និងជំរុញឱ្យឆ្លើយតបសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី នៅក្នុងដំណើការតាក់តែងកម្មវិធី និងគោលនយោបាយ ក្នុងវិស័យពាក់ព័ន្ធវិស័យសេដ្ឋកិច្ច | ក្រសួងកិច្ចការនារី<br>ក្រសួង-ស្ថាប័ន<br>ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>ពាណិជ្ជកម្ម<br>កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>ការងារនិងបណ្តុះ-បណ្តាលវិជ្ជាជីវៈ<br>ដៃគូអភិវឌ្ឍន៍<br>វិស័យឯកជន<br>សង្គមស៊ីវិល | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | ពង្រឹងយន្តការ និងដំណើរការក្រុមការងារបច្ចេកទេសស្តីពីការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចសម្រាប់ស្ត្រី (TWG-WEE) ក្នុងការសម្របសម្រួល និង លើកកម្ពស់ភាពជាដៃគូពាក់ព័ន្ធ ក្នុងការបញ្ជ្រាបយេនឌ័រក្នុងវិស័យ សេដ្ឋកិច្ច និងពាក់ព័ន្ធ (រួមទាំង សកម្មភាពគន្លឹះខាងលើ) | សមាជិកក្រុមការងារ TWG-WEE | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ២. អភិវឌ្ឍសហគ្រិនភាពរបស់ស្ត្រី និងគាំទ្រដល់ស្ត្រីដែលដឹកនាំ និងគ្រប់គ្រងអាជីវកម្មខ្នាតមីក្រូ តូច និងមធ្យម ប្រកបដោយបរិយាបន្ន | **ចំនួនស្ត្រីសហគ្រិន និងអ្នកទទួលផលពីមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនស្ត្រី** (WEDC) ដើម្បីអភិវឌ្ឍន៍ និងពង្រីកកាលានុវត្តន៍ភាពអាជីវកម្មរបស់ស្ត្រី | ដំណើរការកម្មវិធីរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនភាពស្ត្រី (WEDC) ក្នុងការដឹកនាំ និងភាពជាដៃគូ ក្នុងការផ្តល់សេវាលើការអភិវឌ្ឍសហគ្រិនភាពស្ត្រី ការចាប់ផ្តើមអាជីវកម្មនិងអភិវឌ្ឍមុខរបរ និងពង្រឹងបណ្តាញសហគ្រិនស្ត្រីនិងទីផ្សារ (មជ្ឈមណ្ឌល នឹងមានផ្នែកមួយជាថ្នាក់ឱដីថលសម្រាប់សហគ្រិនជាស្ត្រី រួមទាំងស្ត្រីនិងក្មេងស្រី) | ក្រសួងកិច្ចការនារី វិស័យឯកជន អង្គការដៃគូនានា WDCs WEDC | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | **អគារមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនភាពស្ត្រី ដែលបានដាក់ឱ្យដំណើរការ** និងមានរចនាសម្ព័ន្ធដឹកនាំ និងគ្រប់គ្រងជាផ្លូវការ | ជួសជុលអគារ និងដំណើរការជាផ្លូវការមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនភាពស្ត្រី (មានកម្រិតស្មើនាយកដ្ឋាន) | ក្រសួងកិច្ចការនារី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ✓ | ✓ | | | | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | **ចំនួន និងប្រភេទវិធានការគាំទ្រដល់ស្ត្រី នៅក្នុងអាជីវកម្មខ្នាតមីក្រូ តូច និងមធ្យម** (MSME) របស់ក្រសួងស្ថាប័ន និងដៃគូពាក់ព័ន្ធ ដែលបានអនុវត្តតាមរយៈការលើកឡើង ក្នុងព្រឹត្តិការណ៍របស់ក្រសួងកិច្ចការនារី | រៀបចំព្រឹត្តិការណ៍ ដើម្បីបង្កើនការយល់ដឹង និងស្វែងរកការគាំទ្រមតិលើតម្រូវការរបស់ ស្ត្រី នៅក្នុងអាជីវកម្មខ្នាតមីក្រូ តូច និងមធ្យម (តាមរយៈថវិការដ្ឋ និងភាពជាដៃគូជាមួយដៃគូពាក់ព័ន្ធ រួមទាំងវិស័យឯកជន កម្មវិធីនេះ នឹងរៀបចំយ៉ាងតិចមួយឆ្នាំម្តង កម្រិតជាតិ រួមទាំងផ្ទះបញ្ចាំងវឌ្ឍនភាពក្នុងឆ្នាំនីមួយៗ) | ក្រសួងកិច្ចការនារី<br>WEDC<br>វិស័យឯកជន<br>អង្គការដៃគូនានា<br>WDCs | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | បណ្តាញសហគ្រិនស្ត្រីកម្ពុជា និងសមាគមនៅក្នុងវិស័យធុរកិច្ច ដែលបានដំណើរការ តាមរយៈការគាំទ្រពីក្រសួងកិច្ចការនារី | សម្របសម្រួល និងគាំទ្របណ្តាញសហគ្រិនស្ត្រីកម្ពុជា និងសមាគមនានាក្នុងការលើកកម្ពស់សម្លេង និងបរិយាកាសគាំទ្រដល់ស្ត្រី នៅក្នុងវិស័យធុរកិច្ច នៅថ្នាក់ជាតិ និងតំបន់ | ក្រសួងកិច្ចការនារី<br>CamWEN CWEA<br>ក្រសួង ស្ថាប័ន<br>ដៃគូអភិវឌ្ឍន៍<br>វិស័យឯកជន | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | **ចំនួនសហគ្រិនស្ត្រីឆ្នើម និងទទួលបានពានរង្វាន់ប្រចាំតំបន់ និងអន្តរជាតិ**<br>ចំនួនកម្មវិធី សហគ្រិន និងសហគមន៍ឆ្នើម និងមានភាពជាគំរូគាំទ្រដល់ស្ត្រីក្នុងវិស័យធុរកិច្ច និងសេដ្ឋកិច្ច (រួមស្ត្រីដែលស្ថិតក្នុងក្រុមងាយរងគ្រោះ) រួមទាំងការ | ជំរុញ និងគាំទ្រដល់រៀបចំកម្មវិធីលើកទឹកចិត្ត និងកម្មវិធីពានរង្វាន់ដល់សហគ្រិនឆ្នើមប្រចាំឆ្នាំ នៅក្នុងស្រុក និងនៅអាស៊ាន (កម្មវិធី ឬសកម្មភាពនេះ ក៏ត្រូវពិចារណាដល់ការលើកកម្ពស់បរិយាបន្ន ដូចជា ស្ត្រី និងស្ត្រីវ័យក្មេង ដែលស្ថិត ក្នុងក្រុមងាយរងគ្រោះនិងបាត់ឱកាស ដែលមានសមត្ថភាពក្នុងសកម្មភាពសេដ្ឋកិច្ច | ក្រសួងកិច្ចការនារី<br>WEDC<br>CamWEN<br>វិស័យឯកជន<br>អង្គការដៃគូនានា<br>WDCs | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | លើកកម្ពស់សេដ្ឋកិច្ចបៃតង និងការគិតគូរដល់សង្គម | រួមទាំងសេដ្ឋកិច្ចបៃតង និងគិតគូរដល់សង្គមជាដើម ) | | | | | | | | |
| ៣. ពង្រីកបរិយាកាសសម្រាប់ស្ត្រី តាមរយៈការដោះស្រាយគម្លាតយេនឌ័រ ក្នុងជំនាញនិងមុខរបរ និងការអភិវឌ្ឍជំនាញវិជ្ជាជីវៈជូនតា និងជំនាញផ្សេងៗ ប្រកបដោយបរិយាបន្ន | **វឌ្ឍនភាពនៃការកាត់បន្ថយគម្លាតយេនឌ័រ** ក្នុងការចាប់យកជំនាញ និងមុខរបរ ផ្អែកលើបញ្ជីវិភាគរបស់ក្រសួងកិច្ចការនារី<br>**ចំនួនវិធានការ និងគំនិតផ្តួចផ្តើមនានា ក្នុងការលើកកម្ពស់ការកាត់បន្ថយគម្លាតយេនឌ័រ ក្នុងការចាប់យកជំនាញ និងមុខរបរ** | សិក្សាស្រាវជ្រាវ និងវិភាគជាប្រចាំលើរបកគំហើញនៃគម្លាតយេនឌ័រ ក្នុងការចាប់យកមុខរបរ និងជំនាញ (ធ្វើបច្ចុប្បន្នភាព ជាប្រចាំឆ្នាំ និងជំនួយដល់ក្រសួង ក្នុងការរៀបចំកម្មវិធី និងគំនិតផ្តួចផ្តើមនានា ក្នុងការឆ្លើយតប រួមទាំងការស្វែងរកការគាំទ្រមតិជាមួយដៃគូពាក់ព័ន្ធ ) | ក្រសួងកិច្ចការនារី<br>ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួង ស្ថាប័នដៃគូពាក់ព័ន្ធ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | | រៀបចំកម្មវិធីនិងគំនិតផ្តួចផ្តើមនានា ក្នុងការលើកកម្ពស់ការយល់ដឹង និងការគាំទ្រដល់ការកាត់បន្ថយគម្លាតយេនឌ័រ ក្នុងការចាប់យកជំនាញ និងមុខរបរ | ក្រសួងកិច្ចការនារី<br>វិស័យឯកជន<br>អង្គការដៃគូនានា<br>WDCs | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | | សិក្សា ចងក្រង និងធ្វើបច្ចុប្បន្នភាពព័ត៌មានពាក់ព័ន្ធតម្រូវការ និងឱកាសការងារ និងមុខរបរសម្រាប់ស្ត្រី និងផ្សព្វផ្សាយដល់ដៃគូពាក់ព័ន្ធ ដើម្បីមានលទ្ធភាពធ្វើបច្ចុប្បន្នភាពកម្មវិធីបណ្តុះបណ្តាលដែលមានលក្ខណៈសមស្របតាមតំបន់ | ក្រសួងកិច្ចការនារី<br>វិស័យឯកជន<br>អង្គការដៃគូនានា<br>WDCs | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ចំនួនអ្នកដែលទទួលបានការបណ្ដុះបណ្ដាល និងហ្វឹកហាត់ការងារនៅតាមបណ្ដាខេត្តតាមរយៈមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីប្រកបដោយបរិយាបន្ន | មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី រៀបចំ និងផ្តល់វគ្គបណ្តុះបណ្តាលជំនាញ ដល់ស្ត្រី ស្របតាមតម្រូវការសេដ្ឋកិច្ចឌីជីថល ក្នុងតំបន់ប្រកបដោយបរិយាប័ន្ន<br>សម្របសម្រួល ក្នុងការធ្វើបច្ចុប្បន្នជាប្រចាំ លើកម្មវិធីបណ្តុះបណ្តាល កម្មវិធីគ្រប់គ្រងគ្រូបណ្តុះបណ្តាល និងគ្រប់គ្រងមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី តាមបែបឌីជីថល | ក្រសួងកិច្ចការនារី វិស័យឯកជន អង្គការដៃគូនានា<br>WDCs | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | **ចំនួនមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី ដែលបានធ្វើពិពិធកម្មមុខងារ** ឆ្លើយតបតម្រូវការជំនាញ និងការងាររបស់ស្ត្រី និងក្មេងស្រី ស្របតាមតំបន់ប្រកបដោយបរិយាបន្ន។ | រៀបចំការធ្វើពិពិធកម្មមុខងារ និងអភិវឌ្ឍន៍មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី ដែលមានទំនើបកម្ម ស្របតាមតម្រូវការទីផ្សារ ដោយមានការផ្សារភ្ជាប់នឹងការហាត់ការ និងមានយន្តការតាមដានច្បាស់លាស់ | ក្រសួងកិច្ចការនារី វិស័យឯកជន អង្គការដៃគូនានា<br>WDCs | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | របាយការណ៍ ដែលបង្ហាញអំពីជម្រើសនានាសម្រាប់ក្រសួងកិច្ចការនារី ក្នុងការអនុវត្តកម្មវិធីជំនាញមរតកដូនតាដល់ការអភិវឌ្ឍសេដ្ឋកិច្ចគ្រួសារនិងស្ត្រី | សិក្សាលទ្ធភាពនានា និងរៀបចំកម្មវិធីពាក់ព័ន្ធនឹងជំនាញមរតកដូនតា ក្នុងការអភិវឌ្ឍជំនាញសម្រាប់ស្ត្រី | ក្រសួងកិច្ចការនារី វិស័យឯកជន អង្គការដៃគូនានា<br>WDCs | ✓ | ✓ | | | | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ចំនួនកម្មវិធី ជំនាញវិជ្ជាជីវៈ និងការអភិវឌ្ឍមុខរបរត្រូវបានរៀបចំស្របតាមតម្រូវការទីផ្សារការងារប្រកបដោយបរិយាប័ន្ន និងមានការគិតគូរពីការអភិវឌ្ឍជំនាញមរតកដូនតា។ | រៀបចំ និងអនុវត្តកម្មវិធីជំនាញមរតកដូនតា ក្នុងការអភិវឌ្ឍជំនាញសម្រាប់ស្ត្រី តាមរយៈមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី<br>ពិនិត្យលទ្ធភាព ក្នុងការអភិវឌ្ឍជំនាញវិជ្ជាជីវៈលើក្របខ័ណ្ឌគុណវុឌ្ឍិជាតិ ក្នុងការលើកកម្ពស់ជំនាញវិជ្ជាជីវៈដល់ស្ត្រីនៅតាមមូលដ្ឋាន តាមរយៈមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី | ក្រសួងកិច្ចការនារី<br>វិស័យឯកជន<br>អង្គការដៃគូនានា<br>WDCs | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ៤. លើកកម្ពស់សេដ្ឋកិច្ចដែលគិតគូរពីសុខមាលភាព កម្មវិធីតុល្យភាពជីវិតគ្រួសារ និងការងារ និងបរិយាកាសមេត្រីភាពនៅកន្លែងការងារសម្រាប់ស្ត្រី នៅក្នុងសកម្មភាពសេដ្ឋកិច្ច | **ក្របខ័ណ្ឌ និងផែនការសកម្មភាពស្តីពីសេដ្ឋកិច្ចដែលគិតគូរពីសុខុមាលភាព** បានរៀបចំ ផ្សព្វផ្សាយ និងអនុវត្ត<br>កញ្ចប់កម្មវិធីផ្សព្វផ្សាយសម្រាប់ ជំរុញការអនុវត្តក្របខ័ណ្ឌ | ដឹកនាំសម្របសម្រួល ក្នុងការបញ្ចប់សេចក្តីព្រាងក្របខ័ណ្ឌ **និងផែនការសកម្មភាពស្តីពីសេដ្ឋកិច្ចដែលគិតគូរពីសុខុមាលភាព** និងជំរុញការអនុវត្តនៅក្នុងក្របខ័ណ្ឌក្រសួង-ស្ថាប័ន និងដៃគូពាក់ព័ន្ធ<br>(រួមទាំងរៀបចំយន្តការជំរុញការអនុវត្ត)<br>រៀបចំសម្ភារៈផ្សព្វផ្សាយ និងអនុវត្តវិធីសាស្ត្រក្នុងការលើកកម្ពស់ការអនុវត្តក្របខណ្ឌ និងផែនការសកម្មភាពស្តីពីសេដ្ឋកិច្ចដែលគិតគូរពីសុខុមាលភាព រួមទាំងកម្មវិធីអប់រំជាសាធារណៈ ក្នុងការលើក | ក្រសួងកិច្ចការនារី<br>ក្រសួង-ស្ថាប័ន<br>ដៃគូអភិវឌ្ឍ<br>សង្គមស៊ីវិល<br>វិស័យឯកជន | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | កម្ពស់គុណតម្លៃនៃសេដ្ឋកិច្ចគិតគូរ សុខុមាលភាព | | | | | | | | |
| | ចំនួនកម្មវិធីដែលឆ្លើយតប សម្រាប់ស្ត្រី ក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ របស់ក្រសួង កិច្ចការនារី បានអនុវត្ត ក្រោមក្របខណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ចក្រៅប្រព័ន្ធរបស់រាជរដ្ឋាភិបាល | សិក្សាស្វែងយល់ អំពីតម្រូវការអាទិភាពរបស់ស្ត្រីក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងលើកអនុសាសន៍ក្នុងការឆ្លើយតបនៅក្នុងរបៀបវារៈ វិធានការរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ<br>វេទិកាជជែកពិភាក្សា និងវិធានការនានា ក្នុងការជំរុញគាំទ្រផ្នែកគោលនយោបាយនិងកម្មវិធីឆ្លើយតបនឹងតម្រូវការស្ត្រី ក្នុងសកម្មភាពសេដ្ឋកិច្ចក្រៅប្រព័ន្ធ | ក្រសួងកិច្ចការនារី គណៈកម្មាធិការជាតិសេដ្ឋកិច្ចក្រៅប្រព័ន្ធ ក្រសួង ស្ថាប័ន | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | ចំនួនស្ត្រីលក់ដូរតាមដងផ្លូវ និងក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធដែលទទួលផលក្នុងការអភិវឌ្ឍមុខរបរនិងវិធានការសង្គមនានា | រៀបចំកម្មវិធីក្នុងការគាំទ្រដល់ស្ត្រីលក់ដូរតាមដងផ្លូវ និងស្ត្រីនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធផ្សេងទៀត | ក្រសួងកិច្ចការនារី គណៈកម្មាធិការជាតិសេដ្ឋកិច្ចក្រៅប្រព័ន្ធ ក្រសួង ស្ថាប័ន | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | ចំនួនកម្មវិធីផ្សព្វផ្សាយ ស្តីពីកិច្ចគាំពារសុខុមាលភាពនិងសុវត្ថិភាពកន្លែងការងារសម្រាប់ស្ត្រីដើម្បីលើកកម្ពស់ការយកចិត្តទុករបស់វិស័យឯកជន ក្នុងការគិតគូរនិងបរិយាកាសគាំទ្រស្ត្រីនៅ | រៀបចំកម្មវិធីជាមួយវិស័យឯកជន និងដៃគូពាក់ព័ន្ធ ក្នុងការពង្រីកឱកាសទទួលបានការងារ និងទទួលបានកិច្ចគាំពារសុខុមាលភាព និងសុវត្ថិភាពនៅកន្លែងការងារ សម្រាប់ស្ត្រី ប្រកបដោយបរិយាបន្ន រួមទាំងការអនុវត្តគោលនយោបាយ | ក្រសួងកិច្ចការនារី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ វិស័យឯកជន ដៃគូអភិវឌ្ឍន៍<br>សង្គមស៊ីវិល | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | កន្លែងធ្វើការ ប្រកបដោយបរិយាបន្ន | គ្មានការបៀតបៀនផ្លូវភេទនៅកន្លែងការងារ<br>សម្របសម្រួលបង្កើតកម្មវិធីលើកទឹកចិត្តដល់ស្ថាប័នគំរូ ក្នុងការបង្កើនបរិយាកាសមេត្រីភាព និងសុវត្ថិភាពស្ត្រី | | | | | | | | |
| | ចំនួនកម្មវិធីនានា ដែលឆ្លើយតបនិងទទួលស្គាល់នូវតុល្យភាពជីវិតនិងការងារ ការងារផ្ទះនិងការថែទាំដែលមិនមានកម្រៃ | រៀបចំកម្មវិធីបង្កើនការយល់ដឹង និងស្វែងរកការគាំទ្រការយកចិត្តទុកដាក់ និងការទទួលស្គាល់នូវតុល្យភាពជីវិត និងការងារ | ក្រសួងកិច្ចការនារី<br>ក្រសួង-ស្ថាប័ន<br>ដៃគូអភិវឌ្ឍ<br>សង្គមស៊ីវិល<br>វិស័យឯកជន | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | ចំនួនគំនិតផ្តួចផ្តើម និងកម្មវិធីដែលយកចិត្តទុកដាក់ដល់ការលើកកម្ពស់តួនាទីរបស់បុរសលើកិច្ចការផ្ទះសម្បែង និងថែទាំគ្រួសារ | រៀបចំកម្មវិធី និងគំនិតផ្តួចផ្តើម ក្នុងការលើកកម្ពស់ទំនួលខុសត្រូវរបស់បុរសលើកិច្ចការផ្ទះសម្បែង និងការថែទាំ | ក្រសួងកិច្ចការនារី<br>ក្រសួង-ស្ថាប័ន<br>ដៃគូអភិវឌ្ឍ<br>សង្គមស៊ីវិល<br>វិស័យឯកជន | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ៥. លើកកម្ពស់សេដ្ឋកិច្ចគ្រួសាររបស់ស្ត្រីនៅតាមសហគមន៍ តាមរយៈការទទួលបានបច្ចេកវិទ្យាឌីជីថល ការអភិវឌ្ឍអាជីវកម្ម និងបរិយាបន្នហិរញ្ញវត្ថុ | ចំនួនក្រុមគោលដៅជាស្ត្រី និងគ្រួសារ ដែលទទួលផលផ្ទាល់ពីគម្រោងនិងកម្មវិធីលើកកម្ពស់ជីវភាពនិងពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ច និងសុខុមាលភាពហិរញ្ញវត្ថុដល់ស្ត្រីនៅតាមជនបទ | បង្កើតកម្មវិធី និងគំនិតផ្តួចផ្តើម ក្នុងការលើកកម្ពស់ជីវភាពនិងសេដ្ឋកិច្ចគ្រួសាររបស់ស្ត្រី រួមទាំងសុខុមាលភាពហិរញ្ញវត្ថុដល់ស្ត្រី នៅតាមជនបទ<br>កិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការលើកកម្ពស់សេដ្ឋកិច្ចស្ត្រី នៅក្នុងគម្រោង និងកម្មវិធីអភិវឌ្ឍន៍សហគមន៍ | ក្រសួងកិច្ចការនារី<br>ក្រសួង-ស្ថាប័ន<br>ដៃគូអភិវឌ្ឍ<br>សង្គមស៊ីវិល<br>វិស័យឯកជន | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | **ក្របខណ្ឌស្តីពីការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី** បានរៀបចំ<br>ចំនួន និងប្រភេទវិធានដែលមានក្នុងក្របខណ្ឌស្តីពីការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី បានអនុវត្ត | សម្របសម្រួលក្នុងការរៀបចំ និងជំរុញការអនុវត្តក្របខណ្ឌស្តីពីការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី ចូលរួមអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុ | ក្រសួងកិច្ចការនារី<br>ធនាគារជាតិនៃកម្ពុជា<br>ក្រសួង ស្ថាប័ន<br>វិស័យឯកជន<br>ដៃគូពាក់ព័ន្ធ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | ចំនួនកម្មវិធី និងអ្នកទទួលពីកម្មវិធីការលើកកម្ពស់បរិយាបន្នឌីជីថល បច្ចេកវិទ្យាព័ត៌មាននិងហិរញ្ញវត្ថុ និងការអភិវឌ្ឍពិពិធកម្មសេដ្ឋកិច្ចដល់ស្ត្រី និងក្មេងស្រីនៅសហគមន៍ និងទីជនបទ | កសាងកម្មវិធី និងភាពជាដៃគូជាមួយក្រសួង-ស្ថាប័ន វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នមីក្រូហិរញ្ញវត្ថុ ក្នុងការលើកកម្ពស់បរិយាបន្នឌីជីថល បច្ចេកវិទ្យាព័ត៌មាននិងហិរញ្ញវត្ថុ និងការអភិវឌ្ឍពិពិធកម្មសេដ្ឋកិច្ចដល់ស្ត្រី និងក្មេងស្រីនៅសហគមន៍ និងទីជនបទ | ក្រសួងកិច្ចការនារី<br>ធនាគារជាតិនៃកម្ពុជា<br>ក្រសួង ស្ថាប័ន<br>វិស័យឯកជន<br>ដៃគូពាក់ព័ន្ធ | | | | | | | |

# យុទ្ធសាស្ត្រទី២៖ ការលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារ

**គោលបំណង៖** ការលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ តាមរយៈការលើកកម្ពស់យន្តការអន្តរក្រសួង ស្ថាប័ន និងវិធានការពហុវិស័យ និងការអនុវត្តកម្មវិធីភាពជាមាតានិងបិតានិងការអប់រំកូនតាមបែបវិជ្ជមាន ការពង្រឹងវប្បធម៌អហិង្សា និងកសាងគ្រួសារប្រកបដោយសុភមង្គល។

| វិធានការគន្លឹះ | សូចនាករសមិទ្ធកម្មគន្លឹះ | សកម្មភាពគន្លឹះ | ដៃគូពាក់ព័ន្ធ | ពេលវេលា (២០២៤-២០២៨) | | | | | ធនធាន | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ២៤ | ២៥ | ២៦ | ២៧ | ២៨ | ជាតិ | ដៃគូ |
| ១. ដឹកនាំ និងសម្របសម្រួលយន្តការអន្តរស្ថាប័ន នៅថ្នាក់ជាតិ និងក្រោមជាតិ ក្នុងការលើកកម្ពស់ការអនុវត្តវិធានការពហុវិស័យ ក្នុងការបង្ការ និងទប់ស្កាត់គ្រប់ទិដ្ឋភាពទិដ្ឋភាពអវិជ្ជមាន ដើម្បីចូលរួមលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ | អនុក្រឹតស្តីពីការបង្កើនគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី សមាសភាពគណៈកម្មការចម្រុះនៅថ្នាក់រាជធានី ខេត្ត បានរៀបចំ និងអនុម័តដាក់ឱ្យអនុវត្ត | កែសម្រួល និងរៀបចំឡើងវិញគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ (គ.ជ.ស.ស.ខ) និងគណៈកម្មការចម្រុះ លើកកម្ពស់សីលធម៌ សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរនៅថ្នាក់រាជធានី ខេត្ត | គណៈកម្មាធិការជាតិ (គ.ជ.ស.ស.ខ) គណៈកម្មការចម្រុះរាជធានី ខេត្ត | | √ | | | | √ | |
**គោលបំណង៖** ការពង្រឹងអភិបាលកិច្ច និងការធ្វើទំនើបកម្មស្ថាប័នក្រសួងកិច្ចការនារីនិងអង្គភាពចំណុះ ឱ្យក្លាយជារដ្ឋបាលសាធារណៈឌីជីថល និងទំនើប ប្រកបដោយសមត្ថភាពខ្ពស់ ខ្លាំង ឆ្លាតវៃ និងស្អាតស្អំ ព្រមទាំងលើកកម្ពស់ប្រសិទ្ធភាពស្ថាប័ន នៅក្នុងគ្រប់ទិដ្ឋភាពនៃកិច្ចប្រតិបត្តិការរបស់ខ្លួន ទាំងការដឹកនាំស្ថាប័ន ការគ្រប់គ្រងព័ត៌មាន ទំនាក់ទំនងសាធារណៈ កិច្ចសហប្រតិបត្តិការជាមួយដៃគូ និងការត្រួតពិនិត្យនិងវាយតម្លៃ។

| វិធានការគន្លឹះ | សូចនាករសមិទ្ធកម្មគន្លឹះ | សកម្មភាពគន្លឹះ | ដៃគូពាក់ព័ន្ធ | ពេលវេលា (២០២៤-២០២៨) | | | | | ធនធាន | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ២៤ | ២៥ | ២៦ | ២៧ | ២៨ | ជាតិ | ដៃគូ |
| ១. អនុវត្តកម្មវិធីជាតិកែទម្រង់ និងប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ក្នុងរដ្ឋបាលសាធារណៈ: ការអភិវឌ្ឍធនធានមនុស្ស និងនវានុវត្តន៍ ដើម្បីលើកកម្ពស់គុណភាពការងារប្រកបដោយវិន័យសីលធម៌វិជ្ជាជីវៈ ប្រសិទ្ធភាព និងសក្តិសិទ្ធភាព | អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត | កែសម្រួល រចនាសម្ព័ន្ធ មុខងារភារកិច្ច របស់ក្រសួងកិច្ចការនារី ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ<br>ផ្សព្វផ្សាយអនុក្រឹត្យ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារីរៀបចំ | ក្រសួងកិច្ចការនារី | ✓ | ✓ | | | | ✓ | |
| | ចំនួនឯកសារពិពណ៌នាមុខងារភារកិច្ចថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | ពិពណ៌នាមុខងារភារកិច្ច របស់អង្គភាពចំណុះទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | ក្រសួងកិច្ចការនារី | ✓ | ✓ | | | | ✓ | |
| | ស្លាកសញ្ញារបស់ក្រសួងរៀបចំដំណើរការ និងដាក់ឱ្យប្រើប្រាស់ | សម្របសម្រួល រៀបចំស្លាកសញ្ញារបស់ក្រសួងកិច្ចការនារី ជាផ្លូវការ | ក្រសួងកិច្ចការនារី ក្រសួង ស្ថាប័ន | ✓ | ✓ | | | | ✓ | |
| | ប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងព័ត៌មានមន្ត្រីរាជការ និងអង្គភាពចំណុះក្រសួងកិច្ចការនារីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវបានរៀបចំ | រៀបចំ និងគ្រប់គ្រងនូវកម្មវិធីអភិវឌ្ឍន៍សមត្ថភាពមន្ត្រីក្រសួងកិច្ចការនារី ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | ក្រសួងកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ចំនួនថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ទទួលបានការពង្រឹងសមត្ថភាព | សម្របសម្រួលប្រមូលទិន្នន័យអំពីតម្រូវការអភិវឌ្ឍន៍មូលធនមនុស្សរបស់ក្រសួង និងអង្គភាពក្រោមចំណុះ | ក្រសួងកិច្ចការនារី ក្រសួង ស្ថាប័ន អង្គការដៃគូ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | ចំនួនមន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ទទួលបានការពង្រឹងសមត្ថភាព | អភិវឌ្ឍន៍សមត្ថភាព និងជំនាញសម្រាប់មន្ត្រីរាជការ ស្តីពីបរិវត្តកម្មភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរដ្ឋបាល | ក្រសួងកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | ចំនួនកិច្ចប្រជុំ និងសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ (ចំនួនអ្នកចូលរួម) | សន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ និងរៀបចំកិច្ចប្រជុំផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ | ក្រសួងកិច្ចការនារី ដៃគូអភិវឌ្ឍន៍ ក្រសួង-ស្ថាប័ន វិស័យឯកជន | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | ចំនួនមន្ត្រីថ្មី បានចូលបំរើការងារ ក្នុងក្របខ័ណ្ឌក្រសួងកិច្ចការនារី | អនុវត្តប្រព័ន្ធជ្រើសរើសមន្ត្រីរាជការឱ្យចូលបម្រើការងារប្រកបដោយគុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន និងប្រសិទ្ធភាព | ក្រសួងកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | ចំនួនមន្ត្រីជាប់កិច្ចសន្យាបានចូលបំរើការងារក្នុងក្រសួងកិច្ចការនារី | សម្របសម្រួល រៀបចំជ្រើសរើសមន្ត្រីជាប់កិច្ចសន្យា ឱ្យចូលបំរើការងារតាមកិច្ចសន្យា និងដាក់ពង្រាយទៅតាមជំនាញ និងអង្គភាពចំណុះ | ក្រសួងកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ចំនួនមន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលបានលើកទឹកចិត្ត | អនុវត្តប្រព័ន្ធលើកទឹកចិត្ត និងគាំទ្រសមិទ្ធកម្មស្ថាប័នប្រកបដោយសង្គតភាព សមធម៌ ប្រសិទ្ធភាព និងចីរភាព តាមរយៈការតម្លើងឋានន្តរស័ក្តិ គ្រឿងឥស្សរិយយស និងមធ្យោបាយផ្សេងៗទៀត | ក្រសួងកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | ចំនួនមន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវបានតែងតាំង និងសម្រួលភារកិច្ច | សម្របសម្រួលរៀបចំដំណើរការប្រព័ន្ធវាយតម្លៃ តម្លើងឋានៈ និងសម្រួលភារកិច្ចទៅតាមនីតិវិធី និងឋានានុក្រមអនុវត្តតាមលិខិតបទដ្ឋាន គតិយុត្តជាធរមាន | ក្រសួងកិច្ចការនារី<br>ក្រសួងមុខងារសាធារណៈ<br>ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | ចំនួនមន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវបានប្រកាសដាក់ឱ្យចូលនិវត្តន៍ | សម្របសម្រួល និងប្រកាសដាក់ឱ្យមន្ត្រី ចូលនិវត្តន៍ទៅតាមអតីតភាពការងារ និងតាមការស្ម័គ្រចិត្ត | ក្រសួងកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ២.អនុវត្តកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈក្នុងការពង្រឹងប្រសិទ្ធភាពការងារស្ថាប័ន | ផែនការសកម្មភាពរួមតាមដំណាក់កាលនីមួយៗ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ<br>របាយការណ៍សមិទ្ធកម្មប្រចាំត្រីមាស ឆមាស និង ឆ្នាំ | កិច្ចប្រជុំសម្របសម្រួលជាមួយក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងនាយកដ្ឋានពាក់ព័ន្ធ ដើម្បីរៀបចំផែនការសកម្មភាពរួម តាមដំណាក់កាលនីមួយៗ | ក្រសួងកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | ចំនួនមន្ត្រីមានចំណេះដឹងស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រ | អភិវឌ្ឍសមត្ថភាពមន្ត្រីក្រសួង-មន្ទីរកិច្ចការនារី ស្តីពីការគ្រប់គ្រង | ក្រសួងកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ថវិកាឆ្លើយតបនឹងផែនការយុទ្ធសាស្ត្រនារីរតនៈ | ហិរញ្ញវត្ថុសាធារណៈ និងការរៀបចំថវិកា | | | | | | | | |
| | សៀវភៅផែនការយុទ្ធសាស្ត្រថវិកា និងផែនការចំណាយថវិកាប្រចាំឆ្នាំត្រូវបានរៀបចំ | សម្របសម្រួលរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងផែនការចំណាយថវិកាប្រចាំឆ្នាំ | ក្រសួងកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS) ត្រូវបានរៀបចំ | រៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS) | ក្រសួងកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | ចំនួនមន្ត្រីមានចំណេះដឹង និងប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS) បានល្អ | ចូលរួមក្នុងកម្មវិធីអភិវឌ្ឍសមត្ថភាព របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) និងប្រព័ន្ធព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS) | ក្រសួងកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | ចំនួនសវនករ ទទួលបានការអភិវឌ្ឍន៍សមត្ថភាព | អភិវឌ្ឍន៍សមត្ថភាពសវនករលើគោលការណ៍ណែនាំពីនីតិវិធីសវនកម្មផ្ទៃក្នុង សវនកម្មបច្ចេកវិទ្យាព័ត៌មាន និងសវនកម្មសមិទ្ធកម្ម ស្របតាមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ | ក្រសួងកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ផែនការសវនកម្មផ្ទៃក្នុងដោយផ្អែកលើហានិភ័យ និងធនធានសវនកម្មបានរៀបចំ និងអនុវត្ត | រៀបចំផែនការសវនកម្មផ្ទៃក្នុងដោយផ្អែកលើហានិភ័យ និងធនធានសវនកម្ម | ក្រសួងកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | ចំនួនរបាយការណ៍សវនកម្មផ្ទៃក្នុង និងអធិការកិច្ច | សិក្ខាសាលាឆ្លុះបញ្ចាំងលើលទ្ធផលនៃការចុះសវនកម្មផ្ទៃក្នុង និងអធិការកិច្ច<br>ការធ្វើសវនកម្មផ្ទៃក្នុង និងអធិការកិច្ច នៅក្នុងអង្គភាពចំណុះ | ក្រសួងកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ៣.អនុវត្តកម្មវិធីកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈ ការ ក្នុងការពង្រឹងប្រសិទ្ធភាពការងារស្ថាប័ន | ឯកសារគោលការណ៍ណែនាំស្តីពីការអនុវត្តមុខងារនៃការងារកិច្ចការនារី លើការងារស្ត្រីនិងកុមារសម្រាប់ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គមក្រុង-ស្រុក- ខណ្ឌ បានបោះពុម្ព និងផ្សព្វផ្សាយ | បញ្ចប់គោលការណ៍ណែនាំ ស្តីពីការអនុវត្តមុខងាររបស់ការងារកិច្ចការនារី លើការងារស្ត្រី និងកុមារ សម្រាប់ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គមក្រុង-ស្រុក-ខណ្ឌ<br>ផ្សព្វផ្សាយ និងជំរុញការអនុវត្តសេចក្តីណែនាំ | ក្រសួងកិច្ចការនារី<br>លេខាធិការដ្ឋាន គ.ជ.អ.ប<br>រដ្ឋបាលថ្នាក់ក្រោមជាតិ<br>ដៃគូអភិវឌ្ឍ | ✓ | ✓ | ✓ | ✓ | ✓ | | |
| | ចំនួនខេត្តដែលបានចុះតាមដានក្នុងការអនុវត្តមុខងារដែលបានផ្ទេរទៅរដ្ឋបាលថ្នាក់ក្រោមជាតិ | តាមដានការអនុវត្តមុខងារ ដែលបានផ្ទេរទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលថ្នាក់ក្រោមជាតិ | ក្រសួងកិច្ចការនារី<br>មន្ទីរកិច្ចការនារី<br>លេខាធិការដ្ឋាន គ.ជ.អ.ប<br>រដ្ឋបាលថ្នាក់ក្រោមជាតិ<br>ដៃគូអភិវឌ្ឍ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ចំនួនមុខងារថ្មីដែលបាន សិក្សា និងផ្ទេរទៅរដ្ឋបាលថ្នាក់ក្រោមជាតិ | សិក្សាលើលទ្ធភាពក្នុងការផ្ទេរមុខងារថ្មីៗទៅរដ្ឋបាលថ្នាក់ក្រោមជាតិ | ក្រសួងកិច្ចការនារី<br>លេខាធិការដ្ឋាន<br>គ.ជ.អ.ប<br>រដ្ឋបាលថ្នាក់ក្រោមជាតិ<br>ដៃគូអភិវឌ្ឍ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ៤.ពង្រីកការអនុវត្តកម្មវិធីតុល្យភាពជីវិត គ្រួសារ និង ការងារ និងបរិយាកាស មេត្រីភាពឆ្លើយតបនឹងយេនឌ័រនៅកន្លែងការងារក្នុងស្ថាប័ន និងអង្គភាពចំណុះ | ចំនួនទារក និងកុមារប្រចាំឆ្នាំដែលបានទទួលសេវាពីកម្មវិធីទារកដ្ឋាន<br>ចំនួនវិធានការថ្មីៗ ដែលឆ្លើយតបនឹងការគិតគូរដល់តុល្យភាពជីវិត គ្រួសារ និងការងារនៅក្នុងស្ថាប័ន | ពង្រីក និងអភិវឌ្ឍកម្មវិធីទារកដ្ឋានក្នុងការថែទាំតូច សម្រាប់ជួយសម្រាលបន្ទុកដល់មន្ត្រី និងស្ត្រីដែលមានបន្ទុកការងារច្រើនដើម្បីមានឱកាសនិងពេលវេលាក្នុងការបំពេញតួនាទីនិងភារកិច្ចឱ្យកាន់តែមានប្រសិទ្ធភាព | ក្រសួងកិច្ចការនារី<br>ក្រសួង ស្ថាប័ន<br>វិស័យឯកជន | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | | ផ្សព្វផ្សាយ និងដាក់វិធានការក្នុងការទប់ស្កាត់ផ្នត់គំនិតអវិជ្ជមានពាក់ព័ន្ធនឹងយេនឌ័រក្នុងស្ថាប័ន | ក្រសួងកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | | កម្មវិធីលើកទឹកចិត្ត និងភ្ជាប់ទំនាក់ទំនងជាមួយមន្ត្រីចូលនិវត្តន៍ | ក្រសួងកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | | រៀបចំ និងអនុវត្តវិធានការថ្មីៗ ដែលឆ្លើយតបនឹងការគិតគូរដល់តុល្យភាព ជីវិតគ្រួសារ និងការងារនៅក្នុងស្ថាប័ន | ក្រសួងកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ៥.ពង្រឹងប្រព័ន្ធរៀបចំផែន ការ ស្ថិតិ តាម | ប្រព័ន្ធរៀបចំផែនការ ស្ថិតិ តាមដាន ត្រួតពិនិត្យ និងវាយ | ធ្វើបច្ចុប្បន្នភាពប្រព័ន្ធរៀបចំផែនការ ស្ថិតិ តាមដាន ត្រួត | ក្រសួងកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ដាន ត្រួតពិនិត្យ និង វាយតម្លៃ | តម្លៃផ្អែកលើលទ្ធផលការងារ ត្រូវបាន ពង្រឹងប្រកបដោយ គុណភាព និងប្រសិទ្ធភាព | ពិនិត្យ និងវាយតម្លៃ ផ្អែកលើ លទ្ធផល ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ប្រកបដោយគុណភាព និងប្រសិទ្ធភាព | | | | | | | | |
| | ក្របខណ្ឌនិងប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃរបស់នារីរតនៈទី៦ បានបង្កើត និងដំណើរការ | បង្កើត និងដំណើរការក្រុមការងារតាមដាន និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្ររបស់ក្រសួង | ក្រសួងកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | | អភិវឌ្ឍន៍សមត្ថភាព ស្តីពីការត្រួតពិនិត្យ និងវាយតម្លៃ | ក្រសួងកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | | សិក្ខាសាលាតាមដាន និងតម្រង់ការអនុវត្តផែនការយុទ្ធសាស្ត្ររបស់ក្រសួង | ក្រសួងកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | ធាតុចូលទាក់ទងការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រីត្រូវបានបញ្ចូល ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍នានា កម្មវិធី និងគោលដៅអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា | សម្របសម្រួលក្នុងការរៀបចំសូចនាករ ធាតុចូលនៃផែនការយុទ្ធសាស្ត្ររបស់ក្រសួង និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍនានា<br>រៀបចំសូចនាករសមិទ្ធកម្ម និងរបាយការណ៍វឌ្ឍនភាពរបស់ក្រសួង នៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ | ក្រសួងកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | រៀបចំធាតុចូលនៃការអនុវត្ត ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ផែនការសកម្មភាព ស្តីពីប្រជាជន និងការអភិវឌ្ឍ ICPD (២០២៤-២០៣០) គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (គ.អ.ច.ក) របាយការណ៍ជាតិស្ម័គ្រចិត្ត (VNR) និងគោលនយោបាយអភិវឌ្ឍនានា | ក្រសួងកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | | រៀបចំកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិលទាក់ទងនឹងការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី តាមបច្ចេកវិទ្យាឌីជីថល | ក្រសួងកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | ចំនួនមន្ត្រីដែលទទួលបានការអភិវឌ្ឍន៍សមត្ថភាព | អភិវឌ្ឍន៍សមត្ថភាព ក្នុងការរៀបចំ ចងក្រងសៀវភៅស្ថិតិយេនឌ័រ និងដាក់ឱ្យប្រើប្រាស់ | ក្រសួងកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | ស្ថិតិយេនឌ័រសំខាន់ៗត្រូវបានប្រមូល ចងក្រង បោះពុម្ពផ្សព្វ ផ្សាយ និងដាក់ឱ្យប្រើប្រាស់ | ធ្វើបច្ចុប្បន្នភាពខិតប័ណ្ណ និងសៀវ ភៅស្ថិតិយេនឌ័រសំខាន់ៗនៅកម្ពុជា ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងផ្សព្វផ្សាយនិងដាក់ឱ្យប្រើប្រាស់ | ក្រសួងកិច្ចការនារី ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ចំនួនរបាយការណ៍វឌ្ឍនភាពពាក់កណ្ដាល និងបញ្ចប់អាណត្តិ | ដឹកនាំនិងសម្របសម្រួលការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការយុទ្ធសាស្ត្ររបស់ក្រសួងកិច្ចការនារី | ក្រសួងកិច្ចការនារី ក្រសួង ស្ថាប័ន | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | | សម្របសម្រួលរៀបចំរបាយការណ៍ វឌ្ឍនភាពលើការអនុវត្តផែនការយុទ្ធសាស្ត្ររបស់ក្រសួងកិច្ចការនារី | ក្រសួងកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | ចំនួននៃកម្មវិធីត្រួតពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តកិច្ចព្រមព្រៀង និងអនុស្សរណៈនៃការយោគយល់គ្នា | ត្រួតពិនិត្យ តាមដាន និងវាយតម្លៃ លើការអនុវត្តកិច្ចព្រមព្រៀង និងអនុស្សរណៈនៃការយោគយល់គ្នាដែលបានចុះហត្ថលេខា | ក្រសួងកិច្ចការនារី ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ វិស័យឯកជន | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | ចំនួនឯកសារផែនការសកម្មភាព ថ្នាក់តំបន់ ដែលបានធ្វើមូលដ្ឋានីយកម្ម និងផែនការសកម្មភាពជាតិ ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ | សម្របសម្រួលរៀបចំក្របខណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ស្តីពីការអនុវត្តផែនការសកម្ម ភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ | ក្រសួងកិច្ចការនារី អន្តរក្រសួង អង្គការដៃគូអភិវឌ្ឍន៍ | | | ✓ | | | ✓ | ✓ |
| ៦. ពង្រឹងសមត្ថភាពយន្តការនៅថ្នាក់ជាតិ និងក្រោមជាតិក្នុងការសម្របសម្រួល ប្រាស្រ័យទាក់ ទង និង គ្រប់គ្រងព័ត៌ មាន | ចំនួនកម្មវិធី និងសម្ភារៈ អប់រំផ្សព្វផ្សាយ | រៀបចំ និងអនុវត្តយុទ្ធសាស្ត្រទំនាក់ទំនងសាធារណៈរបស់ក្រសួងកិច្ចការនារី<br>សិក្សាស្រាវជ្រាវ ប្រមូល ចងក្រងផលិត ព្រឹត្តិបត្រនារីរតនៈ វីដេអូខ្លីផ្ទាំងរូបភាព និងសារអប់រំ និង | ក្រសួងកិច្ចការនារី ដៃគូ ឬស្ថាប័ន | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ផ្សព្វផ្សាយតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថល និងស្របតាមបរិបទ សង្គម | | ផ្សព្វផ្សាយតាមបណ្តាញសង្គម និងឌីជីថល | | | | | | | | |
| | ចំនួនសមាជិកទំព័របណ្តាញសង្គម និងឌីជីថល ក្រសួងកិច្ចការនារី មានកើនឡើង (Facebook, Youtube, Instagram, TikTok, Telegram Chanel, Website) | រៀបចំ គ្រប់គ្រង និងដំណើរការប្រព័ន្ធផ្សព្វផ្សាយ បណ្តាញសង្គម និងឌីជីថល របស់ក្រសួងកិច្ចការនារី ក្នុងការផ្សព្វផ្សាយព័ត៌មានព្រឹត្តិ- ការណ៍ និងកិច្ចការសំខាន់ៗរបស់ក្រសួង និងមន្ទីរកិច្ចការនារីរាជធានី-ខេត្ត | ក្រសួងកិច្ចការនារី ដៃគូ ឬស្ថាប័ន | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | ចំនួនយុទ្ធនាការឌីជីថល<br><br>ចំនួនវគ្គបណ្តុះបណ្តាលស្តីពីបច្ចេក វិទ្យាឌីជីថល និងព័ត៌មាន | សម្របសម្រួល ក្នុងការធ្វើឌីជីថលូបនីយកម្មលើកម្មវិធីអប់រំផ្សព្វផ្សាយ របស់ក្រសួង និងមន្ទីរកិច្ចការនារីរាជធានី-ខេត្ត | ក្រសួងកិច្ចការនារី ដៃគូ ឬស្ថាប័ន | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | ការឆ្លើយតបព័ត៌មានទៅកាន់សាធារណៈជន កាន់តែមានប្រសិទ្ធិភាព និងទាន់ពេលវេលា | កិច្ចប្រជុំប្រចាំត្រីមាស ដើម្បីគាំទ្រដល់ក្រុមអ្នកនាំពាក្យ និងក្រុមប្រតិកម្មរហ័សរបស់ក្រសួងកិច្ចការនារី ក្នុងការប្រាស្រ័យទាក់ទងជាមួយសាធារណៈ និងការឆ្លើយតបជាប្រចាំលើតម្រូវការ នៅក្នុងប្រព័ន្ធផ្សព្វផ្សាយនិងសារព័ត៌មាន | ក្រសួងកិច្ចការនារី ដៃគូ ឬស្ថាប័ន | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | ការឆ្លើយតបព័ត៌មានទៅកាន់សាធារណៈជន កាន់តែមាន | កិច្ចប្រជុំប្រចាំត្រីមាស ដើម្បីគាំទ្រដល់ក្រុមអ្នកនាំពាក្យ និងក្រុមប្រតិ កម្មរហ័សរបស់ក្រសួងកិច្ច | ក្រសួងកិច្ចការនារី ដៃគូ ឬស្ថាប័ន | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ប្រសិទ្ធភាព និងទាន់ពេលវេលា | ការនារី ក្នុងការប្រាស្រ័យទាក់ទងជាមួយសាធារណៈ និងការឆ្លើយតបជាប្រចាំលើតម្រូវការ នៅក្នុងប្រព័ន្ធផ្សព្វផ្សាយនិងសារព័ត៌មាន | | | | | | | | |
| ៧. រៀបចំ និងសម្របសម្រួលផែនការសកម្មភាពជាតិ ស្តីពីស្ត្រី សន្តិភាពនិងសន្តិសុខ ដើម្បីជំរុញការអនុវត្តរបៀបវារៈស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ពីថ្នាក់តំបន់អាស៊ាន មកថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងពង្រឹងយន្តការក្នុងការពង្រីកកិច្ចសហប្រតិបត្តិការថ្នាក់ជាតិ ថ្នាក់តំបន់ សកល ភាពជាដៃគូរជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ដើម្បីលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ។ | ចំនួនកិច្ចសហប្រតិបត្តិការថ្នាក់ជាតិ ថ្នាក់តំបន់ និងសកល ក្នុងការលើកកម្ពស់ស្ថានភាពស្ត្រី និងការការពារសិទ្ធិស្ត្រី និងកុមារដែលបានសម្របសម្រួល រៀបចំ និងចូលរួមអនុវត្ត | សម្របសម្រួល រៀបចំ និងចូលរួមអនុវត្តតាមផែនការយុទ្ធសាស្ត្ររបស់គណៈកម្មាធិការអាស៊ានស្តីពីស្ត្រី (ACW) និងគណៈកម្មការអាស៊ានស្តីពីការលើក កម្ពស់ និងការការពារសិទ្ធិស្ត្រី និងកុមារ (ACWC) | ក្រសួងកិច្ចការនារី អង្គការដៃគូអភិវឌ្ឍន៍ វិស័យឯកជន | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | ចំនួនកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ានស្តីពីស្ត្រី (AMMW) ដែលបានចូលរួម | ចូលរួមកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ាន ស្តីពីស្ត្រី (AMMW) | ក្រសួងកិច្ចការនារី ក្រសួង ស្ថាប័ន សមាជិកអាស៊ាន | ✓ | | | ✓ | | ✓ | ✓ |
| | ចំនួនឯកសារដែលបានផ្តល់ធាតុចូល | ពង្រឹងកិច្ចសហការនាយកដ្ឋានជំនាញដើម្បីផ្តល់ធាតុចូលលើឯកសារអន្តរជាតិពាក់ព័ន្ធកិច្ចការនារី | ក្រសួងកិច្ចការនារី ដៃគូ ឬស្ថាប័ន | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | ចំនួនរបាយការណ៍ជាតិពាក់ព័ន្ធកិច្ចការនារីនិងសមភាពយេនឌ័រ ដែលបានរៀបចំ | ពង្រឹងកិច្ចសហការនាយកដ្ឋានជំនាញ ក្នុងការរៀបចំរបាយការណ៍ជាតិពាក់ព័ន្ធកិច្ចការនារី និងសមភាពយេនឌ័រ ស្របតាមកាតព្វកិច្ចរបស់រដ្ឋ ដើម្បីចែករំលែកក្នុងព្រឹត្តការណ៍ និងកិច្ចប្រជុំអន្តរជាតិពាក់ព័ន្ធ | ក្រសួងកិច្ចការនារី ដៃគូ ឬស្ថាប័ន | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ផែនការសកម្មភាពជាតិ ស្តីពី ស្ត្រី សន្តិភាព និងសន្តិសុខ ទទួលបានការអនុម័ត និង ដាក់អោយប្រើប្រាស់ | សម្របសម្រួលដឹកនាំរៀបចំក្រុមការងារពិគ្រោះយោបល់ ដើម្បីរៀបចំផែនការសកម្មភាពជាតិ ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ<br>សិក្ខាសាលាពិគ្រោះយោបល់ស្តីពីការរៀបចំផែនការសកម្មភាពជាតិ ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ | ក្រសួងកិច្ចការនារី ក្រសួង ស្ថាប័ន អង្គការដៃគូអភិវឌ្ឍន៍ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | ចំនួនរបៀបវារៈស្តីពីផែនការ ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខដែលបានផ្សព្វផ្សាយ | ផ្សព្វផ្សាយអំពីរបៀបវារៈ ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ដល់មន្ត្រីថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ នឹងដាក់ឱ្យអនុវត្តនូវផែនការសកម្មភាពថ្នាក់តំបន់ និងផែនការសកម្មភាពជាតិស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ | ក្រសួងកិច្ចការនារី ក្រសួង ស្ថាប័ន អង្គការដៃគូអភិវឌ្ឍន៍ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | របាយការណ៍វឌ្ឍនភាពការអនុវត្តសេចក្តីថ្លែងការណ៍ នាទីក្រុងប៉េកាំង ស្តីពីការលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី ក្នុងរយៈពេល៣០ឆ្នាំ (Beijing+30 report) បាន រៀបចំ និងដាក់បញ្ចូល ក្នុងរបាយការណ៍តំបន់ | រៀបចំ និងផ្សព្វផ្សាយរបាយការណ៍វឌ្ឍនភាពការអនុវត្តសេចក្តីថ្លែងការណ៍ នាទីក្រុងប៉េកាំង ស្តីពីការលើកកម្ពស់សមភាពយេនឌ័រនិងបង្កើនភាពអង់អាចដល់ស្ត្រី ក្នុងរយៈពេល៣០ឆ្នាំ (Beijing+30 Report)<br>ចូលរួមក្នុងកិច្ចប្រជុំ និងចែករំលែកមេរៀនបទពិសោធន៍ ក្នុងថ្នាក់តំបន់ និងឆាកអន្តរជាតិ | ក្រសួងកិច្ចការនារី ក្រសួង ស្ថាប័ន អង្គការដៃគូអភិវឌ្ឍន៍ | ✓ | ✓ | | | | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ចំនួនកិច្ចព្រមព្រៀង និងអនុស្សរណៈនៃការយោគយល់គ្នា ដែលក្រសួងកិច្ចការនារី បានចុះហត្ថលេខា | ពិនិត្យ និងសម្របសម្រួល ក្នុងការរៀបចំឯកសារស្នើសុំ និងរៀបចំពិធីចុះកិច្ចព្រមព្រៀង និងអនុស្សរណៈនៃការយោគយល់គ្នា | ក្រសួងកិច្ចការនារី ក្រសួង ស្ថាប័ន អង្គការដៃគូអភិវឌ្ឍន៍ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | ចំនួនកិច្ចប្រជុំតាមដានការអនុវត្តកិច្ចព្រមព្រៀង និងអនុស្សរណៈនៃការយោគយល់គ្នា | ដឹកនាំកិច្ចប្រជុំតាមដានការអនុវត្តកិច្ចព្រមព្រៀង និងអនុស្សរណៈនៃការយោគយល់គ្នា រវាងក្រសួងកិច្ចការនារី និងដៃគូពាក់ព័ន្ធ | ក្រសួងកិច្ចការនារី ក្រសួង និងស្ថាប័នពាក់ព័ន្ធ អង្គការដៃគូអភិវឌ្ឍន៍ វិស័យឯកជន | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | ចំនួនលិខិតគាំទ្រដែលបានផ្តល់ជូនដៃគូពាក់ព័ន្ធ (ជាតិ និងអន្តរជាតិ) | សម្របសម្រួលក្នុងការផ្តល់លិខិតគាំទ្រ ជូនអង្គការដៃគូអភិវឌ្ឍន៍ ដើម្បីបន្តអាណត្តិ ឬចុះអនុស្សរណៈនៃការយោគយល់គ្នា ជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ក្រសួងកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| | ចំនួនវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាដែលបានរៀបចំ | រៀបចំកម្មវិធីអភិវឌ្ឍសមត្ថភាពស្តីពីការងារទំនាក់ទំនងអន្តរជាតិ និងអនុស្សរណៈនៃការយោគយល់គ្នា ដល់មន្ត្រីនិងថ្នាក់ដឹកនាំ | ក្រសួងកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | |
| ៨. ពង្រឹងសមត្ថភាព និងប្រសិទ្ធភាពស្ថាប័ន ក្នុងការឆ្លើយតបប្រកបដោយបរិយាបន្ន និងសមធម៌ ក្នុងការអនុវត្ត | ចំនួនកិច្ចប្រជុំដែលបានរៀបចំក្របខណ្ឌយុទ្ធសាស្ត្រ និងឧបករណ៍ ក្នុងការឆ្លើយតបបញ្ហាបរិយាបន្នរបស់ក្រុមស្ត្រី និងក្មេងស្រីងាយរងគ្រោះ នៅ | កិច្ចប្រជុំរបស់ក្រុមការងារទទួលបន្ទុកឆ្លើយតបក្រុមជនងាយរងគ្រោះជាស្ត្រី និងក្មេងស្រី ប្រកបដោយបរិយាបន្ន | ក្រសួងកិច្ចការនារី | √ | √ | √ | √ | √ | ✓ | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ផែន ការយុទ្ធសាស្ត្រ នារីរតនៈទី៦ ដោយ មិនទុកអ្នកណាម្នាក់ឱ្យ នៅឯកា | តាមអង្គភាព និងនាយកដ្ឋាន ក្រសួងកិច្ចការនារី | រៀបចំ និងជំរុញការអនុវត្តក្រប ខណ្ឌយុទ្ធសាស្ត្ររបស់ក្រុម ការងារ និងឧបករណ៍ឆ្លើយតប ប្រកបដោយបរិយាបន្ន និង សមធម៌ នៅតាមអង្គភាព និង នាយកដ្ឋានក្រសួងកិច្ចការនារី | | | | | | | | |
| | ចំនួនមន្ត្រីរាជការជាស្ត្រីដែល មានពិការភាព និងក្នុងថ្នាក់ធ្វើ សេចក្តីសម្រេចគ្រប់វិស័យ | ជំរុញការអនុវត្តគោលការណ៍ នានា ក្នុងការជ្រើសរើស និងគាំទ្រ ដល់ការជ្រើសរើសមន្ត្រីដែលមាន ពិការភាព<br>ពង្រឹង និងពង្រីកបរិយាកាស គាំទ្រផ្នែកគោលនយោបាយ យន្តការគាំទ្រ និងបរិយាកាសនៅ កន្លែងធ្វើការក្នុងការលើកកម្ពស់ ការចូលរួមរបស់ស្ត្រីពិការជាថ្នាក់ ដឹកនាំគ្រប់វិស័យ | ក្រសួងកិច្ចការនារី | √ | √ | √ | √ | √ | ✓ | |
| | ចំនួនវិធានការដាក់លាក់ដែល ឆ្លើយតបការអនុវត្តផែនការ យុទ្ធសាស្ត្រជាតិស្តីពីពិការ ភាពពាក់ព័ន្ធយេនឌ័រ | រៀបចំ និងអនុវត្តយន្តការ និង វិធានការក្នុងការបញ្ចូលបញ្ហា ពិការភាពក្នុងការងាររបស់អង្គ ភាព និងនាយកដ្ឋានជំនាញ | ក្រសួងកិច្ចការនារី ក្រសួងស្ថាប័ន ទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ | √ | √ | √ | √ | √ | ✓ | ✓ |
| | ចំនួនកម្មវិធីអភិវឌ្ឍសមត្ថភាព ស្តីពីយេនឌ័រ និងបញ្ហាស្ត្រី និងក្មេងស្រីដែលមានពិការ ភាព | អភិវឌ្ឍសមត្ថភាពស្តីពីយេនឌ័រ បញ្ហាស្ត្រីនិងក្មេងស្រីដែលមាន ពិការភាព ក្នុងលទ្ធភាពដើម្បី ឈានទៅអនុវត្តយុទ្ធសាស្ត្រលើក | ក្រុមការងារ សកម្មភាពជនពិការ ក្រសួងកិច្ច-ការនារី ក្រសួង ស្ថាប័ន | √ | √ | √ | √ | √ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | កម្ពស់សមភាពយេនឌ័រ ក្នុងពិការភាព និងភាពអង់អាចរបស់ស្ត្រី និងក្មេងស្រីដែលមានពិការភាព ឆ្លើយតបនឹងការវិវត្តថ្មីៗ | ពាក់ព័ន្ធនានាទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | | | | | | | |
| ៩. ការធ្វើស្ថាប័នីយកម្មឌីជីថល នៅក្នុងក្របខណ្ឌស្ថាប័ននៅថ្នាក់ជាតិ និងក្រោមជាតិ រួមទាំងការគាំទ្រស្ថាប័ន ក្នុងការធ្វើទំនើបកម្មផ្នែកឌីជីថល ក្នុងការអនុវត្តការងារប្រចាំថ្ងៃ និងបំពេញសេវាជាសាធារណៈ | ក្រុមការងារ និងអង្គភាពជំនាញ លើការងារឌីជីថល បានបង្កើតស្របតាមតម្រូវការ និងទំហំការងារ | រៀបចំយន្តការ និងអង្គភាពជាក់លាក់ ក្នុងការធ្វើបរិវត្តកម្មឌីជីថល នៅក្នុងស្ថាប័ន ក្រសួង និងមន្ទីរកិច្ចការនារី | ក្រសួងកិច្ចការនារី | ✓ | ✓ | | | | ✓ | |
| | | រៀបចំផែនការសកម្មភាព និងកម្មវិធីធ្វើបរិវត្តកម្មឌីជីថលរបស់ស្ថាប័ន ក្នុងការគាំទ្រដល់ការអនុវត្តនារីរតនៈ ទី៦ | ក្រសួងកិច្ចការនារី | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | | រៀបចំ និងអនុវត្តអនុស្សរណៈនៃការយោគយល់ រវាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងកិច្ចការនារី ស្តីពីកិច្ចសហប្រតិបត្តិការដាក់ឱ្យប្រើថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងការតភ្ជាប់អ៊ីនធឺណិតនិងការលើកកម្ពស់សមត្ថភាពផ្នែកឌីជីថល | ក្រសួងកិច្ចការនារី ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| | ចំនួនអង្គភាពដែលបានធ្វើឌីជីថលូបនីយកម្មលើកម្មវិធីអប់រំផ្សព្វផ្សាយ ចំនួនកម្មវិធីឌី | សម្របសម្រួលរៀបចំ និងអនុវត្តកម្មវិធីអភិវឌ្ឍសមត្ថភាពផ្នែកឌីជីថលក្នុងការអនុវត្តមុខងារ និង | ក្រសួងកិច្ចការនារី ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ដីថល ដែលបានបង្កើត និង ដំណើរការ ចំនួន វគ្គបណ្តុះបណ្តាល | សេវារបស់នាយកដ្ឋាន អង្គភាព និងមន្ទីរនីមួយៗ<br>អភិវឌ្ឍសមត្ថភាពផ្នែកឌីជីថល ដល់មន្ត្រី និងថ្នាក់ដឹកនាំគ្រប់កម្រិតស្របតាមក្របខណ្ឌរដ្ឋាភិបាលឌីជីថល<br>ធ្វើបច្ចុប្បន្នភាពលើទិន្នន័យ Software and Hardware របស់ក្រសួងកិច្ចការនារី | | | | | | | | |

## ផ្នែកទី ៦៖

# យន្តការអនុវត្ត តាមដាន ត្រួតពិនិត្យ និងការវាយតម្លៃ

## ការរៀបចំផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ

ដោយផ្អែកលើផែនការយុទ្ធសាស្រ្តនារីរតនៈទី៦ ក្រសួងកិច្ចការនារី ក្នុងភាពជាដៃគូជាមួយនឹងក្រសួង-ស្ថាប័ននិងដៃគូអភិវឌ្ឍន៍ នឹងរៀបចំផែនការយុទ្ធសាស្រ្តថវិកា (BSP) និងផែនការសកម្មភាពប្រចាំឆ្នាំ ដោយស្របតាមអាណត្តិនិងភារកិច្ចដែលកំណត់ដោយច្បាប់ ដែលនឹងបញ្ជាក់អំពីអង្គភាព និងនាយកដ្ឋានដែលដឹកនាំការងារ សកម្មភាពនីមួយៗ និងដៃគូពាក់ព័ន្ធជាក់លាក់។ កិច្ចការនេះ នឹងដំណើរការតាមរយៈភាពជាដៃគូ ក្នុងក្របខណ្ឌក្រុមការងារបច្ចេកទេសយេនឌ័រ កិច្ចសហប្រតិបត្តិការ និងដៃគូពាក់ព័ន្ធ។

**ការរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ** ធ្វើឡើងនៅអំឡុងចុងនិងដើមឆ្នាំនីមួយៗ ដោយផ្អែកលើផែនការយុទ្ធសាស្រ្តនារីរតនៈទី៦ និងត្រូវធ្វើបច្ចុប្បន្នភាពឱ្យឆ្លើយតបនឹងជាមួយក្របខ័ណ្ឌគោលនយោបាយនិងកម្មវិធីនានានិងស្របតាមការវិវត្តន៍របស់សង្គម។

ដោយអនុវត្តន៍តាមការណែនាំរបស់កម្មវិធីកែទម្រង់ការគ្រប់គ្រងការងារហិរញ្ញវត្ថុសាធារណៈ អង្គភាពនីមួយៗ រៀបចំផែនការយុទ្ធសាស្រ្តថវិកា ស្របតាមថវិកាសមិទ្ធកម្ម តាមរយៈការជ្រើសរើសនិងចាត់អាទិភាពពីសូចនាករសមិទ្ធកម្មគន្លឹះ ដែលបានកំណត់ក្នុងតារាងសកម្មភាពការងារ (ផ្នែកទី៥នៃឯកសារនេះ)។ ការជ្រើសរើសនិងចាត់អាទិភាពសូចនាករសមិទ្ធកម្មគន្លឹះនេះ ក៏ធ្វើឡើងឱ្យឆ្លើយតបនឹងកាតព្វកិច្ចរបស់ក្រសួងដែលត្រូវរៀបចំរបាយការណ៍ប្រចាំស្តីពីវឌ្ឍនភាព ក្នុងការអនុវត្ត**យុទ្ធសាស្រ្តបញ្ចកោណ-ដំណាក់កាលទី១** ដែលបានដាក់បញ្ចូលក្នុងក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃរបស់រាជរដ្ឋាភិបាល។ ឆ្លើយតបនឹងកិច្ចការនេះ គ្រប់នាយកដ្ឋាននិងអង្គភាពនីមួយៗ ត្រូវពង្រឹកប្រព័ន្ធកត់ត្រា និងគ្រប់គ្រងទិន្នន័យសមិទ្ធកម្មរបស់ខ្លួន។ ក្រសួងក៏ត្រូវធ្វើទំនើបកម្មតាមប្រព័ន្ធបច្ចេកវិទ្យា និងឌីជីថល ក្នុងពង្រឹងប្រព័ន្ធគ្រប់គ្រងទិន្នន័យលទ្ធផលនិងសមិទ្ធកម្មការងាររបស់អង្គភាពនីមួយៗផងដែរ។

ក្រសួងកិច្ចការនារី នឹងរៀបចំសន្និបាតប្រចាំឆ្នាំ និងកិច្ចប្រជុំពិនិត្យមើលលើវឌ្ឍនភាពតាមវិស័យ តាមលទ្ធភាពជាក់ស្តែង។

## ការត្រួតពិនិត្យ និងតាមដាន

ដោយផ្អែកលើសូចនាករដែលបានកំណត់ក្នុងផែនការយុទ្ធសាស្រ្តនេះ ផែនការសកម្មភាពប្រចាំឆ្នាំ និងរបាយការណ៍ប្រចាំឆ្នាំ ក្រសួងកិច្ចការនារី ក្នុងភាពជាដៃគូជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ នឹងធ្វើការត្រួតពិនិត្យឡើងវិញនូវការរីកចម្រើន ក្នុងរយៈពេលខ្លី និងមធ្យម។ កិច្ចការនេះ ជាឧបករណ៍ដ៏សំខាន់ ក្នុងការតម្រង់ទិសនិងកែសម្រួលវិធានការគោលនយោបាយផង និងសម្រាប់តម្រង់ទិសនិងកែសម្រួលការអនុវត្តផង

ជាពិសេសដើម្បីពង្រឹងភស្តុតាង (Evidence-based) ក្នុងការបង្ហាញដល់រាជរដ្ឋាភិបាល និងមហាជន លើសមិទ្ធកម្មរបស់ក្រសួង និងការចូលរួមអនុវត្តយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១របស់រាជរដ្ឋាភិបាល។

ក្រសួងកិច្ចការនារី ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងក្រុមការងារបច្ចេកទេសយេនឌ័រ នឹងសម្របសម្រួល ក្នុងការរៀបចំរបាយការណ៍រីកចម្រើនលើការលើកកម្ពស់សមភាពយេនឌ័រ និងការបញ្ជ្រាបយេនឌ័រជាប្រចាំ ដើម្បីចែករំលែកដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងថ្នាក់ក្រោមជាតិ ព្រមទាំងដៃគូអភិវឌ្ឍន៍។ ដូចនេះ ការត្រួតពិនិត្យនិងតាមដាននូវការរីកចម្រើនលើការអនុវត្តយុទ្ធសាស្ត្រ**នារីរតនៈទី៦** ក៏ត្រូវផ្សារភ្ជាប់នៅក្នុងរបាយការណ៍ទាំងនោះផងដែរ ។

## ការវាយតម្លៃ

ដើម្បីពិនិត្យលើប្រសិទ្ធភាពនិងសក្តិសិទ្ធិភាព នៃការអនុវត្ត**ផែនការយុទ្ធសាស្ត្រនារីរតនៈទី៦** ក្រសួងកិច្ចការនារី នឹងរៀបចំការវាយតម្លៃពាក់កណ្តាលអាណត្តិ និងសន្និបាតបូកសរុបលទ្ធផលការអនុវត្ត**ផែនការយុទ្ធសាស្ត្រនារីរតនៈទី ៦**។ រាល់ដៃគូពាក់ព័ន្ធ នឹងចូលរួមយ៉ាងទូលំទូលាយ ក្នុងការវាយតម្លៃលទ្ធផលការងារទាំងនេះ និងលើកទិសដៅបន្ត។

សន្និបាតជាតិបូកសរុបលទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រ**នារីរតនៈទី៦** នឹងរៀបចំឡើងនៅពេលបញ្ចប់អាណត្តិនៃផែនការយុទ្ធសាស្ត្រ**នារីរតនៈទី៦** តាមរយៈការចូលរួមពីភ្នាក់ងារអនុវត្តនិងដៃគូពាក់ព័ន្ធ ដើម្បីបូកសរុបអំពីលទ្ធផលដែលបានអនុវត្ត និងជាមួយនូវផលប៉ះពាល់ជាវិជ្ជមាននៃផែនការយុទ្ធសាស្ត្រនេះ។ ចំណុចសំខាន់ដែលអាចផ្ទៀងផ្ទាត់អំពីលទ្ធផលនៃការសម្រេចនេះ តាមរយៈការធ្វើបច្ចុប្បន្ននិងពិនិត្យលើការសម្រេចនូវចំណុចដៅនៃសូចនាករសំខាន់ៗដែលពាក់ព័ន្ធនឹងការលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី។

ក្រសួងកិច្ចការនារី នឹងបង្កើតក្រុមការងារតាមដាននិងវាយតម្លៃ និងរៀបចំក្របខ័ណ្ឌតាមដាននិងវាយតម្លៃនៃ**ផែនការយុទ្ធសាស្ត្រនារីរតនៈទី៦** ដែលមានគូសបញ្ជាក់អំពីតួនាទីរបស់ក្រសួងកិច្ចការនារី និងក្រសួង-ស្ថាប័នពាក់ព័ន្ធ។ នៅក្នុងន័យនេះ ការតាមរៀបចំ និងដាក់ឱ្យដំណើរការក្របខ័ណ្ឌតាមដាននិងវាយតម្លៃ គឺជាអភិក្រមនិងកិច្ចការចាំបាច់មួយរបស់**នារីរតនៈទី៦** ក្នុងការពង្រឹងស្ថាប័នរបស់ក្រសួងកិច្ចការនារីក្នុងការរៀបចំប្រព័ន្ធ និងដំណើរការប្រព័ន្ធតាមដាននិងវាយតម្លៃ ជាពិសេសលើការគ្រប់គ្រងការងារដែលផ្អែកតាមលទ្ធផល និងសមិទ្ធកម្មការងារ។ ការសិក្សានិងរៀបចំឱ្យទិន្នន័យមូលដ្ឋាន និងការកំណត់ចំណុចដៅជាក់លាក់សម្រាប់ សូចនាករ ដែលមាននៅក្នុងតារាងផែនការសកម្មភាព៥ឆ្នាំរបស់ក្រសួងកិច្ចការនារី ក៏ត្រូវគិតគូរនិងដាក់បញ្ចូលក្នុងក្របខ័ណ្ឌ។

# សូចនាករតាមដានត្រួតពិនិត្យសំខាន់ៗ ២០២៤-២០២៨

| យុទ្ធសាស្ត្រ/សូចនាករសំខាន់ៗ | | ឯកតា | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ឯកសារយោង | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|---|
| **១. ក្របខណ្ឌបញ្ជ្រាបយេនឌ័រ តាមរយៈការធ្វើបរិវត្តកម្មយេនឌ័រ** | | | | | | | | | | |
| ១ | គោលនយោបាយជាតិ ស្តីពីសមភាពយេនឌ័រ បានអនុម័ត និងដាក់ឱ្យប្រើប្រាស់ដោយរាជរដ្ឋាភិបាល | ចំនួន | | ១ | | | | | ឯកសារគោលនយោបាយ | កកន |
| ២ | ច្បាប់ គោលនយោបាយនិងកម្មវិធីជាតិ កែទម្រង់ ក្នុងការលើកកម្ពស់យេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី | ចំនួន | ៧៣ | ៧៨ | ៨៣ | ៨៨ | ៩៣ | ៩៨ | កកន | កកន |
| ៣ | ក្រសួង ស្ថាប័ន ដែលបានអនុវត្តកម្មវិធី ថវិកាឆ្លើយតបនឹងយេនឌ័រ | ចំនួន | | | ៣ | ៤ | ៥ | ៦ | កកន | កកន |
| ៤ | ក្រសួង ស្ថាប័ន ដែលបានធ្វើការពិនិត្យតាមដាន និងវាយតម្លៃ លើការអនុវត្តកម្មវិធី និងថវិកាឆ្លើយតបនឹងយេនឌ័រ | ចំនួន | | | ៣ | ៤ | ៥ | ៦ | កកន | កកន |
| ៥ | របាយការណ៍ ស្តីពីសវនកម្មយេនឌ័រ ដែលបានរៀបចំ | ចំនួន | ០ | ០ | ០ | ០ | ១ | ១ | កកន | កកន |
| ៦ | ការសិក្សាស្រាវជ្រាវស្ថានភាពយេនឌ័រតាមវិស័យ | ចំនួន | | ៣ | ៦ | ៦ | ៦ | ៦ | កកន | កកន |
| ៧ | វេទិកាជាតិ និងកិច្ចសន្ទនាផ្នែកគោលនយោបាយស្តីពីការលើកកម្ពស់ | ចំនួន | ២ | ៤ | ៥ | ៥ | ៥ | ៥ | កកន | កកន |

| យុទ្ធសាស្ត្រ/សូចនាករសំខាន់ៗ | | ឯកតា | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ឯកសារយោង | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|---|
| | សមភាពយេនឌ័រនិងបង្កើនភាពអង់អាចដល់ស្ត្រី តាមវិស័យ | | | | | | | | | |
| ៨ | ចំនួនកម្មវិធី និងយុទ្ធនាការជាតិ ក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងសិទ្ធិស្ត្រីនិងក្មេងស្រី | ចំនួន | ២ | ៤ | ៦ | ៨ | ១០ | ១២ | កកន | កកន |
| ៩ | ភាគរយនិស្សិតចុះឈ្មោះចូលរៀនក្នុងកម្មវិធីបណ្តុះបណ្តាលផ្នែកស្ទែម | % | ៣១.៥ | ៣២.០០ | ៣២.១៥ | ៣២.៥០ | ៣២.៧ | ៣៣ | របាយការណ៍សន្និបាត | ក្រសួងអប់រំ យុវជន និងកីឡា |
| ១០ | ផែនការជាតិសម្រាប់ស្ត្រី សន្តិភាព និងសន្តិសុខបានអនុម័តនិងដំណើរការ | ចំនួន | ០ | ០ | ១ | ១ | ១ | ១ | កកន | កនន |
| **២.ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី** | | | | | | | | | | |
| ១១ | ចំនួនកម្មវិធីនិងសកម្មភាពជាក់លាក់ក្នុងការអភិវឌ្ឍន៍សហគ្រិនភាពនិងអាជីវកម្មស្ត្រី | ចំនួន | ៥ | ៦ | ៧ | ៨ | ៨ | ៨ | កកន | កកន |
| ១២ | ភាគរយនៃចំនួនស្ត្រីពេញវ័យ ដែលប្រើប្រាស់សេវាហិរញ្ញវត្ថុ | % | ៥២ | ៥៤ | ៥៥ | ៥៦ | ៥៧ | ៥៨ | ធនាគារជាតិ | ធនាគារជាតិ |
| ១៣ | ភាគរយនៃចំនួនស្ត្រីជាតំណាងម្ចាស់អាជីវកម្ម | % | ៦៩ | | | | ៧៣ | | ជំរឿនសេដ្ឋកិច្ច | NIS |

| យុទ្ធសាស្ត្រ/សូចនាករសំខាន់ៗ | | ឯកតា | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ឯកសារយោង | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|---|
| ១៤ | ចំនួនសហគ្រិនស្ត្រីកម្ពុជាឆ្នើម និង ទទួលបានពានរង្វាន់ប្រចាំតំបន់ និង អន្តរជាតិ | ចំនួន | ៤៨ | ៦០ | ៧០ | ៨០ | ៩០ | ១០០ | របាយការណ៍ | សមាគមសហគ្រិនស្ត្រី |
| ១៥ | ចំនួនវិធានការផ្លូវច្បាប់ និងគោលនយោបាយដែលដោះស្រាយនិងទទួលស្គាល់នូវតុល្យភាពជីវិតគ្រួសារនិងការងារ (ការងារផ្ទះនិងការងារថែទាំដែលមិនមានកម្រៃ) និងលើកកម្ពស់ការទទួលបានកាន់តែច្រើននូវការងារសមរម្យសម្រាប់ស្ត្រី | ចំនួន | ១០ | ១១ | ១២ | ១៣ | ១៤ | ១៥ | កកន | កកន |
| ១៦ | អត្រាស្ត្រីដែលមានការងារធ្វើអាយុពី១៥-៦៤ឆ្នាំបែងចែកតាមវិស័យសេដ្ឋកិច្ច | | | | | | | | | |
| | វិស័យកសិកម្ម | % | ៣៨,៣ | | | | | | របាយការណ៍អង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា | របាយការណ៍អង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា |
| | វិស័យឧស្សាហកម្ម | % | ២៤,៣ | | | | | | | |
| | វិស័យសេវាកម្ម | % | ៣៧,៥ | | | | | | | |
| ១៧ | អត្រាប្រាក់ឈ្នួលរបស់ស្ត្រីចូលរួមក្នុងវិស័យការងារអាយុពី១៥-៦៤ឆ្នាំបែងចែងតាមវិស័យសេដ្ឋកិច្ច | | | | | | | | | |
| | វិស័យកសិកម្ម | % | ៣៥,៤ | | | | | | របាយការណ៍អង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា | របាយការណ៍អង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា |
| | វិស័យឧស្សាហកម្ម | % | ២៦,១ | | | | | | | |
| | វិស័យសេវាកម្ម | % | ៣៨,៦ | | | | | | | |

| យុទ្ធសាស្ត្រ/សូចនាករសំខាន់ៗ | | ឯកតា | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ឯកសារយោង | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|---|
| ១៨ | មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី ដែលបានធ្វើពិពិធកម្មមុខងារត្រូវបានធ្វើឱ្យប្រសើរឡើង | ចំនួន | ៧ | ៨ | ១១ | ១២ | ១៣ | ១៤ | កកន | កកន |
| | យុទ្ធសាស្ត្រស្តីពីបរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី បានរៀបចំ និងដាក់ឱ្យអនុវត្ត | ចំនួន | | ១ | | | | | កកន | |
| ១៩ | ផែនការស្តីពីសេដ្ឋកិច្ចដែលគិតគូរពីសុខុមាលភាពសម្រាប់ស្ត្រីនិងគ្រួសារត្រូវបានអនុម័ត | ចំនួន | ០ | | ១ | | | | កកន | កកន |
| ២០ | មជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនស្ត្រីបានដំណើរការជាផ្លូវការ | ចំនួន | | | ១ | | | | កកន | |
| **៣. ការលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ** | | | | | | | | | | |
| ២១ | រៀបចំផែនទីបង្ហាញផ្លូវ ដើម្បីបណ្តុះទម្លាប់មានសីលធម៌ គុណធម៌ និងសុវជីវធម៌ និងទម្លាប់គោរពច្បាប់ និងវិន័យ បានរៀបចំ | | | | | | | | | |
| ២២ | ផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ | ចំនួន | | ១ | | | | | គណៈកម្មាធិការជាតិ | គណៈកម្មាធិការជាតិ |

| យុទ្ធសាស្ត្រ/សូចនាករសំខាន់ៗ | | ឯកតា | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ឯកសារយោង | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|---|
| ២៣ | ចំនួនទារកដ្ឋានដែលបានបង្កើត និង ប្រើប្រាស់នៅតាមក្រសួង-ស្ថាប័ន និង វិស័យឯកជន | ចំនួន | ០២ | ០៤ | ០៦ | ០៨ | ១០ | ១២ | នារីរតនៈ៦ | ក.ក.ន |
| ២៤ | ចំនួនខេត្តគោលដៅដែលអនុវត្តកម្មវិធី ស្តីពីការចិញ្ចឹមកូនបែបវិជ្ជមាននៅតាម សហគមន៍ | ចំនួន | ៩ | ៩ | ១០ | ១០ | ១២ | ១២ | របាយការណ៍ បូកសរុបប្រចាំឆ្នាំ | ក.ក.ន |
| **៤. .ការលើកកម្ពស់សុខុមាលភាពរបស់ស្ត្រី និងក្មេងស្រី** | | | | | | | | | | |
| ២៥ | សមាមាត្ររបស់ស្ត្រីអាយុពី ២០ ដល់ ២៤ឆ្នាំ ដែលបានរៀបការឬរស់នៅ ជាមួយគ្នាមុនអាយុ១៨ឆ្នាំ | % | ១៤,៩ | | | | ១៣ | | ជំរឿន/CDHS | ជំរឿន /CDHS |
| ២៦ | អត្រាមរណភាពមាតាក្នុង១០០ពាន់ កំណើតរស់ | % | ១៥៤ | | | ១២៥ | | | CDHS | CDHS |
| ២៧ | សមាមាត្រស្ត្រីក្នុងវ័យបន្តពូជ(១៥-៤៩ឆ្នាំ)ដែលប្រើមធ្យោបាយពន្យា កំណើតទំនើប | % | ៤៥ | | | ៥៥ | | | CDHS | CDHS |
| ២៨ | សមាមាត្រស្ត្រីវ័យជំទង់អាយុ ១៥-១៩ ឆ្នាំ មានគភ៌ | % | ៤៨ | | | ៣៥ | | | CDHS | CDHS |
| ២៩ | សមាមាត្រស្ត្រីអាយុពី១៥-១៩ឆ្នាំ មាន សភាពស្គមស្គាំង | % | ២៩ | | | ២០ | | | CDHS | CDHS |

| យុទ្ធសាស្ត្រ/សូចនាករសំខាន់ៗ | | ឯកតា | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ឯកសារយោង | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|---|
| ៣០ | សមាមាត្រស្ត្រីអាយុពី២០-៤៩ឆ្នាំ មានសភាពស្គមស្គាំង | % | ៧ | | | ៥ | | | CDHS | CDHS |
| ៣១ | ទារកអាយុពី០ ដល់៥ ខែ ទទួលបានការបំបៅដោយទឹកដោះម្ដាយសុទ្ធ | % | ៥១ | | | ៦៥ | | | CDHS | CDHS |
| ៣២ | សមាមាត្រនៃស្ត្រីក្នុងវ័យបន្តពូជ(១៥-៤៩ឆ្នាំ) ដែលត្រូវការសេវាផែនការគ្រួសារបានពេញចិត្តនឹងមធ្យោបាយពន្យាកំណើតទំនើប | % | ៧៤ | | | ៧៧ | | ៧៧ | CDHS | CDHS |
| ៣៣ | ស្ត្រីអាយុពី៣០-៤៩ឆ្នាំ ដែលបានទទួលការស្រាវជ្រាវរកជម្ងឺមហារីកមាត់ស្បូន យ៉ាងតិច១លើក | % | ១២ | | | ១៤ | | ១៦ | CDHS | CDHS |
| ៣៤ | ច្បាប់គោលនយោបាយ ផែនការ និងលិខិតបទដ្ឋានគតិយុត្តដែលធានាឱ្យស្ត្រីគ្រប់រូប មានលទ្ធភាពទទួលបានព័ត៌មានការអប់រំនិងសេវាសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ | ចំនួន | ១៥ | ១៦ | ១៧ | ១៨ | ១៩ | ២០ | MoWA MOH | MoWA MOH |
| ៣៥ | សមាមាត្រស្ត្រីអាយុពី១៥-៤៩ឆ្នាំ បានពិនិត្យរកជំងឺមហារីកសុដន់ | % | ១១ | | | ២០ | | | CDHS | CDHS |
| ៣៦ | សមាមាត្រស្ត្រីអាយុពី១៥-៤៩ឆ្នាំបានធ្វើតេស្តពិនិត្យរកជំងឺមហារីកមាត់ស្បូន | % | ១៥ | | | ២៥ | | | CDHS | CDHS |

| យុទ្ធសាស្ត្រ/សូចនាករសំខាន់ៗ | | ឯកតា | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ឯកសារយោង | ប្រភព ទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|---|
| ៣៧ | អត្រាប្រេវ៉ាឡង់នៃភាពពិការភ្នែកទាំងសងខាង លើស្ត្រីវ័យលើសពី៥០ឆ្នាំ | % | ៣,២ | | | ២,៥ | | | RAAB | RAAB |
| ៣៨ | ចំនួនវិធានការគោលនយោបាយ និងកម្មវិធីដែលទទួលបានជាតុចូលពីក្រសួងកិច្ចការនារី ដែលបានឆ្លើយតបក្នុងក្របខ័ណ្ឌជាតិគាំពារសង្គម | ចំនួន | | | ១ | ១ | ១ | ១ | MoWA | MoWA |
| **៥. កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រី និងក្មេងស្រី** | | | | | | | | | | |
| ៣៩ | ចំនួនកន្លែងផ្តល់សេវាចម្រុះឆ្លើយតបចំពោះជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ | ចំនួន | ០៦ | ០៨ | ១០ | ១២ | ១៤ | ១៦ | នារីរតនៈ៦ | ក.ក.ន |
| ៤០ | សមាមាត្ររបស់ស្ត្រីនិងក្មេងស្រី ដែលមានអាយុ ១៥ឆ្នាំឡើង ដែលធ្លាប់ទទួលរងនូវអំពើហិង្សាលើរាងកាយ ផ្លូវភេទឬផ្លូវចិត្ត ពីដៃគូបច្ចុប្បន្ន ឬអតីតក្នុងជីវិត | % | ២១ | | | ១៨ | | | របាយការណ៍ | CDHS |
| ៤១ | ផែនការជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីត្រូវបានអនុម័តនិងអនុវត្ត | ចំនួន | ៣ | | ៤ | | | ៤ | TWG-G/GBV | TWG-G/GBV |
| ៤២ | យុទ្ធនាការ ស្តីពីបញ្ចប់អំពើហិង្សាលើស្ត្រី | ចំនួន | ២ | ៤ | ៦ | ៨ | ១០ | ១២ | កកន | កកន |
| ៤៣ | ចំនួនយុទ្ធនាការស្តីពីផលជះនៃអំពើហិង្សាក្នុងគ្រួសារ និងការកេងប្រវ័ញ្ចផ្លូវ | ចំនួន | ១២ | ២៤ | ៣៦ | ៤៨ | ៦០ | ៧១ | កកន | កកន |

| យុទ្ធសាស្ត្រ/សូចនាករសំខាន់ៗ | | ឯកតា | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ឯកសារយោង | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|---|
| | ភេទ ការជួញដូរមនុស្សនិងកិច្ចការពារការប្រើប្រាស់និងការចែកចាយគ្រឿងញៀនតាមអនឡាញនិងផ្ទាល់ | | | | | | | | | |
| ៤៤ | ចំនួនគោលការណ៍ណែនាំ ស្តីពីសេវាពហុវិស័យ ដើម្បីជួយជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រឆ្លើយតបក្រុមកការងារពហុវិស័យនិងសេវាផែនទី | ចំនួន | ០ | ១ | | ៣ | | ៥ | កកន | កកន |
| ៤៥ | ចំនួនការសិក្សាស្រាវជ្រាវជាតិស្តីពីការរៀបអាពាហ៍ពិពាហ៍វ័យក្មេងដោយបង្ខំ | ចំនួន | ០ | ១ | | | | ២ | កកន | កកន |
| ៤៦ | ចំនួនផែនការជាតិស្តីពីការទប់ស្កាត់ការរៀបអាពាហ៍ពិពាហ៍វ័យក្មេង និងការមានផ្ទៃពោះ | ចំនួន | ០ | ០ | ១ | | | | កកន | កកន |
| ៤៧ | ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជួយជនរងគ្រោះត្រូវបានធ្វើវិសោធនកម្ម និងបានអនុវត្ត | ចំនួន | | | ១ | | | | TWG-G/GBV | TWG-G/GBV |
| ៤៨ | ចំនួនក្រុមការងារឆ្លើយតបពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ | ចំនួន | ១០ | ១៣ | ១៨ | ២០ | ២២ | ២៥ | កកន | កកន |
| **៦. ស្ត្រី ក្នុងភាពជាអ្នកដឹកនាំ និងអភិបាលកិច្ច** | | | | | | | | | | |
| ៤៩ | សមាមាត្រស្ត្រីនៅក្នុងព្រឹទ្ធសភា | % | ១៦.១៣ | ១៧.៧៤ | | | | ២០ | លទ្ធផលបោះឆ្នោត | លទ្ធផលបោះឆ្នោត |

| យុទ្ធសាស្ត្រ/សូចនាករសំខាន់ៗ | | ឯកតា | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ឯកសារយោង | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|---|
| ៥០ | សមាមាត្រស្ត្រីនៅក្នុងរដ្ឋសភា | % | ១៣.៦ | | | | | ២៥ | លទ្ធផលបោះឆ្នោត | |
| ៥១ | សមាមាត្រស្ត្រីជាសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ | % | ២២ | | | | ២៥ | | លទ្ធផលបោះឆ្នោត | គ.ជ.ប |
| ៥២ | សមាមាត្រស្ត្រីមានតួនាទីជាអ្នកគ្រប់គ្រងក្នុងវិស័យ សាធារណៈ(អគ្គនាយក អគ្គនាយករង ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ អនុប្រធានការិយាល័យ) | % | ២៧ | ២៨ | ២៩ | ៣០ | ៣១ | ៣១ | ក្រ.មុខងារសាធារណៈ | ក្រ.មុខងារសាធារណៈ |

# គំនូសបំព្រួញ ស្តីពីផែនការយុទ្ធសាស្ត្រនារីរតនៈទី ៦

## ផែនការយុទ្ធសាស្ត្រ ដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងភាពអង់អាចរបស់ស្ត្រីនិងក្មេងស្រី

**ក្របខ័ណ្ឌបញ្ជ្រាបយេនឌ័រ**

តាមរយៈការធ្វើបរិវត្តកម្មយេនឌ័រ នៅក្នុងក្របខ័ណ្ឌច្បាប់ គោលនយោបាយ កម្មវិធីជាតិ និងតាមវិស័យ និងការផ្លាស់ប្តូរឥរិយាបថជាសាធារណៈ

| យុទ្ធសាស្ត្រទី១ | យុទ្ធសាស្ត្រទី២ | យុទ្ធសាស្ត្រទី៣ | យុទ្ធសាស្ត្រទី៤ | យុទ្ធសាស្ត្រទី៥ | យុទ្ធសាស្ត្រទី៦ |
| --- | --- | --- | --- | --- | --- |
| ការបង្កើន ភាពអង់អាច ផ្នែកសេដ្ឋកិច្ច របស់ស្ត្រី | ការលើកកម្ពស់ សីលធម៌សង្គម តម្លៃស្ត្រី និង គ្រួសារ | ការលើកកម្ពស់ សុខុមាលភាព របស់ស្ត្រី និង ក្មេងស្រី | កិច្ចការពារ ផ្លូវច្បាប់សម្រាប់ ស្ត្រី និងក្មេងស្រី | ស្ត្រី ក្នុង ភាពជាអ្នកដឹកនាំ និងអភិបាលកិច្ច | ស្ត្រី និង ការប្រែប្រួល អាកាសធាតុ |

**ការពង្រឹងប្រសិទ្ធភាព និងអភិវឌ្ឍន៍សមិទ្ធកម្មស្ថាប័ន**

ការអនុវត្តកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ វិមជ្ឈការនិងវិសហមជ្ឈការ ការធ្វើទំនើបកម្មស្ថាប័ន ឌីជីថលលូបនីយកម្ម ការអភិវឌ្ឍធនធានមនុស្ស ការពង្រឹងប្រព័ន្ធតាមដាននិងវាយតម្លៃ ការគ្រប់គ្រងព័ត៌មាន ទំនាក់ទំនងសាធារណៈ និងកិច្ចសហប្រតិបត្តិការ

# សន្ទានុក្រម

វាក្យសព្ទដែលប្រើក្នុងផែនការយុទ្ធសាស្ត្រនារីរតនៈ ឆ្នាំ២០២៤-២០២៨ កំណត់ខ្លឹមសារ ដូចខាងក្រោម៖

| | |
|---|---|
| បរិវត្តកម្មយេនឌ័រ (Gender Transformative) | សំដៅដល់ការបញ្ជ្រាបយេនឌ័រ ដែលផ្ដោតលើការគិតគូរបន្ថែម លើសកម្មភាពឆ្លើយតបនឹងការផ្លាស់ប្ដូរ ឈានទៅកាត់បន្ថយគម្លាតយេនឌ័រតាមវិស័យ តួនាទី និងទំនាក់ទំនងយេនឌ័រ រួមទាំងការឆ្លើយតបនឹងតម្រូវការជាយុទ្ធសាស្ត្ររបស់បុរស ស្ត្រី និងក្រុមបរិយាបន្ន ក្នុងគោលបំណងរួមចំណែកផ្លាស់ប្ដូររចនាសម្ព័ន្ធរយៈពេលវែង ទទួលបាននូវចីរភាពនៅក្នុងសង្គម និងសម្រេចបានសមភាពយេនឌ័រ។<br>បរិវត្តកម្មយេនឌ័រ គឺជាដំណាក់កាលទី៣ នៃការបញ្ជ្រាបយេនឌ័រ ដែលដំណាក់កាលទី១ គឺការបង្កើនការយល់ដឹងយេនឌ័រ និងដំណាក់កាលទី២ គឺការលើកកម្ពស់ការឆ្លើយតបយេនឌ័រ។ |
| ស្ថានភាពយេនឌ័រតាមវិស័យ (Gender Situation in Sector) | សំដៅដល់វឌ្ឍនភាព បញ្ហាប្រឈម គម្លាត និងកាលានុវត្តភាព អំពីការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រីនៅតាមវិស័យ។ |
| ភាគលាភយេនឌ័រ (Gender Dividend) | សំដៅដល់សក្ដានុពលកំណើនសេដ្ឋកិច្ច ដែលអាចជាលទ្ធផលនៃការវិនិយោគលើស្ត្រី និងក្មេងស្រី។ គំនិតចម្បង គឺថា ដោយសារតែវិសមភាពយេនឌ័រមានផលប៉ះពាល់អវិជ្ជមានដល់ស្ត្រីនិងក្មេងស្រីពេញមួយជីវិតរបស់ពួកគេ ការកាត់បន្ថយ វិសមភាពយេនឌ័រ គឺជារឿងត្រឹមត្រូវ ប៉ុន្តែក៏មានអត្ថប្រយោជន៍ដល់សេដ្ឋកិច្ច យ៉ាងច្រើនផងដែរ ដែលបណ្ដាលមកពីការកាត់បន្ថយវិសមភាពយេនឌ័រ។ ដូច្នេះ ភាគលាភយេនឌ័រត្រូវបានគេហៅថា «**ករណីជំនួញ**» សម្រាប់សមភាពយេនឌ័រ ដែលការជម្នះបាននូវផលអវិជ្ជមាននៃវិសមភាពយេនឌ័រលើមូលធនមនុស្ស នឹងនាំមកនូវកំណើនសេដ្ឋកិច្ចយ៉ាងខ្លាំង នៃមូលធនមនុស្ស និងផលិតភាពនៃកម្លាំងពលកម្ម។ |
| សមភាពយេនឌ័រ (Gender Equality) | សំដៅដល់សិទ្ធិ ការទទួលខុសត្រូវ និងកាលានុវត្តភាពនានា ដោយស្មើភាពគ្នារបស់ស្ត្រី បុរស ក្មេងស្រី និងក្មេងប្រុស។ ក្នុងន័យនេះ សមភាពយេនឌ័រ សំដៅលើការធានាឱ្យមានគោលការណ៍គ្មានការរើសអើងលើភេទណាមួយ ក្នុងគោលដៅដើម្បីឱ្យស្ត្រី បុរស ក្មេងស្រី និងក្មេងប្រុសមានឱកាស តម្លៃ ធនធាន និងផលប្រយោជន៍ដូចៗគ្នាដោយពិតប្រាកដនៅក្នុងគ្រួសារ សហគមន៍ ស្ថាប័ន និងសង្គម។ |

| | |
|---|---|
| សមធម៌យេនឌ័រ (Gender Equity) | សំដៅដល់វិធានការ គោលការណ៍ និងមធ្យោបាយនានា ដែលបង្កលក្ខណៈ ឬផ្តល់ឱកាសដល់បុគ្គល ឬក្រុមណាមួយ ដើម្បីកាត់បន្ថយគម្លាត និងឈានទៅសម្រេចបានសមភាពយេនឌ័រពិតប្រាកដ។ |
| ការឆ្លើយតបនឹងយេនឌ័រ (Gender Responsive) | សំដៅដល់ការយកចិត្តទុកដាក់ ការគិតគូរ និងដោះស្រាយអំពីបញ្ហាវិសមភាព យេនឌ័រនៅក្នុងគ្រប់ដំណាក់កាល និងគ្រប់ផ្នែកនៃដំណើរការ ឬកិច្ចការ ឬ ស្ថាប័នណាមួយ។ ឧទាហរណ៍ គោលនយោបាយដែលឆ្លើយតបយេនឌ័រ សំដៅដល់គោលនយោបាយដែលបានគិតគូរ និងដោះស្រាយបញ្ហាវិសមភាពយេនឌ័រនៅក្នុងដំណាក់កាលតាក់តែងរៀបចំ តាមរយៈការវិភាគយេនឌ័រ និងមានវិធានការជាក់លាក់ក្នុងការឆ្លើយតបវិសមភាពយេនឌ័រក្នុងវិស័យនានា នៅក្នុងក្របខ័ណ្ឌគោលនយោបាយនោះ ព្រមទាំងបញ្ជាក់អំពីធនធានក្នុងការអនុវត្ត។ |
| ការវិនិយោគលើសមភាពយេនឌ័រ (Gender Equality Investment) | សំដៅដល់ការដាក់ចេញនូវវិធានការជាក់លាក់ ដើម្បីបង្កើត និងបង្កើនចំណាយ សាធារណៈលើសមភាពយេនឌ័រ ព្រមទាំងមានការពិនិត្យ តាមដាន និងវិភាគផលប៉ះពាល់នៃចំណាយសាធារណៈទៅលើវិសមភាពយេនឌ័រ តាមរយៈការធ្វើកម្មវិធីថវិកាដែលឆ្លើយតបនឹងយេនឌ័រ។ |
| ថវិកាដែលឆ្លើយតបនឹងយេនឌ័រ (Gender Responsive Budgeting) | សំដៅដល់វិធីសាស្ត្រ ក្នុងការរៀបចំ និងអនុវត្តថវិកាដែលឆ្លើយតបនឹងតម្រូវការ និងដោះស្រាយគម្លាតយេនឌ័រនៅតាមវិស័យ ស្ថាប័ន ឬសហគមន៍។ |
| ការបញ្ជ្រាបយេនឌ័រ (Gender Mainstreaming) | សំដៅដល់យុទ្ធសាស្ត្រ វិធីសាស្ត្រ និងវិធានការឆ្លើយតបនឹងវិសមភាពយេនឌ័រក្នុងគោលនយោបាយតាមវិស័យ កម្មវិធី លិខិតបទដ្ឋានគតិយុត្ត ស្ថាប័ន សហគមន៍ និងគ្រួសារជាដើម។ |
| អំពើហិង្សាទាក់ទងនឹងយេនឌ័រ (Gender Based Violence) | សំដៅដល់អំពើហិង្សាដោយផ្ទាល់លើស្ត្រី និងក្រុមងាយរងគ្រោះ ដែលកើតឡើងដោយសារតែពួកគាត់ជាភេទស្រី ឬផ្នត់គំនិតយេនឌ័រ និងមានស្ថានទម្ងន់នៃផលប៉ះពាល់ផ្សេងៗគ្នា។ អំពើហិង្សានេះ រាប់បញ្ចូលទាំងសកម្មភាពទាំងឡាយណាដែលធ្វើឱ្យមានរបួសស្នាមដល់រាងកាយ ផ្លូវចិត្ត ឬគ្រោះថ្នាក់ផ្លូវភេទ ឬបង្កការឈឺចាប់ ការគំរាមកំហែងដោយសកម្មភាពបង្ខិតបង្ខំ និងការដកហូតសិទ្ធិសេរីភាពជាដើម។ |
| ផ្នត់គំនិតយេនឌ័រ | សំដៅដល់ផ្នត់គំនិតរបស់សង្គម សហគមន៍ គ្រួសារ ឬបុគ្គលដែលបែងចែកការងារ សិទ្ធិ អំណាច ការទទួលខុសត្រូវដល់បុគ្គលម្នាក់ៗដោយផ្អែកលើភេទ ឬយេនឌ័ររបស់បុគ្គលនោះ។ |

| | |
|---|---|
| ( Gender Stereotype or Mindset ) | |
| ការវិភាគយេនឌ័រ ( Gender Analyses ) | សំដៅដល់ការវិភាគឱ្យឃើញនូវឫសគល់និងផលប៉ះពាល់នៃវិសមភាពយេនឌ័រដែលមានក្នុងសង្គម តាមវិស័យ និងអង្គភាព។ |
| ផលប៉ះពាល់យេនឌ័រ ( Gender Impact ) | សំដៅដល់ប្រភេទនិងទំហំនៃផលប៉ះពាល់ជាអវិជ្ជមាន ដែលកើតឡើងពីវិសមភាពយេនឌ័រលើសង្គម ស្ថាប័នតាមវិស័យ និងនៅក្នុងគ្រួសារ។ |
| សវនកម្មយេនឌ័រ ( Gender Audit ) | សំដៅដល់ឧបករណ៍និងវិធីសាស្ត្រក្នុងការពិនិត្យនិងប៉ាន់ប្រមាណលើវឌ្ឍនភាព បញ្ហាប្រឈម គម្លាត កាលានុវត្តភាព និងអនុសាសន៍ក្នុងការលើកកម្ពស់សមភាពយេនឌ័រក្នុងស្ថាប័នឬវិស័យណាមួយ តាមរយៈការប្រៀបធៀបរវាងការប្តេជ្ញាចិត្តនិងគោលនយោបាយរបស់ស្ថាប័នឬវិស័យជាមួយនឹងស្ថានភាពជាក់ស្តែង។ |
| គម្លាតយេនឌ័រ ( Gender Gap ) | សំដៅដល់ទំហំ ឬវិសាលភាពនៃការឃ្លាតនិងការទទួលបានសិទ្ធិ តម្លៃ អត្ថប្រយោជន៍ ឬភាពជាតំណាងរបស់ក្រុមភេទណាមួយ ក្នុងសង្គម សហគមន៍ ស្ថាប័ន គ្រួសារ និងតាមវិស័យ។ គម្លាតនេះកើតចេញពីកត្តាជីវសាស្ត្រនិងកត្តាសង្គម ដែលរារាំងដល់ការទទួលបានសិទ្ធិ តម្លៃ អត្ថប្រយោជន៍ និងភាពជាតំណាងពេញលេញ។ |
| វិសមភាពយេនឌ័រ ( Gender Inequality ) | សំដៅដល់ការប្រព្រឹត្តទៅរបស់សង្គមឬវប្បធម៌ដែលបានចាត់ទុកភាពខុសគ្នាឬមិនស្មើគ្នាឬលម្អៀងទៅភេទណាមួយដោយផ្អែកលើកត្តាភេទឬយេនឌ័រ។ |
| ស្ថិតិយេនឌ័រ ( Gender Statistic ) | សំដៅដល់ស្ថិតិដែលឆ្លុះបញ្ចាំងពីភាពខុសគ្នា និងវិសមភាពនៃស្ថានភាពរបស់ស្ត្រី បុរស និងក្រុមជនងាយរងគ្រោះនានាលើគ្រប់វិស័យនិងគ្រប់កម្រិត។ |
| ទិន្នន័យបែងចែកតាមភេទ ( Sex-Disaggregated Data ) | សំដៅដល់ការរៀបចំប្រព័ន្ធប្រមូលនិងគ្រប់គ្រងទិន្នន័យរបស់ស្ថាប័ននិងអង្គភាពនានាដែលបានបែងចែកច្បាស់លាស់តាមភេទរបស់ក្រុមគោលដៅ អ្នកទទួលផល និងអ្នកគ្រប់គ្រងទៅតាមប្រភេទនិងផ្នែកនីមួយ។ ទិន្នន័យបែងចែកតាមភេទជាផ្នែកដ៏សំខាន់មួយក្នុងការរៀបចំស្ថិតិយេនឌ័រនៅតាមវិស័យនិងអង្គភាពស្ថាប័ននានា។ |
| ការបង្កើនភាពអង់អាចដល់ស្ត្រី | សំដៅដល់វិធានការដើម្បីបង្កើនសមត្ថភាព អភិវឌ្ឍសក្តានុពល និងការការពារផលប្រយោជន៍ដល់ស្ត្រី។ |

| | |
|---|---|
| Women's Empowerment ) | |
| បរិយាបន្ន ( Inclusion ) | សំដៅដល់ការដាក់បញ្ចូល ការយកចិត្តទុកដាក់ និងឆ្លើយតបដល់គ្រប់ក្រុម គោលដៅនៅក្នុងសង្គម ស្ថាប័ន និងគ្រួសារ ដោយសំដៅ «មិនទុកឱ្យនរណាម្នាក់នៅឯកោ» លើក្រុមគោលដៅដែលងាយរងគ្រោះ និងបាត់បង់ឱកាសនៅក្នុងសង្គមដូចជា ជនមានពិការភាព ក្រុម LGBTIQI+ ជនជាតិដើមភាគតិច កុមារ ស្ត្រី មនុស្សវ័យចាស់ជាដើម។ |
| តុល្យភាពជីវិតនិងការងារនៅកន្លែងធ្វើការ ( Work-Life Balance ) | សំដៅដល់វិធានការរបស់ស្ថាប័ន និងរដ្ឋក្នុងការគាំទ្រដល់បុគ្គលិក និងគ្រួសារក្នុងគោលដៅឱ្យមានតុល្យភាព នៃគុណភាពការងារ និងគុណភាពជីវិត ដែលក្នុងនោះមានដូចជាការគិតគូរ និងឆ្លើយតបសម្រាប់ការសម្រាកលំហែមាតុភាព ការសម្រាកថែទាំគ្រួសារ ការរៀបចំកន្លែងថែទាំកុមារនៅកន្លែងធ្វើការ និងការរៀបចំការងារដែលមានភាពបត់បែនទៅតាមស្ថានភាពចាំបាច់ ឬតម្រូវការបុគ្គលិកនិងគ្រួសាររបស់ពួកគេ។ |
| ស្ថាបនូបយកម្មយេនឌ័រ ( Gender Institutionalization ) | សំដៅលើដំណើរការនៃការសម្រេចសមភាពយេនឌ័រ នៅក្នុងស្ថាប័ន។ ដំណើរការនេះតម្រូវធ្វើឡើងជាប្រព័ន្ធ និងក្នុងរចនាសម្ព័ន្ធផ្លូវការរបស់ស្ថាប័ន និងអង្គភាពចំណុះនីមួយៗ រួមទាំងនៅក្នុងការគ្រប់គ្រងធនធានមនុស្សរបស់ស្ថាប័ន ការរៀបចំផែនការនិងថវិកា ការប្រាស្រ័យទាក់ទងនិងព័ត៌មាន កិច្ចការផ្តល់សេវាកម្ម ដល់ក្រុមគោលដៅរបស់ខ្លួន និងការតាមដាននិងវាយតម្លៃជាដើម។ |
| ឌីជីថលូបនីយកម្ម ( Digitalization ) | សំដៅលើដំណើរការនៃការកែសម្រួលអភិបាលកិច្ច ស្ថាប័ន ឬដំណើរការការងារឱ្យមានប្រសិទ្ធភាព តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងទិន្នន័យក្នុងទម្រង់ឌីជីថល។ |
| មាតិកាព័ត៌មានយេនឌ័រ ( Gender Media Content ) | សំដៅលើមាតិកា ឬខ្លឹមសារព័ត៌មាន ដែលឆ្លើយតបនឹងការផ្លាស់ប្តូរផ្នត់គំនិតអវិជ្ជមានរបស់សង្គម និង មហាជន ដែលឈានទៅលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី។ នៅក្នុងសម័យដែលបណ្តាញសង្គម និងប្រព័ន្ធឌីជីថល ដើរតួនាទីកាន់តែសំខាន់ ក្នុងការផ្សព្វផ្សាយ និងកិច្ចការផ្សេងៗ នៅក្នុងការរស់នៅប្រចាំថ្ងៃ ការរៀបចំមាតិកាព័ត៌មានយេនឌ័រ តម្រូវការឱ្យមានការរៀបចំ និងធ្វើឱ្យមានការទាក់ទាញពីមហាជន ដើម្បីជានាបណ្តាញសង្គម និងពិភពអនឡាញ អាចចូលរួមប្រកបដោយវិជ្ជមាន ក្នុងការផ្លាស់ប្តូរផ្នត់គំនិតអវិជ្ជមាន និងបណ្តុះផ្នត់គំនិតវិជ្ជមាន ក្នុងការលើកកម្ពស់សមភាពយេនឌ័រ នៅក្នុងសង្គម។ |

# សូមអរគុណដល់ដៃគូពាក់ព័ន្ធ
# ដែលបានចូលរួមគាំទ្រ នៅក្នុងដំណើរការតាក់តែង បោះពុម្ព
# និងផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រនារីរតនៈទី៦

ក្រសួងកិច្ចការនារី
ផ្លូវទ្រុងមាន់ ភូមិដំណាក់ធំ ៣ សង្កាត់ស្ទឹងមានជ័យ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
អ៊ីម៉ែល៖ info@mowa.gov.kh
វេបសាយ៖ www.mowa.gov.kh
ហ្វេសប៊ុក៖ www.facebook.com/mowa.gov.kh